ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅណែនាំ
# ស្តីពី
# ការគ្រប់គ្រងការស្រាវជ្រាវ
# នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស.ភ.ភ.ព.)



រៀបចំដោយ
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស.ភ.ភ.ព.)
ឧសភា ២០២៣

# មាតិកា


មាតិកា ........................................ ១
បុព្វកថា ........................................ ៤
អារម្ភកថា ........................................ ៥
សេចក្ដីផ្ដើម ........................................ ៦
ជំពូកទី១
ក្របខណ្ឌគោលនយោបាយនៃការគ្រប់គ្រងការស្រាវជ្រាវ ........................................ ៨
១. ចក្ខុវិស័យ ........................................ ៨
២. បេសកកម្ម ........................................ ៨
៣. គោលបំណងនៃប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវ ........................................ ៨
៤. យុទ្ធសាស្ត្រ ........................................ ៩
៥. វដ្តនៃដំណើការគ្រប់គ្រងការស្រាវជ្រាវ ........................................ ១០
៦. ការកំណត់អាទិភាព និងប្រភេទនៃការស្រាវជ្រាវ ........................................ ១១
៦.១. វិស័យអាទិភាព ........................................ ១១
៦.២. ប្រភេទនៃការស្រាវជ្រាវ ........................................ ១២
ជំពូកទី២
ក្របខណ្ឌអនុវត្តការគ្រប់គ្រងការស្រាវជ្រាវ ........................................ ១៤
១. រចនាសម្ព័ន្ធគ្រប់គ្រងការស្រាវជ្រាវ ........................................ ១៤
២. តួនាទីនិងភារកិច្ចរបស់ការិយាល័យទាំងបី ........................................ ១៦
២.១. ការិយាល័យតាមដាននិងវាយតម្លៃគម្រោងស្រាវជ្រាវ ........................................ ១៦
២.២. ការិយាល័យកម្មសិទ្ធិបញ្ញា និងនវានុវត្តន៍ ........................................ ១៧
២.៣. ការិយាល័យបោះពុម្ពផ្សាយ និងគាំទ្រទស្សនាវដ្ដីវិទ្យាសាស្ត្រ ........................................ ១៧
ជំពូកទី៣
ក្របខណ្ឌអំណាច និងការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ ........................................ ១៩
១. ក្របខណ្ឌអនុវត្តលើការស្រាវជ្រាវ ........................................ ១៩
១.១. ការកំណត់សូចនាករផលសម្រេចលើការស្រាវជ្រាវ ........................................ ១៩
១.២. ការកំណត់ផែនការសកម្មភាពពី ៣ ទៅ ៥ឆ្នាំ ក្នុងប្រព័ន្ធធានាគុណភាពអប់រំឧត្តមសិក្សា ...២០
២. ការពិនិត្យតាមដាន និងវាយតម្លៃ ........................................ ២២

២.១. ការពិនិត្យតាមដានសកម្មភាពស្រាវជ្រាវ........................................................................២២
២.២. ការវាយតម្លៃសមត្ថភាពស្រាវជ្រាវ.............................................................................២២
៣. ការអភិវឌ្ឍធនធានមនុស្ស........................................................................................២៦
៣.១. ចំនួនអ្នកស្រាវជ្រាវ...................................................................................................២៦
៣.២. តម្រូវការបណ្តុះជំនាញសម្រាប់អ្នកស្រាវជ្រាវ ..............................................................២៧
៣.៣. ការកសាងសមត្ថភាពស្រាវជ្រាវ.................................................................................២៩
៣.៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវ.......................................................................៣១
៣.៥. ការបណ្តុះបណ្តាល និងកសាងសមត្ថភាព ..................................................................... ៣២
៣.៦. ការថែរក្សានិងលើកទឹកចិត្តអ្នកស្រាវជ្រាវ ...................................................................... ៣៣
៤. ជំរុញកំណើនផលិតភាពនៃការស្រាវជ្រាវ .......................................................................៣៤
៤.១. យន្តការគាំទ្រការវិនិយោគលើការស្រាវជ្រាវសម្រាប់កម្មវិធីមួយ ........................................៣៤
ផលិតផលមួយ ..................................................................................................................៣៤
៤.២. យន្តការគ្រប់គ្រង និងលើកកម្ពស់គុណភាពស្រាវជ្រាវ.......................................................៣៥
៤.២.១. ដំណើរការជ្រើសរើសគម្រោងស្រាវជ្រាវ....................................................................៣៥
៤.២.២. ថវិកាស្រាវជ្រាវ......................................................................................................៣៥
៤.២.៣. យន្តការគ្រប់គ្រង និងលើកកម្ពស់គុណភាពស្រាវជ្រាវ................................................. ៣៧
៤.២.៤. ប្រព័ន្ធតាមដាននិងវាយតម្លៃ......................................................................................៣៨
៤.២.៥. ការរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានអ្នកស្រាវជ្រាវ .........................................................៣៩
៤.២.៦. ការពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តគម្រោងស្រាវជ្រាវនៅគ្រឹះស្ថាន.................... ៤០
៤.២.៧. កសាងអន្តរកម្មរវាងគ្រឹះស្ថាន វិស័យឯកជនឬឧស្សាហកម្ម និងសហគមន៍................. ៤១
ជំពូកទី៤
ក្របខណ្ឌអនុវត្តប្រព័ន្ធផ្តល់ថាមពលគាំទ្រការងារស្រាវជ្រាវ.................................................. ៤៥
១. ការកសាងកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ ........................................................... ៤៥
២. ការវាយតម្លៃការអនុវត្តការងារស្រាវជ្រាវ........................................................................ ៤៦
២.១. កិច្ចការដែលត្រូវរៀបចំនិងផ្តល់ការណែនាំមុនពេលវាយតម្លៃ ......................................... ៥១
២.២. ដំណើរការវាយតម្លៃ ................................................................................................. ៥១
៣. ការផ្តល់រង្វាន់..............................................................................................................៥២
៤. ការអភិវឌ្ឍគន្លងអាជីពអ្នកស្រាវជ្រាវនៅ ស.ភ.ភ.ព.........................................................៥៣

៥. និរន្តរភាពនៃប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវនៅ ស.ភ.ភ.ព ..... ៥៥
៥.១. យន្តការប្រតិបត្តិ ..... ៥៥
៥.២. ធនធានមនុស្សគាំទ្រការស្រាវជ្រាវ ..... ៥៥
៥.៣. កម្មវិធីស្រាវជ្រាវរបស់និស្សិត ..... ៥៥
៥.៤. កម្មវិធីក្រោយបណ្ឌិត ..... ៥៦
៥.៥. ធនធានហិរញ្ញវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រការស្រាវជ្រាវ ..... ៥៨
៥.៥.១. គម្រោងស្រាវជ្រាវជាមួយដៃគូថ្នាក់ជាតិ ..... ៥៨
៥.៥.២. គម្រោងស្រាវជ្រាវជាមួយដៃគូអន្តរជាតិ ..... ៥៨
៥.៥.៣. សុជីវធម៌ស្រាវជ្រាវ និងក្រុមសុជីវធម៌ស្រាវជ្រាវ ..... ៥៩
៥.៦. សុជីវធម៌អ្នកស្រាវជ្រាវ និងក្រុមសីលធម៌ស្រាវជ្រាវ ..... ៥៩
ឧបសម្ព័ន្ធ ..... ៦០
ឧបសម្ព័ន្ធ១៖ គំរូកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ ..... ៦១
ឧបសម្ព័ន្ធ២៖ ទម្រង់វាយតម្លៃសមត្ថភាពស្រាវជ្រាវរបស់ស្ថាប័ន ..... ៦៤
ឧបសម្ព័ន្ធ៣៖ ទម្រង់គំរូគម្រោងស្រាវជ្រាវ ..... ៦៦
ឧបសម្ព័ន្ធ៤៖ លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃសំណើគម្រោងស្រាវជ្រាវ ..... ៨១
ឧបសម្ព័ន្ធ៥៖ ទម្រង់ពិនិត្យតាមដានគម្រោងទាំងមូលរបស់គ្រឹះស្ថាន ..... ៩៥
ឧបសម្ព័ន្ធ៦៖ របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ..... ១០២
ឧបសម្ព័ន្ធ៧៖ ក្របខណ្ឌនៃលទ្ធផល ..... ១០៥
ឧបសម្ព័ន្ធ៨៖ ទម្រង់ពិនិត្យតាមដានគម្រោងនីមួយៗ ..... ១០៧
ឧបសម្ព័ន្ធ៩៖ របាយការណ៍វឌ្ឍនភាពប្រចាំឆមាស ..... ១១០
ឧបសម្ព័ន្ធ១០៖ ទម្រង់គំរូវាយតម្លៃបញ្ចប់គម្រោង ..... ១១២
ឧបសម្ព័ន្ធ១១៖ របាយការណ៍វាយតម្លៃ ..... ១១៤
ឧបសម្ព័ន្ធ១២៖ គំរូរៀបចំប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា ..... ១១៦

# បុព្វកថា

ក្នុងនាមជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈដែលមានវ័យចំណាស់ជាងគេនិងឈានមុខគេនៅកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស.ភ.ភ.ព.) បានខិតខំលើកកម្ពស់គុណភាពនៃការបង្រៀន ការរៀន ការស្រាវជ្រាវ និងការផ្ដល់សេវាសហគមន៍។ បច្ចុប្បន្ន សាកលវិទ្យាល័យកំពុងចូលរួមសកម្មភាពនានានៅថ្នាក់ជាតិ ថ្នាក់តំបន់ និងពិភពលោក ដើម្បីឆ្ពោះទៅសម្រេចបាននូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) របស់រាជរដ្ឋាភិបាល និងការអភិវឌ្ឍប្រកបដោយចីរភាព (SDGs) របស់អង្គការសហប្រជាជាតិ។

ទន្ទឹមនឹងនេះ ស.ភ.ភ.ព. កំពុងដើរតួយ៉ាងសំខាន់ក្នុងការផ្ដល់ចំណេះដឹង សមត្ថភាព និងបំណិនការងារ ដោយផ្សារភ្ជាប់ទ្រឹស្ដីទៅនឹងការអនុវត្ត តាមរយៈសកម្មភាពស្រាវជ្រាវរបស់បុគ្គលិកអប់រំនិងនិស្សិត ស.ភ.ភ.ព. ក្នុងការចូលរួមចំណែកបង្កើតទ្រឹស្ដី ទស្សនទាន គំនិត និងគំហើញថ្មីៗ ដែលអាចឈានដល់ការបង្កើតផលិតផលថ្មី ក៏ដូចជាការដោះស្រាយបញ្ហាសង្គមនានាផងដែរ។ ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងនវានុវត្តន៍គឺជាយន្តការសមស្របបំផុតសម្រាប់ការស្វែងរកបេកគំហើញថ្មីៗ និងបង្កើតផលិតផលថ្មីៗ ដែលមានសារសំខាន់សម្រាប់សេដ្ឋកិច្ចជាតិក្នុងការឈានទៅរកយុគសម័យបដិវត្តឧស្សាហកម្ម៤.០។ ការធ្វើឱ្យ ស.ភ.ភ.ព. ក្លាយជាគ្រឹះស្ថានស្រាវជ្រាវឈានមុខក្នុងប្រទេសនឹងជួយប្រែក្លាយខឿនសេដ្ឋកិច្ចកម្ពុជា ពីការពឹងផ្អែកលើកម្លាំងពលកម្មគ្មានជំនាញ ទៅការជំរុញដោយពឹងលើជំនាញឧស្សាហកម្ម។ ចក្ខុវិស័យនេះក៏ស្របតាមគោលនយោបាយអភិវឌ្ឍឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ផងដែរ។

ស.ភ.ភ.ព. កំពុងលើកកម្ពស់ការស្រាវជ្រាវ ដើម្បីបង្កើតទ្រឹស្ដីដែលឈានទៅរកការបង្កើតផលិតផលថ្មី នវានុវត្តន៍ និងការបង្កើតភស្តុតាងដែលមានលក្ខណៈវិទ្យាសាស្ត្រ ដើម្បីរួមចំណែកធ្វើគោលនយោបាយ ផែនការ ការរៀបចំគម្រោងអភិវឌ្ឍន៍ និងការបង្កើនគុណភាពសេវាកម្ម។

សៀវភៅណែនាំស្ដីពីការគ្រប់គ្រងការស្រាវជ្រាវនៅ ស.ភ.ភ.ព. នេះត្រូវបានរៀបចំឡើងដោយមានជំនួយបច្ចេកទេសពីនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ មានការឧបត្ថម្ភថវិកាពីអគ្គនាយកដ្ឋានឧត្តមសិក្សា ផ្នែកវិភាគគោលនយោបាយ និងអភិវឌ្ឍអាជីពនៃអនុសមាសភាគ ៣.១ របស់គម្រោងកែលម្អការអប់រំឧត្តមសិក្សា (Higher Education Improvement Project-HEIP) នៃក្រសួងអប់រំ យុវជន និងកីឡា និងមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលជួយឱ្យការអនុវត្តកាន់តែមានប្រសិទ្ធភាពនិងប្រសិទ្ធផល ព្រមទាំងមាននិរន្តរភាពទៀតផង។ នៅក្នុងសៀវភៅនេះ មានគោលនយោបាយ យុទ្ធសាស្ត្រ វិធីសាស្ត្រ យន្តការ សកម្មភាព និងសូចនាករសំខាន់ៗដើម្បីជួយសម្រួលដល់ការងារស្រាវជ្រាវនៅ ស.ភ.ភ.ព.។

សៀវភៅនេះគឺជាឯកសារយុទ្ធសាស្ត្រដ៏សំខាន់ ដែលមានលក្ខណៈទូលំទូលាយ និងស៊ីជម្រៅ។ មិនតែប៉ុណ្ណោះ សៀវភៅនេះនឹងជួយផ្ដល់ភាពងាយស្រួលដល់ការលើកស្ទួយសកម្មភាពស្រាវជ្រាវនិងនវានុវត្តន៍ និងមានលក្ខណៈទន់ភ្លន់ ដែលអាចបត់បែនតាមបម្រែបម្រួលសង្គម តំបន់ និងពិភពលោកទៀតផង។

ថ្ងៃច័ន្ទ ៨រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣

**ប្រធានក្រុមប្រឹក្សាភិបាល**

**បណ្ឌិត សាន វឌ្ឍនា**

# អារម្ភកថា

ការរៀបចំសៀវភៅណែនាំស្តីពីការគ្រប់គ្រងការស្រាវជ្រាវនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស.ភ.ភ.ព.) នេះ មានគោលដៅអភិវឌ្ឍសមត្ថភាពសាកលវិទ្យាល័យភូមិន្ទភ្នំពេញឱ្យក្លាយជាគ្រឹះស្ថានឧត្តមសិក្សាមួយប្រកបដោយវិជ្ជាជីវៈផ្នែកស្រាវជ្រាវ ដែលអាចឆ្លើយតបទៅនឹងការវិវត្តនៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងអាចឆ្លើយតបតាមតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

សៀវភៅនេះក៏ជាឯកសារដែលអាចប្រើប្រាស់ក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវមួយយ៉ាងលម្អិតដែលអាចវាស់វែងបាន និងប្រទាក់ក្រឡាគ្នាពីចំណុចមួយទៅចំណុចមួយ ដោយផ្តើមចេញពីស្ថានភាពនិងសមត្ថភាពស្រាវជ្រាវរបស់គ្រឹះស្ថាន តម្រូវការកិច្ចការចម្បងៗដែលគាំទ្រដល់ការលើកកម្ពស់កម្រិតស្រាវជ្រាវរបស់គ្រឹះស្ថានពីកម្រិតមួយទៅកម្រិតមួយ ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនិងគាំទ្រការស្រាវជ្រាវ ការចាប់ផ្តើមរៀបចំផែនការវិនិយោគ ការអភិវឌ្ឍធនធានមនុស្ស ការគ្រប់គ្រងគុណភាពនៃការស្រាវជ្រាវ សមត្ថភាពរកប្រាក់ចំណូលពីការស្រាវជ្រាវ និងការរៀបចំប្រព័ន្ធលើកទឹកចិត្តសម្រាប់អ្នកស្រាវជ្រាវ ស.ភ.ភ.ព.។

ការអនុវត្តតាមសៀវភៅនេះធ្វើឡើងជាអន្តរសកម្មជាមួយយុទ្ធសាស្ត្រអនុវិស័យ ស.ភ.ភ.ព. ស្របតាមយុទ្ធសាស្ត្រគ្រឹះស្ថានឧត្តមសិក្សា។ ជាងនេះទៅទៀត សេចក្តីណែនាំប្រតិបត្តិផ្សេងៗទៀតក៏មានទិសដៅនាំមកនូវការអភិវឌ្ឍការស្រាវជ្រាវ និងនវានុវត្តន៍ ផ្សារភ្ជាប់នឹងការអភិវឌ្ឍនិងការបង្កើតប្រភពប្រាក់ចំណូលរបស់គ្រឹះស្ថាន។ ស.ភ.ភ.ព. ចាត់ទុកថា ភាពជោគជ័យក្នុងការអនុវត្តតាមគោលការណ៍ណែនាំក្នុងសៀវភៅនេះត្រូវការជាចាំបាច់នូវការប្តេជ្ញាចិត្ត ភាពជាម្ចាស់ ការចូលរួមពីថ្នាក់ដឹកនាំសាកលវិទ្យាល័យ ក្រសួង និងគ្រឹះស្ថានឧត្តមសិក្សា ការធានាបាននូវការចូលរួមអនុវត្តការងារដោយមន្ត្រីទាំងអស់ និងការដឹកនាំផ្អែកលើលទ្ធផល។

ប្រការនេះនឹងជួយដល់ ស.ភ.ភ.ព. ក្នុងការផ្តល់សេវាសាធារណៈដែលអាស្រ័យគ្នាទៅវិញទៅមករវាងការសិក្សានិងការស្រាវជ្រាវជាមួយនឹងការបង្កើនការងារ និងការអភិវឌ្ឍ។ គ្រឹះស្ថានឧត្តមសិក្សាអាចបង្កើតកិច្ចសហការក្នុងភាពជាដៃគូជាមួយវិស័យឯកជន និងកសាងក្រុមហ៊ុនតូច មធ្យម ឬធំ ដែលជារបស់ផ្ទាល់ខ្លួន និងអាចប្រើប្រាស់ជាកន្លែងសិក្សាផង ធ្វើកម្មសិក្សាផង និងស្រាវជ្រាវផង។ ក្រៅពីនេះ ស.ភ.ភ.ព. អាចសហការគ្នារៀបចំ និងធ្វើការស្រាវជ្រាវកម្រិតនវានុវត្តន៍ និងនាំបច្ចេកវិទ្យាពីសាកលលោកមកអនុវត្ត ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ។

សៀវភៅណែនាំនេះក៏ត្រូវបានរៀបចំឡើងដើម្បីឱ្យគ្រឹះស្ថានឧត្តមសិក្សានីមួយៗយល់ដឹងអំពីកិច្ចការគន្លឹះសំខាន់ៗដែលត្រូវអនុវត្តដើម្បីជំរុញសកម្មភាពស្រាវជ្រាវ និងផលិតភាពដែលទាញចេញពីគម្រោងដែលអនុវត្តដោយបុគ្គលិកអប់រំ ស.ភ.ភ.ព. ការស្រាវជ្រាវរបស់គ្រឹះស្ថានផ្ទាល់ និងការស្រាវជ្រាវជាមួយដៃគូក្រុមហ៊ុន ឬសហគ្រាសឧស្សាហកម្មផងដែរ។

តាងនាមគណៈគ្រប់គ្រង ស.ភ.ភ.ព. សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលបានកំណត់ទិសដៅជាយុទ្ធសាស្ត្រក្នុងកំណែទម្រង់ឧត្តមសិក្សាឆ្ពោះទៅរកគុណភាពនៃស្តង់ដាជាតិ តំបន់ និងអន្តរជាតិ។ ជាមួយគ្នានេះ ខ្ញុំក៏

សូមថ្លែងអំណរគុណនិងកោតសរសើរផងដែរចំពោះក្រុមការងារនិងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំចងក្រងសៀវភៅនេះនិងសម្របសម្រួលដំណើរការអនុវត្តការងារស្រាវជ្រាវនៅឧត្តមសិក្សាឱ្យកាន់តែប្រសើរឡើង។

ថ្ងៃអង្គារ ៥រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣

**សាកលវិទ្យាធិការ**

**បណ្ឌិត ជេត ជាលី**

# សេចក្តីផ្តើម

នាពេលពីរទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាត្រូវបានទទួលស្គាល់ជាអន្តរជាតិថាមានការរីកចម្រើនខ្លាំងទាំងផ្នែកសេដ្ឋកិច្ចនិងសង្គម។ ទន្ទឹមនឹងនោះ វិស័យអប់រំឧត្តមសិក្សាត្រូវបានចាត់ទុកជាកត្តាដ៏សំខាន់ក្នុងការផ្តល់វិភាគទានដល់ការអភិវឌ្ឍប្រកបដោយចីរភាពតាមរយៈការផ្តល់ចំណេះដឹងនិងជំនាញ។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស.ភ.ភ.ព.) គឺជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈធំនិងចាស់ជាងគេនៅកម្ពុជា ដែលបាននិងកំពុងផ្តល់ចំណេះដឹង ជំនាញ និងសមត្ថភាពការងារ ដោយផ្អែកលើទស្សនទាននៃការសិក្សាពេញមួយជីវិត ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។ ស.ភ.ភ.ព. ជាសមាជិកពេញសិទ្ធនៃបណ្តាញសាកលវិទ្យាល័យអាស៊ាន (AUN) និងមាននិស្សិតសរុបចំនួន ២៦,៧១១ (ស្រី ១៥,១០០) នាក់ ទាំងកម្មវិធីថ្នាក់បរិញ្ញាបត្រនិងក្រោយបរិញ្ញាបត្រ ទាំងអាហារូបករណ៍និងបង់ថ្លៃ។ គិតត្រឹមឆ្នាំ២០២២ ស.ភ.ភ.ព. ផលិតធនធានមនុស្សបានចំនួន ៦០,៥៧៧ នាក់។

ចក្ខុវិស័យរបស់ ស.ភ.ភ.ព. គឺ "ដើម្បីក្លាយជាសាកលវិទ្យាល័យឈានមុខគេនៅកម្ពុជា ប្រកបដោយកិត្តិនាមថ្នាក់តំបន់ក្នុងការរៀននិងបង្រៀន ការស្រាវជ្រាវនិងនវានុវត្តន៍ ព្រមទាំងការចូលរួមសកម្មភាពសង្គម"។ ស.ភ.ភ.ព. បានរៀបចំផែនការយុទ្ធសាស្ត្រ ឆ្នាំ២០១៤-២០១៨ និង ឆ្នាំ២០១៩-២០២៣ របស់ខ្លួនដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននេះ និងដើម្បីតម្រង់ទិសសកម្មភាពនានារបស់ខ្លួនឱ្យសម្រេចបានតាមចក្ខុវិស័យខាងលើនេះផង។ បេសកកម្មរបស់ ស.ភ.ភ.ព. ខាងផ្នែកស្រាវជ្រាវគឺបង្កើនការស្រាវជ្រាវនិងអភិវឌ្ឍលើគ្រប់កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ដើម្បីឱ្យក្លាយជាគ្រឹះស្ថានឧត្តមសិក្សាឈានមុខក្នុងការស្រាវជ្រាវ ការពិគ្រោះយោបល់ និងការផ្តល់សេវាសហគមន៍។ បច្ចុប្បន្ន ស.ភ.ភ.ព. កំពុងធ្វើដំណើរឆ្ពោះទៅរកគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ដោយរួមចំណែកនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងកម្រិតពិភពលោក។ ស.ភ.ភ.ព. ខិតខំចូលរួមលើកកម្ពស់បេតិកភណ្ឌវប្បធម៌ជាតិ និងការគ្រប់គ្រងធនធានធម្មជាតិរបស់កម្ពុជា តាមរយៈការអនុវត្តការស្រាវជ្រាវនិងការច្នៃប្រឌិតយ៉ាងសកម្មប្រកបដោយគុណភាព។

ផែនការយុទ្ធសាស្ត្របច្ចុប្បន្នរបស់ ស.ភ.ភ.ព. មានភាពស៊ីសង្វាក់គ្នាជាមួយផែនការយុទ្ធសាស្ត្រថ្នាក់ជាតិស្តីពីការអប់រំជាតិ (ESP) ២០១៩-២០២៣ ដែលគាំទ្រដល់ការប្រែក្លាយប្រទេសដែលមានប្រាក់ចំណូលពីមធ្យមកម្រិតទាបទៅមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទទួលបានឋានៈជាប្រទេសជឿនលឿននៅឆ្នាំ២០៥០។ សាកលវិទ្យាល័យបានកំណត់យកជាអាទិភាពនូវការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវដើម្បីបោះពុម្ពផ្សាយដែលមានការត្រួតពិនិត្យពីក្រុមអ្នកវិទ្យាសាស្ត្រ និងការផ្សារភ្ជាប់ទៅនឹងបណ្តាញឧស្សាហកម្មនិងសហគមន៍ ដើម្បីបង្កើតផលិតផលថ្មី ផលិតផលគំរូ និងការដាក់ស្នើនិងលក់ប៉ាតង់។ នាពេលបច្ចុប្បន្ននេះ ស.ភ.ភ.ព. កំពុងផ្តោតលើការស្រាវជ្រាវផ្នែកទ្រឹស្តីនិងអនុវត្តន៍ ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច ដោយផ្សារភ្ជាប់នឹងឧស្សាហកម្ម បង្កើនចំណេះដឹង និងនវានុវត្តន៍។ ស.ភ.ភ.ព. បានខិតខំប្រឹងប្រែងអនុវត្តឱ្យបានល្អបំផុតក្នុងវិស័យស្រាវជ្រាវនិងសេវាសង្គម ដើម្បីឱ្យមានការទទួលស្គាល់ពីសំណាក់អង្គការជាតិនិងអន្តរជាតិថាជាគ្រឹះស្ថានឈានមុខគេក្នុងវិស័យស្រាវជ្រាវនេះ។

ដើម្បីនិរន្តរភាពកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គម រាជរដ្ឋាភិបាលកម្ពុជាកំពុងជំរុញការអប់រំលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)។ ទន្ទឹមនឹងនេះ មុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងសិក្សាអភិវឌ្ឍន៍ក៏មានសារសំខាន់ក្នុងការរួមចំណែកសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ ការបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រត្រូវបានចាត់ទុកជាចំណុចសំខាន់បំផុតក្នុងការលើកកម្ពស់គោលនយោបាយឧស្សាហកម្ម ៤.០ របស់កម្ពុជា។ គោលនយោបាយនេះមានបំណងបង្កើតការច្នៃប្រឌិត និងនវានុវត្តន៍ ដែលជាតម្រូវការចាំបាច់សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គម។ ដើម្បីជុំរុញការបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវឱ្យបានផុលផុស ស.ភ.ភ.ព. ក៏បានបង្កើតទស្សនាវដ្ដីស្រាវជ្រាវដែលមានការត្រួតពិនិត្យត្រឹមត្រូវពីអ្នកវិទ្យាសាស្ត្រ។ ទស្សនាវដ្ដីទាំងនោះគឺ៖ Cambodian Journal of Natural History, Insight: Cambodian Journal of Basic and Applied Research, Cambodian Review of Language Learning and Teaching, និង Cambodian Communication Review of EFL Research។

ប៉ុន្តែទោះជាយ៉ាងនេះក្ដី ក្នុងនាមជាគ្រឹះស្ថានស្រាវជ្រាវឈានមុខគេ ប្រសិនបើ ស.ភ.ភ.ព. ចង់បានចំណាត់ថ្នាក់សាកលវិទ្យាល័យកម្រិតពិភពលោកនោះ ការវិនិយោគទ្រង់ទ្រាយធំលើសមត្ថភាពស្រាវជ្រាវរបស់គ្រឹះស្ថានគឺជាតម្រូវការចាំបាច់។ ប្រសិនបើបំណងនេះបានសម្រេចមែន វានឹងបង្ហាញយ៉ាងច្បាស់ថាប្រទេសកម្ពុជាមានសមត្ថភាពកាន់តែប្រសើរក្នុងការបង្កើតចំណេះដឹងក្នុងស្រុក និងនវានុវត្តន៍ក្នុងប្រទេស និងក្នុងការដោះស្រាយដោយឯករាជ្យនូវបញ្ហាប្រឈមនានាក្នុងដំណើរការធ្វើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមមានលទ្ធផលកាន់តែល្អប្រសើរ។ បច្ចុប្បន្ន ការអនុវត្តគម្រោងស្រាវជ្រាវនិងបោះពុម្ពស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្ររបស់បុគ្គលិកស្រាវជ្រាវនៅស.ភ.ភ.ព. ត្រូវបានធ្វើឡើងជាលក្ខណៈបុគ្គល ដោយសារមានចំណង់ចំណូលចិត្ត ដោយសារទទួលបានអត្ថប្រយោជន៍ផ្ទាល់ខ្លួន និងដោយសារមានសមត្ថភាពក្នុងការស្វែងរកធនធានពីខាងក្រៅសម្រាប់ការស្រាវជ្រាវ។ ទាំងនៅថ្នាក់គ្រឹះស្ថាននិងទាំងនៅថ្នាក់ជាតិ យន្តការដែលមានស្រាប់សម្រាប់ជំរុញការអភិវឌ្ឍវប្បធម៌ស្រាវជ្រាវមានតិចតួចប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្ដី ស.ភ.ភ.ព. ត្រូវបានស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជាធនាគារពិភពលោកជាដើម ជ្រើសរើសយកធ្វើជាគ្រឹះស្ថានឧត្តមសិក្សាគំរូដែលអនុវត្តការស្រាវជ្រាវបានល្អបំផុតនៅកម្ពុជា។ កិត្តិយសនេះគឺជាលទ្ធផលនៃការខិតខំយ៉ាងខ្លាំងរបស់សាស្ត្រាចារ្យ ស.ភ.ភ.ព. ក្នុងការលើកកម្ពស់ការបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវ។

# ជំពូកទី១
# ក្របខណ្ឌគោលនយោបាយនៃការគ្រប់គ្រងការស្រាវជ្រាវ

## ១. ចក្ខុវិស័យ

ត្រឹមឆ្នាំ២០៣០ ស.ភ.ភ.ព. នឹងក្លាយជាគ្រឹះស្ថានឈានមុខក្នុងប្រទេសកម្ពុជានិងតំបន់ក្នុងការស្រាវជ្រាវទាំងផ្នែកទ្រឹស្តី (academic research) និងទាំងផ្នែកអនុវត្តន៍ (applied research) លើវិស័យស្ទែម (STEM) វិទ្យាសាស្ត្រសង្គម និងសិក្សាអភិវឌ្ឍន៍។

## ២. បេសកកម្ម

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើនេះ ស.ភ.ភ.ព. មានបេសកកម្មធំៗបីដូចខាងក្រោម៖

- វិនិយោគរយៈពេលវែងលើការកសាងចំណេះដឹង ជំនាញ និងសមត្ថភាពស្រាវជ្រាវឱ្យកាន់តែប្រសើរជូនបុគ្គលិកអប់រំ ស.ភ.ភ.ព. តាមរយៈការបញ្ជូនទៅចូលរួមវគ្គបណ្តុះបណ្តាល និងចូលរួមក្នុងសកម្មភាពស្រាវជ្រាវទាំងថ្នាក់ជាតិ/អន្តរជាតិ ការណែនាំ និងការផ្តល់ប្រឹក្សាយោបល់។
- បង្កើតភាពជាដៃគូសហការស្រាវជ្រាវ ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ដើម្បីជួយគាំទ្រដល់បុគ្គលិកស្រាវជ្រាវ ស.ភ.ភ.ព. តាមរយៈហិរញ្ញប្បទានស្រាវជ្រាវ ការស្រាវជ្រាវរួមគ្នា និងកម្មវិធីផ្លាស់ប្តូរនានា។
- បង្កើតយន្តការអនុវត្តគោលនយោបាយផ្តល់ហិរញ្ញប្បទាន ស.ភ.ភ.ព. សម្រាប់ការស្រាវជ្រាវ និងផ្តល់គ្រឿងលើកទឹកចិត្ត ប្រាក់រង្វាន់ ឬតួនាទី ដល់បុគ្គលិកស្រាវជ្រាវដែលបានបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវ ឬផលិតប៉ាតង់ដែលមានអាជ្ញាប័ណ្ណ។

## ៣. គោលបំណងនៃប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវ

បង្កើតប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដើម្បីគាំទ្រនិងសម្របសម្រួលសកម្មភាពស្រាវជ្រាវ និងការកៀរគរមូលនិធិគម្រោងស្រាវជ្រាវ និងនវានុវត្តន៍ទាំងផ្នែកទ្រឹស្តី និងផ្នែកអនុវត្តដោយផ្តោតលើវិស័យស្ទែម (STEM) វិទ្យាសាស្ត្រសង្គម និងគោលដៅអភិវឌ្ឍដោយចីរភាព។ ប្រព័ន្ធតាមដាននិងវាយតម្លៃមានសារសំខាន់ក្នុងការសម្របសម្រួលការអនុវត្តគម្រោងស្រាវជ្រាវឱ្យមានប្រសិទ្ធិភាព ប្រសិទ្ធិផល គណនេយ្យភាព និងតម្លាភាព ដែលជាសូចនាករស្នូលនៃអភិបាលកិច្ចល្អ។ ត្រឹមឆ្នាំ២០៣០ ស.ភ.ភ.ព. អាចសម្រេចបានដូចខាងក្រោម៖

- យ៉ាងហោចណាស់ ៥០% នៃបុគ្គលិកអប់រំ ស.ភ.ភ.ព. នឹងមានសមត្ថភាពអាចកៀរគរមូលនិធិស្រាវជ្រាវ និងធ្វើការស្រាវជ្រាវទាំងផ្នែកទ្រឹស្តី និងទាំងផ្នែកអនុវត្តន៍។
- ក្នុងចន្លោះ ឆ្នាំ២០២៣ និង ២០៣០ ចំនួនគម្រោងស្រាវជ្រាវ ចំនួនថវិកាស្រាវជ្រាវ ការបោះពុម្ពស្នាដៃស្រាវជ្រាវ និងការចុះបញ្ជីកម្មសិទ្ធិបញ្ញានៃផលិតផល ដែលបានមកពីការស្រាវស្រាវអាចនឹងមានការកើនឡើង យ៉ាងហោចណាស់ ១០% ក្នុងមួយឆ្នាំ។

## ៤. យុទ្ធសាស្ត្រ

ស.ភ.ភ.ព. មានយុទ្ធសាស្ត្រស្រាវជ្រាវយូរអង្វែង ហើយចែកចេញជាបីជំហ៊ានដូចខាងក្រោម៖

- **ជំហានទី១** : បណ្តុះវប្បធម៌ស្រាវជ្រាវ និង កៀរគរធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស។
- **ជំហានទី២** : ធ្វើឱ្យការស្រាវជ្រាវមានភាពរលូននិងជឿនលឿន។
- **ជំហានទី៣** : ធ្វើឱ្យការស្រាវជ្រាវតាមវិស័យនានាមានភាពស្រួចស្រាល់និងស៊ីជម្រៅ

1. ពីឆ្នាំ២០២០ ដល់ ២០២៤ ស.ភ.ភ.ព. ចង់សម្រេចបានជំហានទី១ "បណ្តុះវប្បធម៌ស្រាវជ្រាវ និងកៀរគរធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស" ។
2. ពីឆ្នាំ២០២៥ ដល់ ២០៣០ ស.ភ.ភ.ព ចង់សម្រេចបានជំហានទី២ "ធ្វើឱ្យការស្រាវជ្រាវមានភាពរលូននិងជឿនលឿន"
3. ពីឆ្នាំ២០៣១ដល់២០៣៥ ចង់សម្រេចបានជំហានទី៣ "ធ្វើឱ្យការស្រាវជ្រាវតាមវិស័យនានាមានភាពស្រួចស្រាល់និងស៊ីជម្រៅ"

ដេប៉ាតឺម៉ងនីមួយៗនឹងកំណត់វិស័យស្រាវជ្រាវជាអាទិភាព សំដៅពង្រីកចំណេះដឹងដែលជួយគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមក្នុងផែនការសកម្មភាព។ វិស័យស្រាវជ្រាវជាអាទិភាពទាំងនោះត្រូវឆ្លើយតបទៅនឹងបញ្ហាធំៗរបស់ជាតិ។ ភ្ជាប់លទ្ធផលស្រាវជ្រាវទៅនឹងការអនុវត្តជាក់ស្តែង ដោយបញ្ចូលទ្រឹស្តីនិងទស្សនទានទាំងនេះទៅក្នុងគោលនយោបាយនិងកម្មវិធីសិក្សា។

**តារាងទី១. សង្ខេបសមិទ្ធផលស្រាវជ្រាវដែលរំពឹងទុក**

| យុទ្ធសាស្ត្រ៥ឆ្នាំ | ចំនួន |
|---|---|
| លើកកម្ពស់ការងារស្រាវជ្រាវតាមរយៈដំណើរការគណៈកម្មការ/អនុគណៈកម្មការ | ៣ |
| • អនុគណៈកម្មការក្រមសីលធម៌ស្រាវជ្រាវ | ១ |
| • អនុគណៈកម្មការប្រឹក្សាយោបល់ | ១ |
| • អនុគណៈកម្មការគ្រប់គ្រងការបោះពុម្ពឯកសារសិក្សានិងស្រាវជ្រាវ | ១ |
| អភិវឌ្ឍសមត្ថភាពនិងនិរន្តភាពហិរញ្ញប្បទានស្រាវជ្រាវ | ៥លានដុល្លា/ឆ្នាំ |
| លើកទឹកចិត្តស្រាវជ្រាវតាមវិធីច្នៃប្រឌិត | ២០រង្វាន់/ឆ្នាំ |
| បោះពុម្ពផ្សាយនិងការផ្សព្វផ្សាយស្នាដៃស្រាវជ្រាវតាមរយៈដំណើការទស្សនាវដ្តីវិទ្យាសាស្ត្រ | ៤ លេខ/ឆ្នាំ |
| បោះពុម្ពផ្សាយនិងការផ្សព្វផ្សាយស្នាដៃស្រាវជ្រាវក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ | ១ អត្ថបទ/១ គម្រោង |
| ករបង្កើតផលិតផលថ្មី (ផលិតផលគំរូ) | ១ផលិតផលគំរូ/៥ គម្រោង |

| | |
|---|---|
| ករបង្កើតផលិតផលថ្មី (ប៉ាតង់) | ១ប៉ាតង់/១០ គម្រោង |
| ចំណូលដែលទទួលបានពីការស្រាវជ្រាវ (ផលិតផលគំរូ ឬប៉ាតង់) | ១ ក្នុង១០គម្រោង |
| បង្កើនការគាំទ្រដល់ការស្រាវជ្រាវផ្នែកនិងផ្នែកអនុវត្ត | ១២ វគ្គ/ឆ្នាំ |

## ៥. វដ្តនៃដំណើរការគ្រប់គ្រងការស្រាវជ្រាវ

រូបភាពទី១បង្ហាញពីវដ្តនៃដំណើការគ្រប់គ្រងការស្រាវជ្រាវដែលមាន ៦ ដំណាក់កាលគឺៈ (១) កំណត់អាទិភាពលើវិស័យឬប្រធានបទស្រាវជ្រាវ, (២) ប្រមូលធនធានសម្រាប់សកម្មភាពស្រាវជ្រាវ, (៣) អនុវត្តគម្រោងស្រាវជ្រាវ និងនវានុវត្តន៍, (៤) បោះពុម្ពផ្សាយ និងស្នើផលិតផលគំរូ ឬសុំប៉ាតង់, (៥) ផ្សព្វផ្សាយ និងលក់ផលិតផលគំរូឬសុំប៉ាតង់, និង(៦) វាយតម្លៃលទ្ធផលនៃសកម្មភាពស្រាវជ្រាវ។

**រូបភាពទី១. វដ្តនៃដំណើការគ្រប់គ្រងការស្រាវជ្រាវនៅស.ភ.ភ.ព.**




ដេប៉ាតឺម៉ង់នីមួយៗត្រូវកំណត់អាទិភាពលើវិស័យឬប្រធានបទស្រាវជ្រាវជារៀងរាល់ឆ្នាំ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងប្រទេស និងតាមការផ្លាស់ប្តូរចំណេះដឹង ជំនាញ និងវិទ្យាសាស្ត្រក្នុងតំបន់ និងអន្តរជាតិ។ ការកំណត់អាទិភាពលើវិស័យ ឬប្រធានបទស្រាវជ្រាវមានសារសំខាន់សម្រាប់ការប្រមូលធនធានសម្រាប់សកម្មភាពស្រាវជ្រាវពី ស.ភ.ភ.ព. ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍនានា។

នៅពេលអនុវត្តគម្រោងស្រាវជ្រាវ ស.ភ.ភ.ព. មានប្រព័ន្ធតាមដាន និងវាយតម្លៃក្នុងការប្រមូលទិន្នន័យដែលឆ្លើយតបទៅនឹងសូចនាករប្រតិបត្តិការសំខាន់ៗ (KPI) ដែលបានគ្រោងទុក។ លទ្ធផលស្រាវជ្រាវនឹងត្រូវបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ និងស្នើផលិតផលគំរូឬសុំប៉ាតង់។ លទ្ធផលស្រាវជ្រាវនិងការបង្កើតផលិតផលថ្មីនឹងត្រូវប្រើប្រាស់សម្រាប់ការបង្កើតប្រាក់ចំណូលតាមរយៈការលក់សេវា ការលក់ផលិតផលស្រាវជ្រាវ និងការលក់ផលិតផលគំរូឬសុំប៉ាតង់។ សមិទ្ធិផលត្រូវបានវាយតម្លៃជារៀងរាល់ឆ្នាំតាមរយៈប្រព័ន្ធតាមដាននិងវាយតម្លៃ ស.ភ.ភ.ព.។

## ៦. ការកំណត់អាទិភាព និងប្រភេទនៃការស្រាវជ្រាវ

### ៦.១. វិស័យអាទិភាព

ការស្រាវជ្រាវ ស.ភ.ភ.ព ផ្តោតសំខាន់ទៅលើវិស័យស្ទែម (STEM) វិទ្យាសាស្ត្រសង្គម និងសិក្សាអភិវឌ្ឍន៍។ ការស្រាវជ្រាវត្រូវផ្តល់អាទិភាពទៅលើ៖ (១) គម្រោងស្រាវជ្រាវគំនិតមួយផលិតផលមួយ ផលិតផលគំរូ និងការស្រាវជ្រាវដែលប្រើប្រាស់ដោយឧស្សាហកម្ម, (២) អភិវឌ្ឍនវានុវត្តន៍សង្គម (Social innovation), (៣) គន្លងប្រក្រតីយភាពថ្មី (New Normal), (៤) យេនឌ័រនិងបរិយាបន្នសង្គម ការគាំពារសង្គម, (៥) នគរូបនីយកម្ម និងអភិវឌ្ឍន៍ក្រុង, (៦) សិប្បកម្មខ្នាតតូចនិងខ្នាតមធ្យមរបស់កម្ពុជាដែលគាំទ្រកំណើនសេដ្ឋកិច្ច, និង (៧) គោលដៅអភិវឌ្ឍដោយចីរភាព។

**រូបភាពទី២. គោលដៅយុទ្ធសាស្ត្រ១០ឆ្នាំរបស់ ស.ភ.ភ.ព**




រាល់លទ្ធផលស្រាវជ្រាវនឹងត្រូវបានប្រើប្រាស់ក្នុងសកម្មភាពបង្កើនសេដ្ឋកិច្ចតាមរយៈការបង្កើតផលិតផលថ្មី ការលក់ប៉ាតង់ និងសកម្មភាពបង្កើតប្រាក់ចំណូល។ បុគ្គលិកអប់រំ ស.ភ.ភ.ព ក៏នឹងប្រើប្រាស់លទ្ធផលស្រាវជ្រាវដើម្បីបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រកម្រិតជាតិ កម្រិតតំបន់ និងកម្រិតអន្តរជាតិដែលមានការត្រួតពិនិត្យត្រឹមត្រូវពីអ្នកវិទ្យាសាស្ត្រ។ ការបោះពុម្ពទស្សនាវដ្តីវិទ្យាសាស្ត្របែបនេះមានសារសំខាន់ក្នុងការលើកកម្ពស់ការបង្រៀននិងរៀន និងការទទួលបានចំណាត់ថ្នាក់សាកល

វិទ្យាល័យកម្រិតជាតិ កម្រិតតំបន់ និងកម្រិតអន្តរជាតិ។ ជារួម គោលដៅយុទ្ធសាស្ត្រ១០ឆ្នាំ របស់ស.ភ.ភ.ព គឺការអភិវឌ្ឍកម្មវិធីសិក្សា ការស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីសម្រេចបានគោលបំណង សកម្មភាពយុទ្ធសាស្ត្រ និងអនុវត្តសកម្មភាពយុទ្ធសាស្ត្រ។ លទ្ធផលស្រាវជ្រាវក៏មានសារសំខាន់សម្រាប់ជួយដល់ការកែលម្អនិងអភិវឌ្ឍកម្មវិធីសិក្សា ការបង្រៀន និងការរៀន និងការបង្កើតប្រាក់ចំណូល។

### ៦.២. ប្រភេទនៃការស្រាវជ្រាវ

ដើម្បីសម្រេចបេសកកម្មយុទ្ធសាស្ត្រ១០ឆ្នាំ ក្នុងការ (១) ផ្តល់ដល់បុគ្គលិកអប់រំ ស.ភ.ភ.ព និងនិស្សិតនូវចំណេះដឹង បំណិន គុណតម្លៃ និងឥរិយាបថចាំបាច់នានា ដែលជាតម្រូវការសង្គមដែលផ្អែកលើព័ត៌មាននិងពុទ្ធិ (២) ផ្តល់នូវការស្រាវជ្រាវ និងនវានុវត្តន៍ប្រកបដោយគុណភាពខ្ពស់ និង (៣) ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពឧស្សាហកម្ម និងសង្គម។ ស.ភ.ភ.ព អនុវត្តការស្រាវជ្រាវបីប្រភេទធំៗគឺៈ

**តារាងទី២. ប្រភេទនៃការស្រាវជ្រាវ**

| ប្រភេទ | ពិពណ៌នា |
|---|---|
| ការស្រាវជ្រាវបែបទ្រឹស្តី (academic research) | • ការស្រាវជ្រាវដើម្បីបង្កើតគំនិតថ្មី ទស្សនាទានថ្មី ឬទ្រឹស្តីថ្មីក្នុងជំនាញ វិទ្យាសាស្ត្រណានូ គីមី ជីវវិទ្យា រូបវិទ្យា និងគណិតវិទ្យា។ល។<br>• លទ្ធផលស្រាវជ្រាវអាចឈានទៅរកការបង្កើតថ្មី ដើម្បីពង្រីកចំណេះដឹង និងនវានុវត្តន៍។<br>• លទ្ធផលស្រាវជ្រាវអាចបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រដែលជួយដល់ចំណាត់ថ្នាក់គ្រឹះស្ថានឧត្តមសិក្សា (University ranking) ក្រុមហ៊ុនឯកជន និងឧស្សាហកម្មក្នុងការប្រើប្រាស់សម្រាប់បង្កើតផលិតផលថ្មី។ |
| ការស្រាវជ្រាវឆ្លើយតបទៅនឹងគោលនយោបាយថ្នាក់ជាតិ | • ការស្រាវជ្រាវសម្រាប់ប្រមូលទិន្នន័យ និង ភ័ស្តុតាងបែបវិទ្យាសាស្ត្រ។<br>• ប្រើប្រាស់លទ្ធផលស្រាវជ្រាវសម្រាប់ជួយគាំទ្រសកម្មភាព រៀបចំគម្រោង អនុវត្តគម្រោង ការធ្វើផែនការ និងគោលនយោបាយ។<br>• អ្នកអនុវត្តសកម្មភាព អ្នកធ្វើផែនការ និងអ្នកធ្វើគោលនយោបាយអាចប្រើប្រាស់ដើម្បីបង្កើតការសន្ទនាសម្រាប់ការអភិវឌ្ឍ |

| | |
|---|---|
| | • ការស្រាវជ្រាវត្រូវឆ្លើយតបនឹងផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ |
| ការស្រាវជ្រាវប្រតិបត្តិ (Applied research) | • ការស្រាវជ្រាវដើម្បីបង្កើតផលិតផលនិងបច្ចេកវិទ្យាថ្មីក្នុងវិស័យកសិកម្ម អាហារ គ្រឿងសម្អាង សុខាភិបាល និងថាមពល សម្រាប់ទីផ្សារ និងបម្រើដល់ការអភិវឌ្ឍឧស្សាហ៍កម្ម និងដោះស្រាយបញ្ហាសង្គមតាមតម្រូវការ។<br>• ការស្រាវជ្រាវដែលអាចបង្កើតប្រាក់ចំណូលដល់ ស.ភ.ភ.ព តាមរយៈការផលិតផលិតផលដែលបានស្រាវជ្រាវ ការលក់ប៉ាតង់ (អាជ្ញាប័ណ្ណ)។ |

# ជំពូកទី២
# ក្របខណ្ឌអនុវត្តការគ្រប់គ្រងការស្រាវជ្រាវ

យុទ្ធសាស្ត្រ១០ឆ្នាំរបស់ ស.ភ.ភ.ព. មានគោលបំណង៖ (១) កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបង្កើតវប្បធម៌ស្រាវជ្រាវ ដើម្បីគាំទ្រដល់សកម្មភាពការសិក្សាស្រាវជ្រាវ, (២) បង្កើនសមត្ថភាពស្រាវជ្រាវនៅក្នុង ស.ភ.ភ.ព., និង (៣) បង្កើតយន្តការរៀបចំប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវឱ្យរឹងមាំ។ ការគ្រប់គ្រងការស្រាវជ្រាវផ្ដោតសំខាន់លើ៖ (ក) ការគាំទ្រផ្នែករដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស និងប្រកួតប្រជែងការស្រាវជ្រាវទាំងក្នុងនិងក្រៅស្ថាប័ន, (ខ) បង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រស្រាវជ្រាវ រួមទាំងកញ្ចប់ថវិការបស់សាកលវិទ្យាល័យសម្រាប់ជំរុញការស្រាវជ្រាវ យុទ្ធសាស្ត្រផ្សព្វផ្សាយការស្រាវជ្រាវ និងនវានុវត្តន៍, និង (គ) គ្រប់គ្រងមជ្ឈមណ្ឌលស្រាវជ្រាវនិងប្រើប្រាស់ធនធានដែលមានប្រកបដោយប្រសិទ្ធភាព។

**រូបភាពទី៣. ការពង្រឹងសមត្ថភាពស្រាវជ្រាវនៅ ស.ភ.ភ.ព.**




## ១. រចនាសម្ព័ន្ធគ្រប់គ្រងការស្រាវជ្រាវ

ដើម្បីគ្រប់គ្រងការងារស្រាវជ្រាវនិងសម្រេចយុទ្ធសាស្ត្រ១០ឆ្នាំ ស.ភ.ភ.ព. នឹងបង្កើតមជ្ឈមណ្ឌលគាំទ្រការស្រាវជ្រាវ និងនវានុវត្តន៍ ដែលក្នុងនោះ មានការិយាល័យចំនួនបីគឺ៖

១. ការិយាល័យតាមដាន និងវាយតម្លៃគម្រោងស្រាវជ្រាវ

២. ការិយាល័យកម្មសិទ្ធិបញ្ញា និងនវានុវត្តន៍ និង

៣. ការិយាល័យបោះពុម្ពផ្សាយ និងគាំទ្រទស្សនាវដ្តីវិទ្យាសាស្ត្រ។

មជ្ឈមណ្ឌលគាំទ្រការស្រាវជ្រាវនិងនវានុវត្តន៍មានតួនាទីនិងភារកិច្ចយ៉ាងសំខាន់ក្នុងការជួយគាំទ្រប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវដូចខាងក្រោម៖

- ចូលរួមធ្វើផែនការយុទ្ធសាស្ត្រ គោលនយោបាយ និងបទដ្ឋានប្រតិបត្តិនៃនីតិវិធីគោលនយោបាយស្រាវជ្រាវ (SOP) និងបទដ្ឋានស្រាវជ្រាវ ការគ្រប់គ្រងមន្ទីរពិសោធន៍ និងនវានុវត្តន៍
- រៀបចំ និងលើកគម្រោងផែនការសម្រាប់ប្រតិបត្តិ និងកំណត់អាទិភាពការងារស្រាវជ្រាវ ការគ្រប់គ្រងមន្ទីរពិសោធន៍ និងនវានុវត្តន៍
- កសាងបណ្តាញការងារជាមួយស្ថាប័នស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍ ដើម្បីកៀរគរមូលនិធិ និងបច្ចេកទេសស្រាវជ្រាវ ការអភិវឌ្ឍមន្ទីរពិសោធន៍ន៍ និងរៀបចំការបោះពុម្ពផ្សាយ
- ជួយគាំទ្រការស្រាវជ្រាវ មន្ទីរពិសោធន៍ ដំណើរការដាក់ស្នើសុំក្រុមសីលធម៌ស្រាវជ្រាវ និងការបោះពុម្ពផ្សាយរបស់សាស្ត្រាចារ្យ ស.ភ.ភ.ព. និងសាស្ត្រាចារ្យបរទេស
- បើកវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រស្រាវជ្រាវ ការវិភាគទិន្នន័យ ការសរសេរបាយការណ៍ស្រាវជ្រាវ ការគ្រប់គ្រងមន្ទីរពិសោធន៍ និងការបោះពុម្ពផ្សាយ
- គ្រប់គ្រងកម្មសិទ្ធិបញ្ញា មន្ទីរពិសោធន៍ និងការបោះពុម្ពផ្សាយរបស់សាស្ត្រាចារ្យ ស.ភ.ភ.ព ដែលសហការស្រាវជ្រាវជាមួយសាស្ត្រាចារ្យបរទេស
- តាមដាននិងវាយតម្លៃការងារស្រាវជ្រាវ ផលិតផលគំរូ/ផលិតផលស្រាវជ្រាវ កម្មសិទ្ធិបញ្ញា និងការបោះពុម្ពផ្សាយរបស់សាស្ត្រាចារ្យ ស.ភ.ភ.ព. ដែលសហការស្រាវជ្រាវជាមួយសាស្ត្រាចារ្យបរទេស
- រៀបចំរបាយការណ៍សកម្មភាព និងលទ្ធផលការងារតាមកាលកំណត់ជូនគណៈគ្រប់គ្រងនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀត ដែលសាកលវិទ្យាល័យប្រគល់ជូន។

គណៈកម្មការគ្រប់គ្រងការងារស្រាវជ្រាវដែលមានស្រាប់នឹងផ្តល់អនុសាសន៍និងជំនួយបច្ចេកទេសដល់មជ្ឈមណ្ឌលគាំទ្រការស្រាវជ្រាវ និងនវានុវត្តន៍។ ជាងនេះទៅទៀត ដើម្បីពិភាក្សា ពិគ្រោះយោបល់ និងស្វែងរកដំណោះស្រាយបញ្ហាផ្សេងៗទាក់ទងនឹងការស្រាវជ្រាវនិងការគ្រប់គ្រងមន្ទីរពិសោធន៍ គណៈកម្មការគ្រប់គ្រងការងារស្រាវជ្រាវនឹងបង្កើតអនុគណៈកម្មការចំនួនបីគឺ៖

១. **អនុគណៈកម្មការក្រុមសីលធម៌ស្រាវជ្រាវ** សម្រាប់ពិនិត្យសំណើស្រាវជ្រាវ និងពិសោធន៍នានា និងធានាសេចក្តីថ្លៃថ្នូរ សិទ្ធិ សុវត្ថិភាព និងសុខុមាលភាពរបស់អ្នកចូលរួមស្រាវជ្រាវអំពីមនុស្សនិងសត្វ

២. **អនុគណៈកម្មការប្រឹក្សាយោបល់** សម្រាប់ត្រួតពិនិត្យនិងផ្តល់ជំនួយបច្ចេកទេសដល់បុគ្គលិកអប់រំក្នុងការអភិវឌ្ឍ និងអនុវត្តគម្រោងស្រាវជ្រាវ និង

៣. **អនុគណៈកម្មការគ្រប់គ្រងការបោះពុម្ពឯកសារសិក្សានិងស្រាវជ្រាវ** ដើម្បីលើកស្ទួយការបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ ដែលមានការត្រួតពិនិត្យត្រឹមត្រូវពីក្រុមអ្នកវិទ្យាសាស្ត្រ និងផ្តល់សេវាសន្ទស្សន៍និងសង្ខិត្តន័យ។

**រូបភាពទី៤.** រចនាសម្ព័ន្ធគ្រប់គ្រងការស្រាវជ្រាវ ស.ភ.ភ.ព.




## ២. តួនាទីនិងភារកិច្ចរបស់ការិយាល័យទាំងបី

### ២.១. ការិយាល័យតាមដាននិងវាយតម្លៃគម្រោងស្រាវជ្រាវ

- បណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពអ្នកស្រាវជ្រាវតាមមហាវិទ្យាល័យ/វិទ្យាស្ថាន
- ជាកន្លែងចែកចាយប្រភពព័ត៌មានហិរញ្ញវត្ថុ
- គាំទ្រដំណើរការត្រួតពិនិត្យគុណភាពនៃទិន្នន័យគម្រោងស្រាវជ្រាវ
- គ្រប់គ្រង និងវាយតម្លៃការអភិវឌ្ឍគម្រោងស្រាវជ្រាវនីមួយៗនៅ ស.ភ.ភ.ព
- គ្រប់គ្រងច្រកចេញ-ចូលតែមួយ (One Window Service) សម្រាប់ការអនុវត្តគម្រោងស្រាវជ្រាវដោយផ្តល់សេវារដ្ឋបាលដូចជា ធ្វើឯកសាររដ្ឋបាលនិងហិរញ្ញវត្ថុ សម្របសម្រួលនីតិវិធីរដ្ឋបាល និងទទួលថ្លៃសេវារដ្ឋបាលទាំងនេះ (administrative fee)
- រៀបចំរបាយការណ៍ និងថែរក្សាទិន្នន័យនិងព័ត៌មានទាក់ទងនឹងគម្រោងស្រាវជ្រាវ ការងារមន្ទីរពិសោធន៍ ការបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ ការរក្សាកម្មសិទ្ធិបញ្ញាដែលសម្រេចបាននៅ ស.ភ.ភ.ព.
- រៀបចំរបាយការណ៍វាយតម្លៃគម្រោងស្រាវជ្រាវតាមដំណាក់កាលឱ្យបានទៀងទាត់ និងធ្វើការសម្រេចចិត្តលើវឌ្ឍនភាពនៃដំណើរការគម្រោងស្រាវជ្រាវ

- វាយតម្លៃសកម្មភាពគម្រោងដើម្បីកែលម្អ
- ផ្សព្វផ្សាយគម្រោងអភិវឌ្ឍ និងការស្នើសុំគម្រោងអត្ថបទស្រាវជ្រាវពីមហាវិទ្យាល័យនីមួយៗ
- រៀបចំកម្មវិធីសិក្ខាសាលាដើម្បីពិនិត្យតាមដានគម្រោងឱ្យមានប្រសិទ្ធភាព
- វាយតម្លៃកិច្ចការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឧត្តមភាពសម្រាប់សាកលវិទ្យាល័យ និងដាក់ចេញនូវសកម្មភាពដើម្បីពង្រឹងនិងបំពេញចំណុចខ្វះខាតនានា
- ពិនិត្យតាមដាន ប្រមូលនិងវិភាគទិន្នន័យ និងប្រមូលព័ត៌មានពីបណ្តាប្រភពផ្សេងៗដើម្បីពង្រឹងប្រសិទ្ធភាពនៃគម្រោងស្រាវជ្រាវ
- ធ្វើរបាយការណ៍ស្រាវជ្រាវជាប្រចាំសម្រាប់ដាក់ជូនគណៈគ្រប់គ្រងសាកលវិទ្យាល័យ និង
- ផ្តល់ទិន្នន័យនិងព័ត៌មានទាក់ទងការងារស្រាវជ្រាវ ការងារមន្ទីរពិសោធន៍ និងនវានុវត្តន៍នៅ ស.ភ.ភ.ព. ទៅក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធ។

## ២.២. ការិយាល័យកម្មសិទ្ធិបញ្ញា និងនវានុវត្តន៍

- រៀបចំគម្រោងផែនការស្រាវជ្រាវឱ្យសមស្របតាមចក្ខុវិស័យ គោលបំណង គោលដៅ និងកម្មវិធីរបស់សាកលវិទ្យាល័យ។
- បង្កើតនិងដំណើរការក្រុមប្រឹក្សាត្រួតពិនិត្យក្រមសីលធម៌ស្រាវជ្រាវផ្ទៃក្នុង ឬ Internal Review Board ( IRB )។
- រៀបចំផែនការគម្រោងស្រាវជ្រាវ ការងារមន្ទីរពិសោធន៍ន៍ និងចូលរួមអនុវត្តគម្រោងស្រាវជ្រាវឱ្យមានប្រសិទ្ធភាព។
- បង្កើតគំរូលិខិតសម្រាប់ដាក់ពាក្យផ្ទេរកម្មសិទ្ធិបញ្ញា ដែលពាក់ព័ន្ធនឹងស្នាដៃបោះពុម្ពសម្រាប់មជ្ឈមណ្ឌលឧត្តមភាព។
- ផ្តល់ជំនួយបច្ចេកទេស និងច្បាប់សម្រាប់ការរក្សាកម្មសិទ្ធិបញ្ញា និងការបញ្ចូលលទ្ធផលស្រាវជ្រាវនៅ ស.ភ.ភ.ព. ទៅក្នុងអាជ្ញាប័ណ្ណកម្រិតជាតិ កម្រិតតំបន់ និងអន្តរជាតិ និង
- លើកកម្ពស់ការបោះពុម្ពស្នាដៃស្រាវជ្រាវកម្រិតសាកលវិទ្យាល័យតាមអង្គភាពចំណុះ។

## ២.៣. ការិយាល័យបោះពុម្ពផ្សាយ និងគាំទ្រទស្សនាវដ្តីវិទ្យាសាស្ត្រ

- គ្រប់គ្រង និងដឹកនាំការងារស្រាវជ្រាវដែលអនុវត្តដោយមជ្ឈមណ្ឌលស្រាវជ្រាវ
- ផ្តល់ការគាំទ្រ និងជួយបេក្ខជនបណ្ឌិតក្នុងការបោះពុម្ពស្នាដៃក្នុងទស្សនាវដ្តីជាតិ និងអន្តរជាតិ
- បង្កើតទំនាក់ទំនង និងរក្សាដៃគូជាមួយវិស័យរដ្ឋនិងឯកជន អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា
- បង្កើតនិងបង្កើនទំនាក់ទំនងជាមួយសាកលវិទ្យាល័យដៃគូដើម្បីពង្រីកកិច្ចសហប្រតិបត្តិការក្នុងការបង្កើតគម្រោងស្រាវជ្រាវ
- កសាងទំនាក់ទំនងជាតិនិងអន្តរជាតិ ដើម្បីកៀរគរធនធាននិងធ្វើសហប្រតិបត្តិការស្រាវជ្រាវ

- កំណត់អាទិភាពនៃប្រភពបោះពុម្ព (Publisher) និងទស្សនាវដ្ដីវិទ្យាសាស្ត្រ ដែលបោះពុម្ពដោយសាស្ត្រាចារ្យ ស.ភ.ភ.ព.
- បោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវ ដែលទទួលបានពីមហាវិទ្យាល័យនីមួយៗនិងអ្នកពាក់ព័ន្ធដទៃទៀត
- បោះពុម្ពជាប្រចាំក្នុងទស្សនាវដ្ដីស្រាវជ្រាវជាតិ តំបន់ និងអន្តរជាតិ និង
- គ្រប់គ្រងរោងពុម្ព ស.ភ.ភ.ព. និងកំណត់ស្តង់ដាអត្ថបទសម្រាប់បោះពុម្ព ការពិនិត្យអត្ថន័យខ្លឹមសារ មាតិកា ក្រមសីលធម៌ស្រាវជ្រាវ ការងារមន្ទីរពិសោធន៍ន៍និងការលួចចម្លងសម្រាប់សៀវភៅ និងឯកសារស្រាវជ្រាវសម្រាប់ការបោះពុម្ពផ្សាយ។

# ជំពូកទី៣
# ក្របខណ្ឌអំណាច និងការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ

## ១. ក្របខណ្ឌអនុវត្តលើការស្រាវជ្រាវ
### ១.១. ការកំណត់សូចនាករផលសម្រេចលើការស្រាវជ្រាវ

សកម្មភាពស្រាវជ្រាវត្រូវបានកំណត់ជាអាទិភាព និងជំរុញឱ្យមានការចូលរួមទាំងនិស្សិត ទាំងបុគ្គលិកអប់រំ ស.ភ.ភ.ព.។ និស្សិតថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតនឹងមានឱកាសចូលរួមការស្រាវជ្រាវក្រោមគម្រោងស្រាវជ្រាវ ស.ភ.ភ.ព. ដែលនាំឱ្យមានការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត។ ជាងនេះទៅទៀត បុគ្គលិកអប់រំ ស.ភ.ភ.ព. ក៏អាចចូលរួមស្រាវជ្រាវជាមួយអ្នកស្រាវជ្រាវជាតិ តំបន់ និងអន្តរជាតិផងដែរ។ ការស្រាវជ្រាវត្រូវបានធ្វើឡើងដើម្បីលើកកម្ពស់ការស្រាវជ្រាវ ដែលពាក់ព័ន្ធនឹងការបង្កើតវិធីសាស្ត្រ និងបច្ចេកវិទ្យាថ្មី និង សេដ្ឋកិច្ចនិងឧស្សាហកម្ម។ ដូច្នេះ អ្នកស្រាវជ្រាវ ស.ភ.ភ.ព. ត្រូវផ្តោតការស្រាវជ្រាវទៅលើ៖ (១) គំនិតមួយផលិតផលមួយ, (២) ការផ្សារភ្ជាប់នឹងអភិវឌ្ឍន៍ និងការផ្ទេរបច្ចេកវិទ្យា, (៣) ការប្រើប្រាស់ដោយឧស្សាហកម្ម និងកសិកម្ម, និង (៤) ការស្វែងរកដំណោះស្រាយបញ្ហាបរិស្ថាន និងសុខមាលភាពសង្គម។

ដើម្បីលើកកម្ពស់ការស្រាវជ្រាវ ស.ភ.ភ.ព. បានកំណត់សូចនាករផលសម្រេចលើកញ្ចប់ស្រាវជ្រាវនៅចន្លោះឆ្នាំ២០២១ និង ២០៣០ ដូចតារាងទី២ និងទី៣ ខាងក្រោម។

**តារាងទី៣. ចំនួនកញ្ចប់ស្រាវជ្រាវនៅស.ភ.ភ.ព. (២០២១-២០៣០)**

| សូចនាករ | ឆ្នាំសម្រេចគោលដៅ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 2021 | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 |
| ចំនួនកញ្ចប់ស្រាវជ្រាវពីគំនិតមួយទៅជាផលិតផលមួយ | 0 | 15 | 15 | 15 | 15 | 15 | 15 | 15 | 20 | 20 |
| ចំនួនកញ្ចប់ស្រាវជ្រាវផ្សារភ្ជាប់នឹងការអភិវឌ្ឍ | 0 | 5 | 5 | 5 | 5 | 6 | 6 | 6 | 6 | 6 |
| ចំនួនកញ្ចប់ស្រាវជ្រាវប្រើដោយឧស្សាហ៍កម្ម | 0 | 16 | 16 | 16 | 16 | 16 | 16 | 16 | 20 | 20 |
| សរុប | 0 | 36 | 36 | 36 | 36 | 37 | 37 | 37 | 46 | 46 |

តារាងខាងក្រោមបង្ហាញបរិមាណនិងកញ្ចប់ថវិកា ដែលត្រូវបានព្យាករសម្រាប់ការងារស្រាវជ្រាវនៅចន្លោះឆ្នាំ២០២៣ និង ២០៣០។ កញ្ចប់ថវិកាត្រូវបានបែងចែកជាបីផ្នែកធំៗគឺ៖ (១) ៣០% សម្រាប់ការស្រាវជ្រាវផ្សារភ្ជាប់នឹងការអភិវឌ្ឍ, (២) ៦០% សម្រាប់ការស្រាវជ្រាវផ្នែកអាជីវកម្ម, និង (៣) ១០% សម្រាប់ការស្រាវជ្រាវរបស់និស្សិតក្រោយបរិញ្ញាបត្រ។ ក្នុងឆ្នាំ២០២២ ស.ភ.ភ.ព មានថវិកាសរុបចំនួន ៥,០០០,០០០ ដុល្លារអាមេរិក។ តារាងខាងក្រោមបង្ហាញការប៉ាន់ស្មានកំណើនថវិកា ១០% ក្នុងមួយឆ្នាំនៅចន្លោះពី ឆ្នាំ២០២៣ ដល់ ២០៣០។

**តារាងទី៤. ថវិកានិងចំនួនគម្រោងស្រាវជ្រាវនៅ ស.ភ.ភ.ព. (២០២១-២០៣០)**

| សូចនាករ | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 |
|---|---|---|---|---|---|---|---|---|
| ថវិកាសម្រាប់ការស្រាវជ្រាវមូលដ្ឋាន | | | | | | | | |
| ថវិកា | 5500000 | 6050000 | 6655000 | 7320500 | 8052550 | 885781 | 9743586 | 10717945 |
| ចំនួនគម្រោង | 0 | 7 | 7 | 7 | 7 | 7 | 10 | 10 |
| ថវិកាសម្រាប់ការស្រាវជ្រាវផ្សារភ្ជាប់នឹងការអភិវឌ្ឍ | | | | | | | | |
| ថវិកា | 1650000 | 1815000 | 1996500 | 2196150 | 2415765 | 265734.2 | 2923076 | 3215384 |
| ចំនួនគម្រោង | 0 | 0 | 0 | 5 | 5 | 6 | 6 | 6 |
| ចំនួនគម្រោងផ្ដើមអាជីវកម្ម | | | | | | | | |
| ថវិកា | 3000000 | 2200000 | 2420000 | 2662000 | 2928200 | 3221020 | 354312 | 389743 |
| ចំនួនគម្រោង | 0 | 5 | 5 | 5 | 5 | 5 | 5 | 5 |
| ថវិកាស្រាវជ្រាវសម្រាប់និស្សិតក្រោយបរិញ្ញាបត្រ | | | | | | | | |
| ថវិកា | 500000 | 550000 | 605000 | 665500 | 732050 | 805255 | 88578 | 97436 |
| ចំនួនគម្រោង | 0 | 50 | 50 | 50 | 70 | 70 | 70 | 70 |
| ចំនួនអត្ថបទបោះពុម្ពកម្រិតជាតិ | | | | | | | | |
| ចំនួនគម្រោង | 0 | 10 | 10 | 20 | 20 | 20 | 20 | 20 |
| ចំនួនអត្ថបទបោះពុម្ពកម្រិតអន្តរជាតិ | | | | | | | | |
| ចំនួនគម្រោង | 0 | 30 | 30 | 45 | 45 | 45 | 60 | 60 |
| ចំនួនផលិតផលចុះបញ្ជី ឬប៉ាតង់ | | | | | | | | |
| ចំនួនគម្រោង | 0 | 4 | 4 | 4 | 4 | 10 | 10 | 10 |

### ១.២. ការកំណត់ផែនការសកម្មភាពពី ៣ ទៅ ៥ឆ្នាំ ក្នុងប្រព័ន្ធធានាគុណភាពអប់រំឧត្តមសិក្សា

ស.ភ.ភ.ព. មានឆន្ទៈខ្ពស់ក្នុងការង្កើតប្រព័ន្ធធានាគុណភាពអប់រំឧត្តមសិក្សា ដើម្បីឈានដល់ការបង្កើតថ្មី និងវានុវត្តន៍។ ផែនការយុទ្ធសាស្ត្រ (២០២១-២០៣០) ស.ភ.ភ.ព. បានកំណត់ផែនការសកម្មភាពពី ៣ ទៅ ៥ឆ្នាំ ក្នុងប្រព័ន្ធធានាគុណភាពអប់រំឧត្តមសិក្សាចំនួន០៦ចំណុចដូចខាងក្រោម៖

- កសាងសមត្ថភាពលើជំនាញស្រាវជ្រាវ និងត្រួតពិនិត្យការស្រាវជ្រាវថ្នាក់បណ្ឌិត
- ធ្វើការស្រាវជ្រាវរួមគ្នាជាមួយស្ថាប័នស្រាវជ្រាវក្នុងស្រុក តំបន់ និងអន្តរជាតិ
- កែលម្អគុណភាពកម្មវិធីសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ
- ជ្រើសរើសអ្នកសិក្សាជាន់ខ្ពស់ ដើម្បីផ្តល់ការណែនាំ និងដឹកនាំការស្រាវជ្រាវ
- រៀបចំសិក្ខាសាលាស្រាវជ្រាវសម្រាប់បុគ្គលិក ដើម្បីអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងចែករំលែកលទ្ធផលស្រាវជ្រាវ ដោយបង្កើតយន្តការសម្រាប់ផ្តល់ការទទួលស្គាល់ និងផ្តល់រង្វាន់ជូនអ្នកមានស្នាដៃស្រាវជ្រាវល្អៗ
- អញ្ជើញអ្នកស្រាវជ្រាវល្បីៗមកធ្វើទស្សនកិច្ច និងសហការស្រាវជ្រាវជាមួយបុគ្គលិកអប់រំ ស.ភ.ភ.ព.។

**រូបភាពទី៥. ផែនការសកម្មភាពពី ៣ ទៅ ៥ឆ្នាំ ក្នុងប្រព័ន្ធធានាគុណភាពអប់រំ ស.ភ.ភ.ព.**




អន្តរជាតូបនីយកម្មបង្កើតបានជាផ្នែកនៃផែនការយុទ្ធសាស្ត្ររបស់ ស.ភ.ភ.ព. ដើម្បីចាប់ដំណើរការប្រកួតប្រជែងក្នុងតំបន់ និងអន្តរជាតិ។ ការសម្រេចបាននូវស្តង់ដាអន្តរជាតិសម្រាប់ការអប់រំឧត្តមសិក្សា គឺជាតម្រូវការជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ ការិយាល័យទំនាក់ទំនងអន្តរជាតិ (IRO) នៅ ស.ភ.ភ.ព. បានអនុវត្តរបៀបវារៈនេះតាមរយៈការកែលម្អបណ្តាញទំនាក់ទំនងជាមួយដៃគូក្នុងតំបន់ និងអន្តរជាតិសម្រាប់ការកែលម្អកម្មវិធីសិក្សា និងការស្រាវជ្រាវ។ ជាលទ្ធផល ស.ភ.ភ.ព. បានសហការជាមួយសាកលវិទ្យាល័យផ្សេងៗទូទាំងពិភពលោកតាមរយៈ៖

ក. កម្មវិធីផ្លាស់ប្តូរបុគ្គលិកអប់រំ ស.ភ.ភ.ព សម្រាប់ការស្រាវជ្រាវ

ខ. កម្មវិធីផ្លាស់ប្តូរនិស្សិតសម្រាប់ការស្រាវជ្រាវ

គ. ការបណ្តុះបណ្តាលជំនាញស្រាវជ្រាវ

ឃ. ចូលរួមកម្មវិធីកែលម្អលទ្ធផលអប់រំនិងស្រាវជ្រាវដូចជា ចូលរួមកិច្ចសហប្រតិបត្តិការអន្តរជាតិលើគម្រោងស្រាវជ្រាវ ចូលរួមក្នុងសន្និសីទអន្តរជាតិ សិក្ខាសាលា និងការប្រជុំនានា ព្រមទាំងចែករំលែកផងដែរនូវព័ត៌មានតាមរយៈអត្ថបទដែលបានបោះពុម្ពនៅក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រអន្តរជាតិ។

## ២. ការពិនិត្យតាមដាន និងវាយតម្លៃ

### ២.១. ការពិនិត្យតាមដានសកម្មភាពស្រាវជ្រាវ

ការិយាល័យតាមដាននិងវាយតម្លៃគម្រោងស្រាវជ្រាវនៃមជ្ឈមណ្ឌលគាំទ្រ និងគ្រប់គ្រងការស្រាវជ្រាវ និងនវានុវត្តន៍ត្រូវធ្វើការជាមួយអង្គភាពស្រាវជ្រាវនីមួយៗ ក្នុងការពិនិត្យគម្រោងស្រាវជ្រាវ ការបង្កើតផលិតផលគំរូថ្មី និងការលក់ប៉ាតង់នានា។ ការិយាល័យនឹងបង្កើតបណ្ណសារឌីជីថល (Digital Research Output) ដើម្បីតម្កល់ឯកសារស្រាវជ្រាវអនឡាញនេះសម្រាប់វាយតម្លៃស្នាដៃស្រាវជ្រាវ ផលប្រយោជន៍ និងផលជះនៃស្នាដៃស្រាវជ្រាវរបស់អ្នកស្រាវជ្រាវ។ មិនតែប៉ុណ្ណោះ ប្រព័ន្ធបណ្ណសារស្រាវជ្រាវឌីជីថលនេះនឹងត្រូវបានប្រើប្រាស់សម្រាប់តាមដាន និងប្រមូលទិន្នន័យផងដែរដូចជា៖

ក. ចំនួនសរុបនៃអ្នកស្រាវជ្រាវ ស.ភ.ភ.ព. ដែលត្រូវបានបែងចែកតាមប្រភេទស្រាវជ្រាវ

ខ. ចំនួនថវិកាស្រាវជ្រាវសរុប ដោយបែងចែកតាមប្រភពថវិកា (ស.ភ.ភ.ព. រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍នានា)

គ. ចំនួនគម្រោងស្រាវជ្រាវសរុបដោយបែងចែកតាមប្រភពថវិកាដូចជា ស.ភ.ភ.ព. រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាជាដើម

ង. ចំនួនសរុបនៃអត្ថបទស្រាវជ្រាវដែលបានបោះពុម្ព ចំនួនផលិតផលគំរូ និងចំនួនប៉ាតង់ដែលបានចុះឈ្មោះថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ និងចំនួនស្រាវជ្រាវដែលប្រើប្រាស់ដោយឧស្សាហកម្ម

ច. ចំនួនមន្ទីរពិសោធន៍ន៍ស្រាវជ្រាវស្តង់ដាជាតិ និងអន្តរជាតិ ដែលបំរើសេវាជូនឧស្សាហ៍កម្ម និងកសិកម្ម រួមទាំងដំណោះស្រាយបញ្ហាបរិស្ថាន និងសុខមាលភាព និង

ឆ. ចំនួនអ្នកស្រាវជ្រាវ និងឋានៈសាស្ត្រាចារ្យដែលអ្នកស្រាវជ្រាវទទួលបានការតែងតាំង។

### ២.២. ការវាយតម្លៃសមត្ថភាពស្រាវជ្រាវ

ស្នាដៃស្រាវជ្រាវទាំងអស់នឹងត្រូវបានបោះពុម្ពទុកក្នុងប្រព័ន្ធបណ្ណសារស្រាវជ្រាវឌីជីថល (Digital Research Output) ដើម្បីបង្កភាពងាយស្រួលដល់បុគ្គលិកអប់រំ ស.ភ.ភ.ព. ក្នុងការចែករំលែកព័ត៌មានស្រាវជ្រាវ និងងាយស្រួលក្នុងការធ្វើកិច្ចសហការស្រាវជ្រាវអន្តរជាតិ ឬស្ថាប័នដទៃ។ ប្រព័ន្ធបណ្ណសារស្រាវជ្រាវឌីជីថលនេះ (Digital Research Output) ជួយដល់ការផ្សព្វផ្សាយស្នាដៃស្រាវជ្រាវ និងលើកស្ទួយផលប្រយោជន៍ និងផលជះនៃស្នាដៃស្រាវជ្រាវរបស់បុគ្គលិកអប់រំ ស.ភ.ភ.ព. ឱ្យកាន់តែទូលំទូលាយ។ បុគ្គលិកអប់រំ ស.ភ.ភ.ព. ម្នាក់ៗត្រូវបង្កើតគណនីយមួយសម្រាប់បញ្ចូលនិងរក្សាទិន្នន័យដែលទាក់ទងនឹងការស្រាវជ្រាវក្នុងប្រព័ន្ធបណ្ណសារស្រាវជ្រាវឌីជីថលនេះរៀងរាល់៣ខែម្តង (ត្រីមាសទី១ ត្រីមាសទី២ ត្រីមាសទី៣ និងត្រីមាសទី៤)។ សមត្ថភាពអ្នកស្រាវជ្រាវត្រូវបានវាស់វែងនិងវាយតម្លៃដោយបែងចែកជា៥កម្រិត ដែលកម្រិតនីមួយៗមានលក្ខខណ្ឌដូចក្នុងតារាងខាងក្រោម។

## តារាងទី៥. ការវាយតម្លៃសមត្ថភាពស្រាវជ្រាវ

| សូចនាករ | ពិពណ៌នា |
|---|---|
| *ផែនការយុទ្ធសាស្ត្រ ឬសកម្មភាពអភិវឌ្ឍការស្រាវជ្រាវ* | |
| ឆ្នាំ 2022 | បាននិងកំពុងអនុវត្តពី 1 ទៅ 2 ឆ្នាំ (កម្រិត 1) |
| ឆ្នាំ 2030 | បាននិងកំពុងអនុវត្តច្រើនជាង 5 ឆ្នាំ (កម្រិត 3) |
| *កម្មវិធីវិនិយោគ (សាធារណៈ) លើការស្រាវជ្រាវ* | |
| ឆ្នាំ 2022 | បាននិងកំពុងអនុវត្តកម្មវិធីវិនិយោគ (សាធារណៈ) លើការស្រាវជ្រាវ ពី 1 ទៅ 3 ឆ្នាំ (កម្រិត 2) |
| ឆ្នាំ 2030 | បាននិងកំពុងអនុវត្តកម្មវិធីវិនិយោគ (សាធារណៈ) លើការស្រាវជ្រាវច្រើនជាង 3 ឆ្នាំ (កម្រិត 3) |
| *របនាសម្ព័ន្ធគ្រប់គ្រង និងគាំទ្រការស្រាវជ្រាវ* | |
| ឆ្នាំ 2022 | បាននិងអនុវត្តរចនាសម្ព័ន្ធគ្រប់គ្រង និងគាំទ្រការស្រាវជ្រាវពី 1 ទៅ 2 ឆ្នាំ (កម្រិត 1) |
| ឆ្នាំ 2030 | បាននិងអនុវត្តរចនាសម្ព័ន្ធគ្រប់គ្រង និងគាំទ្រការស្រាវជ្រាវច្រើនជាង 4 ឆ្នាំ (កម្រិត 3) |
| *ចំនួនអ្នកស្រាវជ្រាវ* | |
| ឆ្នាំ 2022 | មានផែនការ (កម្រិត 1) |
| ឆ្នាំ 2030 | សម្រេចបានយ៉ាងតិច 70% នៃផែនការ (កម្រិត 2) |
| *ផែនការអភិវឌ្ឍសមត្ថភាព* | |
| ឆ្នាំ 2022 | មានផែនការ (កម្រិត 1) |
| ឆ្នាំ 2030 | សម្រេចបានយ៉ាងតិច 70% នៃផែនការ (កម្រិត 2) |
| *ចំនួនគម្រោងស្រាវជ្រាវ* | |
| ឆ្នាំ 2022 | អនុវត្តពី 1 ទៅ 10 គម្រោង (កម្រិត 2) |
| ឆ្នាំ 2030 | អនុវត្តច្រើនជាង 10 គម្រោង (កម្រិត 3) |
| *សមិទ្ធផលនៃការស្រាវជ្រាវ* | |
| ឆ្នាំ 2022 | មានផែនការ (កម្រិត 1) |
| ឆ្នាំ 2030 | សម្រេចបានយ៉ាងតិច 70% នៃផែនការ (កម្រិត 2) |
| *ទិន្នន័យស្រាវជ្រាវ* | |
| ឆ្នាំ 2022 | កំពុងរៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងការស្រាវជ្រាវ (កម្រិត 1) |
| ឆ្នាំ 2030 | ប្រព័ន្ធព័ត៌មានគ្រប់គ្រងការស្រាវជ្រាវដំណើរការ (កម្រិត 2) |
| *ការរកចំណូលពីការស្រាវជ្រាវ* | |
| ឆ្នាំ 2022 | មានផែនការ (កម្រិត 1) |
| ឆ្នាំ 2030 | សម្រេចបានយ៉ាងតិច 70% នៃផែនការ (កម្រិត 2) |
| *ប្រព័ន្ធគាំទ្រ និងលើកទឹកចិត្តអ្នកស្រាវជ្រាវ* | |
| ឆ្នាំ 2022 | មានផែនការ (កម្រិត 1) |
| ឆ្នាំ 2030 | សម្រេចបានយ៉ាងតិច 70% នៃផែនការ (កម្រិត 2) |

ស.ភ.ភ.ព. ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជាគ្រឹះស្ថានឧត្តមសិក្សាជាតិឈានមុខគេខាងផ្នែកលទ្ធផលស្រាវជ្រាវ។ ឧទាហរណ៍ ការស្វែងរកមួយរបស់ Scopus បានបង្ហាញថា ស.ភ.ភ.ព. ជាគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាតែមួយគត់ដែលស្ថិតក្នុងលំដាប់កំពូលទាំង១០ ដែលមានអត្ថបទស្រាវជ្រាវបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីអន្តរជាតិដែលមានការត្រួតពិនិត្យត្រឹមត្រូវពីក្រុមអ្នកវិទ្យាសាស្ត្រ។ ទោះបីជាយ៉ាងនេះក្តី ក្នុងនាមជាគ្រឹះស្ថានស្រាវជ្រាវឈានមុខគេ ប្រសិនបើ ស.ភ.ភ.ព. មានបំណងចង់បានចំណាត់ថ្នាក់សាកលវិទ្យាល័យពិភពលោកនោះ ការវិនិយោគទ្រង់ទ្រាយធំលើសមត្ថភាពស្រាវជ្រាវរបស់គ្រឹះស្ថានគឺជាតម្រូវការចាំបាច់។ ប្រសិនបើគោលបំណងនេះបានសម្រេចមែន នោះមានន័យថា ប្រទេសកម្ពុជាមានសមត្ថភាពកាន់តែប្រសើរក្នុងការបង្កើតចំណេះដឹងក្នុងស្រុក និងនវានុវត្តន៍ក្នុងប្រទេស និងមានសមត្ថភាពក្នុងការដោះស្រាយដោយឯករាជ្យនូវបញ្ហាប្រឈមនានាដែលជួបប្រទះក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមឱ្យបានលទ្ធផលកាន់តែល្អប្រសើរ។

ចាប់តាំងពីឆ្នាំ២០១៧ ស.ភ.ភ.ព. បានចាប់ផ្តើមបង្កើតកញ្ចប់ថវិកាមួយហៅថា "ហិរញ្ញប្បទានស្រាវជ្រាវ ស.ភ.ភ.ព." សម្រាប់លើកស្ទួយវប្បធម៌ស្រាវជ្រាវនៅ ស.ភ.ភ.ព. និងដើម្បីលើកទឹកចិត្តអ្នកស្រាវជ្រាវឱ្យបោះពុម្ពស្នាដៃស្រាវជ្រាវក្នុងទស្សនាវដ្តីដែលមានការត្រួតពិនិត្យយ៉ាងត្រឹមត្រូវពីអ្នកវិទ្យាសាស្ត្រ និងដើម្បីបង្កើតផលិតផលគម្រូនិងផលិតផលថ្មី។ ស.ភ.ភ.ព. អាចវាយតម្លៃបានថា កម្រិតនៃសមិទ្ធផលស្រាវជ្រាវរបស់ខ្លួនស្ថិតនៅកម្រិតទី១ និងបន្តទៅកម្រិតទី២នៅឆ្នាំ២០៣០។ ដល់ឆ្នាំ២០៣៥ ស.ភ.ភ.ព. អាចឈានដល់កម្រិតទី ៣ ដែលគ្រឹះស្ថានមានការស្រាវជ្រាវសកម្មខ្លាំង ដើរតួនាទីជាស្ថាប័នស្រាវជ្រាវ អាចប្រកួតប្រជែងក្នុងកម្រិតជាតិ និងអន្តរជាតិ អនុវត្តប្រព័ន្ធគាំទ្រការស្រាវជ្រាវបានល្អប្រសើរ មានសក្តានុពល និងមានការទទួលស្គាល់ស្នាដៃស្រាវជ្រាវតាមស្តង់ដា ផ្សារភ្ជាប់ទៅនឹងការផលិត ឬរកប្រាក់ចំណូលពីទីផ្សារជាតិ និងអន្តរជាតិ តាមរយៈការពង្រឹងការស្រាវជ្រាវពីផលិតផលមួយផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍ។

**តារាងទី៦. កម្រិតនៃសមិទ្ធិផលស្រាវជ្រាវ ស.ភ.ភ.ព.**

| កម្រិត | វាយតម្លៃ | ឆ្នាំ | ពន្យល់ |
|---|---|---|---|
| 2 | ចន្លោះពីមធ្យមទៅខ្ពស់ | 2022 | គ្រឹះស្ថានមានសកម្មភាពស្រាវជ្រាវពីមធ្យមទៅខ្ពស់ ពោលគឺបាននិងកំពុងអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការវិនិយោគសាធារណៈរយៈពេលវែងរបស់ខ្លួនលើការស្រាវជ្រាវ ទាំងការបង្កើនធនធានមនុស្ស និងគម្រោងស្រាវជ្រាវ រៀបចំ និងអនុវត្តប្រព័ន្ធគាំទ្រការស្រាវជ្រាវដោយផ្តោតសំខាន់លើការបោះពុម្ព និងរកប្រាក់ចំណូលពីការស្រាវជ្រាវពីគំនិតមួយទៅផលិតផលមួយ។ |
| 2 | ចន្លោះពីមធ្យមទៅខ្ពស់ | 2030 | គ្រឹះស្ថានមានសកម្មភាពស្រាវជ្រាវពីមធ្យមទៅខ្ពស់ ពោលគឺបាននិងកំពុងអនុវត្តផែនការយុទ្ធសាស្ត្រ និង |

| | | | |
|---|---|---|---|
| | | | ផែនការវិនិយោគសាធារណៈរយៈពេលវែងរបស់ខ្លួនលើការស្រាវជ្រាវ ទាំងការបង្កើនធនធានមនុស្ស និងគម្រោងស្រាវជ្រាវ រៀបចំ និងអនុវត្តប្រព័ន្ធគាំទ្រការស្រាវជ្រាវដោយផ្តោតសំខាន់លើការបោះពុម្ព និងរកប្រាក់ចំណូលពីការស្រាវជ្រាវពីគំនិតមួយទៅផលិតផលមួយ។ |
| 3 | ខ្លាំង | 2035 | គ្រឹះស្ថានមានសកម្មភាពស្រាវជ្រាវសកម្មខ្លាំង ដើរតួនាទីជាស្ថាប័នស្រាវជ្រាវ អាចប្រកួតប្រជែងកម្រិតជាតិ និងអន្តរជាតិបាន អនុវត្តប្រព័ន្ធគាំទ្រការស្រាវជ្រាវបានល្អប្រសើរ មានសក្តានុពល និងការទទួលស្គាល់ស្នាដៃស្រាវជ្រាវតាមស្តង់ដា ផ្សារភ្ជាប់ទៅនឹងការផលិត ឬរកប្រាក់ចំណូលពីទីផ្សារជាតិនិងអន្តរជាតិ តាមរយៈការពង្រឹងការស្រាវជ្រាវពីផលិតផលមួយផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍ។ |

ការវាយតម្លៃសមត្ថភាពអ្នកស្រាវជ្រាវមានសារសំខាន់ក្នុងការកំណត់តែងតាំងតំណែង និងការផ្តល់ឋានៈសាស្ត្រាចារ្យ រួមទាំងរង្វាន់លើកទឹកចិត្តជាសាច់ប្រាក់ និងការផ្តល់លិខិតសរសើរ។ ការិយាល័យបោះពុម្ពផ្សាយនិងគាំទ្រទស្សនាវដ្តីវិទ្យាសាស្ត្រ នឹងចេញលទ្ធផលបូកសរុបនៅចុងខែធ្នូក្នុងគោលបំណងវាយតម្លៃលើស្នាដៃស្រាវជ្រាវរបស់បុគ្គលិកអប់រំ ស.ភ.ភ.ព. ដើម្បីកំណត់តំណែងជាសាស្ត្រាចារ្យ រង្វាន់លើកទឹកចិត្តប្រចាំឆ្នាំជាសាច់ប្រាក់ និងលិខិតសរសើរថ្នាក់ដូចមានកំណត់ក្នុងតារាងខាងក្រោម។

**តារាងទី៧. កម្រិតនៃសមិទ្ធផលស្រាវជ្រាវ**

| កម្រិតនៃសមិទ្ធផលស្រាវជ្រាវ | ប្រភេទរង្វាន់លើកទឹកចិត្ត |
|---|---|
| **កម្រិត 1 ៖** ចំនួនគម្រោងដែលគ្រប់គ្រងត្រូវបានអនុវត្តដោយជោគជ័យ | 20 ពិន្ទុសម្រាប់តំណែងជាសាស្ត្រាចារ្យ និងលិខិតសរសើរថ្នាក់លេខ 5 |
| **កម្រិត 2 ៖** ចំនួនអត្ថបទស្រាវជ្រាវ ឬ សន្ទស្សន៍/កម្រិតផលជះ (Impact Factor) ឬសៀវភៅសិក្សាដែលបានបោះពុម្ព (កម្រិតជាតិ និងអន្តរជាតិ) | 40 ពិន្ទុសម្រាប់តំណែងជាសាស្ត្រាចារ្យ រួមទាំងរង្វាន់លើកទឹកចិត្តប្រចាំឆ្នាំជាថវិកា និងលិខិតសរសើរថ្នាក់លេខ 4 |
| **កម្រិត 3 ៖** ចំណូលពីគម្រោងស្រាវជ្រាវ តាមរយៈការលក់ ការផ្តល់សេវាកម្ម និងការបង្កើតធុរកិច្ចថ្មី | 60 ពិន្ទុសម្រាប់តំណែងជាសាស្ត្រាចារ្យ រួមទាំងរង្វាន់លើកទឹកចិត្តចិត្តប្រចាំឆ្នាំជាថវិកា និងលិខិតសរសើរថ្នាក់លេខ 3 |

| | |
|---|---|
| **កម្រិត 4 ៖** ប្រកាសនីយបត្រតក្កកម្ម ឬយុទ្ធសាស្ត្រ/គោលនយោបាយដែលបានរៀបចំ | 80 ពិន្ទុសម្រាប់តំណែងជាសាស្ត្រាចារ្យ រួមទាំងរង្វាន់លើកទឹកចិត្តចិត្តប្រចាំឆ្នាំជាថវិកា និងលិខិតសរសើរថ្នាក់លេខ 2 |
| **កម្រិត 4 ៖** ការផ្ទេរចំណេះដឹង និងបច្ចេកវិទ្យាដែលបានចុះប្រកាសនីយបត្រតក្កកម្មទៅវិស័យឧស្សាហកម្ម ឬ សេវាកម្មក្នុងនិងក្រៅស្រុក | **100** ពិន្ទុសម្រាប់តំណែងជាសាស្ត្រាចារ្យ រួមទាំងរង្វាន់លើកទឹកចិត្តប្រចាំឆ្នាំជាថវិកា និងលិខិតសរសើរថ្នាក់លេខ 1 |

## ៣. ការអភិវឌ្ឍធនធានមនុស្ស

### ៣.១. ចំនួនអ្នកស្រាវជ្រាវ

ការិយាល័យតាមដាននិងវាយតម្លៃគម្រោងស្រាវជ្រាវត្រូវរៀបចំលក្ខខណ្ឌកំណត់អ្នកស្រាវជ្រាវ ហើយត្រូវធ្វើការជាមួយដេប៉ាតឺម៉ង់នីមួយៗដើម្បីកំណត់ចំនួនអ្នកស្រាវជ្រាវ។ ដើម្បីប្រែក្លាយ ស.ភ.ភ.ព. ទៅជាសាកលវិទ្យាល័យស្រាវជ្រាវ ផលធៀបរវាងអ្នកស្រាវជ្រាវនិងបុគ្គលិកបង្រៀនពេញម៉ោងត្រូវតែ ១:៣ នៅឆ្នាំ ២០៣០ និង ១:២ នៅឆ្នាំ២០៣៥។

តម្រូវការអ្នកស្រាវជ្រាវតាមផលធៀបរវាងអ្នកស្រាវជ្រាវនិងគ្រូបង្រៀនពេញម៉ោងសរុបតាមឆ្នាំមានដូចខាងក្រោម៖

- ផលធៀបរវាងអ្នកស្រាវជ្រាវនិងបុគ្គលិកបង្រៀនពេញម៉ោង ១:២
- ផលធៀបរវាងអ្នកស្រាវជ្រាវនិងបុគ្គលិកបង្រៀនពេញម៉ោង ១:៣
- ផលធៀបរវាងអ្នកស្រាវជ្រាវនិងបុគ្គលិកបង្រៀនពេញម៉ោង ១:៤
- ផលធៀបរវាងអ្នកស្រាវជ្រាវនិងបុគ្គលិកបង្រៀនពេញម៉ោង ១:៥

ក្នុងឆ្នាំ២០២២ ស.ភ.ភ.ព. មានបុគ្គលិកសរុបចំនួន ១០៨០នាក់ ដែលក្នុងនោះ មាន ៤៣៨នាក់ ជាបុគ្គលិកក្របខណ្ឌ និង ៦៤២នាក់ ជាបុគ្គលិកកិច្ចកិច្ចសន្យា។ ក្នុងចំណោមបុគ្គលិកសរុប ១០៨០នាក់ នោះ មានបុគ្គលិកបង្រៀនពេញម៉ោងចំនួន ៧៤៩នាក់ និង បុគ្គលិកការិយាល័យចំនួន ៣៣១នាក់។ ទន្ទឹមនឹងនោះ ស.ភ.ភ.ព. មានអ្នកស្រាវជ្រាវជាប់លាប់ចំនួន ៩៧នាក់ ក្នុងនោះ ផ្នែកស្នែមមានចំនួន ៥៩នាក់ និងផ្នែកដទៃទៀតមានចំនួន ៣៨នាក់។ ដូច្នេះ ផលធៀបរវាងអ្នកស្រាវជ្រាវនិងបុគ្គលិកបង្រៀនពេញម៉ោងរបស់ ស.ភ.ភ.ព. គឺ ១:៥ ឬស្ថិតក្នុងកម្រិត១ខ នៅឡើយក្នុងឆ្នាំ២០២២។ យោងតាមការប៉ាន់ស្មានតាមកំណើន១០% ក្នុង១ឆ្នាំ ស.ភ.ភ.ព. នឹងត្រូវមានអ្នកស្រាវជ្រាវចំនួន ៣០២នាក់ ឬត្រូវមានផលធៀបរវាងអ្នកស្រាវជ្រាវនិងបុគ្គលិកបង្រៀនពេញម៉ោង ១:៣ នៅឆ្នាំ២០៣០ ទើប ស.ភ.ភ.ព. អាចប្រែក្លាយជាសាកលវិទ្យាល័យស្រាវជ្រាវ កម្រិត២ (មធ្យម-ខ្ពស់)។

**តារាងទី៨. កម្រិតសមត្ថភាពស្រាវជ្រាវ**

| កម្រិតសមត្ថភាពស្រាវជ្រាវ | សូចនាករ | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 |
|---|---|---|---|---|---|---|---|---|---|---|

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| **កម្រិត 3** (សកម្មខ្លាំង) | ផលធៀប 1 : 2 | | | | | | | | | |
| **កម្រិត 2** (មធ្យម-ខ្ពស់) | ផលធៀប 1 : 3 | | | | | | | 250 | 275 | 302 |
| **កម្រិត 1 ក** (ដំបូង) | ផលធៀប 1 : 4 | | | | 187 | 206 | 227 | | | |
| **កម្រិត 1 ខ** (តិចតួច) | ផលធៀប 1 : 5 | 145 | 160 | 175 | | | | | | |

## ៣.២. តម្រូវការបណ្តុំជំនាញសម្រាប់អ្នកស្រាវជ្រាវ

បណ្តុំជំនាញនិងធាតុផ្សំសំខាន់ៗសម្រាប់អ្នកស្រាវជ្រាវ ស.ភ.ភ.ព. ផ្តោតការយកចិត្តទុកដាក់លើមានៈ ស្រាវជ្រាវ ពាណិជ្ជកម្ម វិទ្យាសាស្ត្រទិន្នន័យ គ្រប់គ្រងថវិកា គ្រប់គ្រងគម្រោង អភិបាលកិច្ច ច្បាប់ រៀបចំកម្មវិធីផ្សេងៗ ទំនាក់ទំនងសាធារណៈ និងវិទ្យាសាស្ត្រសង្គម។ អ្នកស្រាវជ្រាវត្រូវមានចំណេះដឹង (knowledge) បំណិន (skill) និងសមត្ថភាពការងារ (competency)។ មិនតែប៉ុណ្ណោះ អ្នកស្រាវជ្រាវត្រូវមានបណ្តុំជំនាញ ដែលអាចធ្វើការស្រាវជ្រាវដោយជោគជ័យ ការបោះពុម្ព និងបង្កើតប្រាក់ចំណូលពីគម្រោងស្រាវជ្រាវតាមរយៈការលក់ ការផ្តល់សេវាកម្ម និងការបង្កើតធុរកិច្ចថ្មី។

**តារាងទី៩. កម្រិតតម្រូវការបណ្តុំជំនាញសម្រាប់អ្នកស្រាវជ្រាវ**

| បណ្តុំជំនាញ | ពិពណ៌នា |
|---|---|
| **ស្រាវជ្រាវ** | ចំណេះដឹងនិងជំនាញស្តីពីដំណើរការស្រាវជ្រាវ សមត្ថភាពវិភាគនិងប្រើប្រាស់ទិន្នន័យជាលទ្ធផលឬព័ត៌មាន ការបង្កើតកម្រងសំណួរ ការរៀបចំប្លង់សិក្សាពិសោធន៍ ការសរសេរអត្ថបទស្រាវជ្រាវសម្រាប់បោះពុម្ពក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ និងការដាក់ប្រកាសនីយបត្រតក្កកម្ម (Patent)។ |
| **ពាណិជ្ជកម្ម** | ចំណេះដឹង និងជំនាញសាកលស្តីពីការប្រកួតប្រជែងពាណិជ្ជកម្មក្នុងទីផ្សារសេរី ការរៀបចំស្នើសុំប្រកាសនីយបត្រតក្កកម្មទៅវិស័យឧស្សាហកម្ម ឬសេវាកម្មក្នុង/ក្រៅស្រុកឬតំបន់ និងអាចបង្កើតចំណូលបានពីគម្រោងស្រាវជ្រាវ តាមរយៈការលក់ ការផ្តល់សេវាកម្ម និងការបង្កើតធុរកិច្ចថ្មី |
| **វិទ្យាសាស្ត្រទិន្នន័យ** | ចំណេះដឹងផ្នែក Big Data ការទាញយកមកប្រើប្រាស់ ការគ្រប់គ្រងទិន្នន័យឌីជីថល និង ការវិភាគនិងការបកស្រាយទិន្នន័យ |
| **គ្រប់គ្រងថវិកា** | ជំនាញគណនេយ្យ ហិរញ្ញវត្ថុ សវនកម្ម លទ្ធកម្ម ការគ្រប់គ្រងគម្រោង |
| **អភិបាលកិច្ច** | ការងារក្រុម ការធានាគុណភាព រចនាសម្ព័ន្ធគ្រប់គ្រង ការវិភាគយុទ្ធសាស្ត្រ |
| **ច្បាប់** | ចំណេះដឹងក្រមសីលធម៌ស្រាវជ្រាវ ការប្រមូលទិន្នន័យ និងប្រើប្រាស់ទិន្នន័យគោលនយោបាយ និងក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិ |

| | |
|---|---|
| **ការរៀបចំកម្មវិធី** | សមត្ថភាពរៀបចំពិធី/ព្រឹត្តិការណ៍/វេទិកាផ្សេងៗដើម្បីផ្ទេរនិងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ នៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ |
| **គ្រប់គ្រងគម្រោង** | ជំនាញសរសេរគម្រោងស្រាវជ្រាវ ការរៃអង្គាសធនធាន ការគ្រប់គ្រងគម្រោង និងជំនាញដឹកនាំក្រុមអ្នកស្រាវជ្រាវ |
| **ទំនាក់ទំនងសាធារណៈ** | ជំនាញទំនាក់ទំនងសាធារណៈ និងគ្រប់គ្រងបុគ្គលិក កម្មវិធីផ្លាស់ប្តូរ ការចូលរួមសិក្ខាសាលាថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ |
| **វិទ្យាសាស្ត្រសង្គម** | គោលដៅអភិវឌ្ឍដោយចីរភាពផ្នែកអភិវឌ្ឍន៍សហគមន៍និងទីក្រុង បរិស្ថាន បម្រែបម្រួលអាកាសធាតុ អប់រំ ចិត្តវិទ្យា ទន្លេមេគង្គ និងទន្លេសាប |

បណ្តុំជំនាញខាងលើគឺជាមូលដ្ឋានសម្រាប់អ្នកស្រាវជ្រាវបង្ហាញពីសមត្ថភាព និងលទ្ធភាពរបស់ខ្លួនក្នុងការបំពេញការងារ ក៏ដូចជាការរៀបចំផែនការស្រាវជ្រាវ។ ការិយាល័យតាមដាននិងវាយតម្លៃគម្រោងស្រាវជ្រាវមានតួនាទីវាយតម្លៃដើម្បីកំណត់កម្រិតតម្រូវការជំនាញរបស់អ្នកស្រាវជ្រាវ ដែលមាន ៣ កម្រិត៖ (១) ថ្នាក់ដឹកនាំ, (២) គ្រប់គ្រង, និង (៣) បច្ចេកទេស។ ជាងនេះទៅទៀត ការិយាល័យនេះនឹងផ្តល់វគ្គបណ្តុះបណ្តាល ដើម្បីពង្រឹងនិងពង្រីកសមត្ថភាពអ្នកស្រាវជ្រាវឱ្យមានសមត្ថភាពខ្ពស់។ តម្រូវការនៃជំនាញនានាត្រូវបានបែងចែកតាមកម្រិតនីមួយៗដូចក្នុងតារាងខាងក្រោម។

**តារាងទី១០. តារាងតម្រូវការជំនាញទាំង ៣ កម្រិតនៅក្នុងការងារស្រាវជ្រាវ**

| កម្រិត | តម្រូវការជំនាញ |
|---|---|
| **កម្រិតថ្នាក់ដឹកនាំ** | • តាក់តែង វិភាគ និងវាយតម្លៃគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការស្រាវជ្រាវ<br>• កៀរគរថវិកានិងទំនាក់ទំនងសាធារណៈ ចរចារជាមួយដៃគូជាតិនិងអន្តរជាតិ<br>• កម្មសិទ្ធិបញ្ញា និង ការផ្ទេរចំណេះដឹងនិងបច្ចេកវិទ្យាទៅក្នុងទីផ្សារ<br>• គ្រប់គ្រងដំណើរស្រាវជ្រាវ និងអ្នកស្រាវជ្រាវ<br>• ប្រើប្រាស់ទិន្នន័យពីលទ្ធផលស្រាវជ្រាវរបស់គ្រឹះស្ថានឧត្តមសិក្សាដើម្បីកំណត់ចក្ខុវិស័យ និងបេសកកម្ម<br>• ការធ្វើពាណិជ្ជកម្មលើលទ្ធផលស្រាវជ្រាវ<br>• តាមដានការអនុវត្តផែនការសកម្មភាព និងលើកទឹកចិត្តអ្នកស្រាវជ្រាវ។ |
| **កម្រិតគ្រប់គ្រង** | • សមត្ថភាពភាសាអង់គ្លេសនិងភាសាបរទេសផ្សេងទៀតកាន់តែប្រសើរ<br>• តាក់តែង វិភាគ និងវាយតម្លៃគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតគតិយុត្តពាក់ព័ន្ធនឹងការស្រាវជ្រាវ<br>• ជំនាញសរសេរគម្រោងស្រាវជ្រាវ និងស្នើសុំមូលនិធិស្រាវជ្រាវ |

| | |
|---|---|
| | • ជំនាញវិធីសាស្ត្រស្រាវជ្រាវ វិភាគស្ថិតិ សរសេររបាយការណ៍ស្រាវជ្រាវ<br>• ជំនាញផែនការ និងគ្រប់គ្រងគម្រោងស្រាវជ្រាវ<br>• គ្រប់គ្រងក្រមសីលធម៌នៃការស្រាវជ្រាវ<br>• ទំនាក់ទំនងសាធារណៈ ចរចារជាមួយដៃគូជាតិ និងអន្តរជាតិ និងកៀរគរថវិកា<br>• ការធ្វើពាណិជ្ជកម្មលើលទ្ធផលស្រាវជ្រាវ<br>• គ្រប់គ្រងពិនិត្យតាមដានលទ្ធផលស្រាវជ្រាវ។ |
| **កម្រិតបច្ចេកទេស** | • សមត្ថភាពភាសាអង់គ្លេសនិងភាសាបរទេសផ្សេងទៀតកាន់តែប្រសើរ<br>• ជំនាញសរសេរគម្រោងស្រាវជ្រាវនិងស្នើសុំមូលនិធិស្រាវជ្រាវ<br>• ជំនាញវិធីសាស្ត្រស្រាវជ្រាវនិងវិភាគស្ថិតិ<br>• ជំនាញផែនការនិងគ្រប់គ្រងគម្រោងស្រាវជ្រាវ<br>• ជំនាញគ្រប់គ្រងទិន្នន័យនិងសរសេររបាយការណ៍/អត្ថបទស្រាវជ្រាវ<br>• ការបង្កើតនិងគ្រប់គ្រងទស្សនាវដ្ដីវិទ្យាសាស្ត្រ<br>• ការពិនិត្យគុណភាពអត្ថបទ/របាយការណ៍ស្រាវជ្រាវ<br>• ជំនាញបោះពុម្ពអត្ថបទស្រាវជ្រាវ ឬរៀបចំប៉ាតង់សម្រាប់លទ្ធផលស្រាវជ្រាវ<br>• រៀបចំវេទិកា ឬថ្នាលផ្សព្វផ្សាយសមិទ្ធផលស្រាវជ្រាវ<br>• ជំនាញ ឬយល់ដឹងពីកិច្ចការហិរញ្ញវត្ថុសាធារណៈ<br>• ជំនាញឬយល់ដឹងពីកិច្ចការលទ្ធកម្មសាធារណៈ។ |

### ៣.៣. ការកសាងសមត្ថភាពស្រាវជ្រាវ

ផែនការយុទ្ធសាស្ត្រឆ្នាំ២០២១-៣០ បានចាត់ទុកការកសាងសមត្ថភាពស្រាវជ្រាវ ជាយុទ្ធសាស្ត្រចម្បងមួយរបស់ ស.ភ.ភ.ព. ដើម្បីឈានទៅរកភាពជោគជ័យក្នុងការអនុវត្តសកម្មភាព និងការប្រតិបត្តិគម្រោងនានាក្នុងសាកលវិទ្យាល័យ។ ដើម្បីធ្វើឱ្យធនធានមនុស្សមានសមត្ថភាពពេញលេញក្នុងការប្រតិបត្តិអាជីព សាកលវិទ្យាល័យត្រូវផ្តល់ជំនាញដល់បុគ្គលិកអប់រំ ស.ភ.ភ.ព. ក្រោមឱវាទ ចំនួន០២ សំខាន់ៗគឺ ជំនាញទន់ (soft skill) និងជំនាញរឹង (hard skill)។ ក្នុងន័យនេះ បុគ្គលិកអប់រំ ស.ភ.ភ.ព. ត្រូវការអភិវឌ្ឍជំនាញទន់និងរឹងជាប្រចាំ ដើម្បីធានាថា ជំនាញឯកទេសរបស់ខ្លួនដើរទាន់សម័យឌីជីថល ដោយរួមបញ្ចូលទាំងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការគ្រប់គ្រងព័ត៌មាន/ទិន្នន័យ ការចែកចាយ និងការផ្សព្វផ្សាយព័ត៌មាន ចំណេះដឹងក្នុងវិស័យអប់រំ និងទំនាក់ទំនងតាមបណ្តាញសង្គមផ្សេងៗ។ល។

**តារាងទី១១. ជំនាញទន់និងជំនាញរឹង ដែលត្រូវផ្តល់ជូនបុគ្គលិកអប់រំ ស.ភ.ភ.ព.**

| **ជំនាញទន់ (soft skill)** | **ជំនាញរឹង (hard skill)** |
|---|---|
| • ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង | • ចំណេះដឹងក្នុងការប្រើប្រាស់បច្ចេកវិទ្យា |

| | |
|---|---|
| • ការងាររដ្ឋបាលនិងហិរញ្ញវត្ថុ<br>• ការងារលទ្ធកម្ម<br>• ទំនាក់ទំនងសាធារណៈ<br>• ការសម្របសម្រួល<br>• ការងារជាក្រុម<br>• ការដោះស្រាយបញ្ហា<br>• ការសម្របខ្លួន<br>• ការត្រិះរិះពិចារណាគ្រប់ជ្រុងជ្រោយ<br>• ជំនាញធ្វើបទបង្ហាញ<br>• ការគ្រប់គ្រងមន្ទីរពិសោធន៍ន៍<br>• នីតិវិធីដាក់ប៉ាតង់ឬផលិតផលថ្មី | • ការប្រើប្រាស់ software សម្រាប់វិភាគទិន្នន័យ<br>• Machine learning and big data and data science,<br>• ការស្រាវជ្រាវទីផ្សារ និងទស្សនៈរបស់អ្នកប្រើប្រាស់ (consumer insights)<br>• វិធីសាស្ត្រស្រាវជ្រាវ<br>• ការគ្រប់គ្រង វិភាគ និងបកស្រាយទិន្នន័យ<br>• ការសរសេរបាយការណ៍ស្រាវជ្រាវ និងបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រ<br>• ការប្រើប្រាស់ ថែរក្សា និងជួសជុលមន្ទីរពិសោធន៍ន៍ |

**រូបភាពទី៦. ចំនួន និងតម្រូវការជំនាញទន់និងរឹង**




ដើម្បីបណ្ដុះគំនិតភាពជាអ្នកដឹកនាំ ស.ភ.ភ.ព. បាននិងកំពុង៖ (១) បញ្ចូលមុខវិជ្ជាវិធីសាស្ត្រស្រាវជ្រាវទៅក្នុងកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់គ្រប់ជំនាញ, (២) រៀបចំកម្មវិធីបំប៉នអ្នកស្រាវជ្រាវនៅ ស.ភ.ភ.ព., (៣) រៀបចំគោលនយោបាយស្រាវជ្រាវ និងសេចក្ដីណែនាំក្រមសីលធ៌មស្រាវជ្រាវ, និង (៤) បញ្ចូលមុខវិជ្ជាវិធីវិទ្យាសាស្ត្រ (Scientific Methods) និងក្រមសីលធម៌ស្រាវជ្រាវទៅក្នុងកម្មវិធីសិក្សាថ្នាក់បណ្ឌិត។ ចាប់ពីឆ្នាំ២០១៨ដល់២០២២ គម្រោងស្រាវជ្រាវ ដែលមានកិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិ និងមានប្រភពថវិកាពីម្ចាស់ជំនួយអន្តរជាតិ មានចំនួន១២គម្រោង។ ដៃគូនិងម្ចាស់ជំនួយទាំងអស់នោះច្រើនមកពីអឺរ៉ុប អាមេរិក និងអាស៊ី។ គម្រោងសហប្រតិបត្តិការអន្តរជាតិច្រើនតែជួយកសាងនិងពង្រឹងសមត្ថភាពបុគ្គលិក-សាស្ត្រាចារ្យលើការសិក្សាស្រាវជ្រាវ បោះពុម្ពផ្សាយ បង្រៀននិងរៀន និងផ្ដល់ការគាំទ្រដល់

បុគ្គលិក-សាស្ត្រាចារ្យនិងនិស្សិតទៅបន្តការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រនៅសាកលវិទ្យាល័យដៃគូទាំងនោះទៀតផង។

## ៣.៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវ

ក្នុងការចូលរួមចំណែកលើកកម្ពស់គុណភាពធនធានមនុស្សនិងកម្រិតជីវភាពប្រជាជន និងក្នុងដំណើរការអនុវត្តក្របខណ្ឌលទ្ធផលរយៈពេល១០ឆ្នាំ (២០២១-២០៣០) តាមប្រព័ន្ធ E4 ស.ភ.ភ.ព. នឹងបង្កើនការស្រាវជ្រាវផ្នែកអនុវត្ត និងផ្នែកទ្រឹស្តី។ ស.ភ.ភ.ព. មានសកម្មភាពយុទ្ធសាស្ត្រដូចខាងក្រោមៈ

**តារាងទី១២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវ**

| ប្រភេទ | ពិពណ៌នា |
|---|---|
| រៀបចំមន្ទីរពិសោធន៍ន៍ស្រាវជ្រាវឱ្យមានស្តង់ដា និងបង្កើតក្រុមស្រាវជ្រាវ | • មន្ទីរពិសោធន៍ន៍សម្រាប់អ្នកស្រាវជ្រាវគឺជាកន្លែងអនុវត្តកិច្ចការពិសោធ ក្នុងគោលបំណងស្វែងរកគំហើញថ្មីៗ និងវឌ្ឍនភាពក្នុងវិស័យវិទ្យាសាស្ត្រ។ មន្ទីរពិសោធន៍ន៍ក៏ត្រូវបានប្រើដើម្បីត្រួតពិនិត្យគុណភាព និងបង្កើនប្រសិទ្ធភាពនៃដំណើរការមុននឹងផលិត។<br>• ស.ភ.ភ.ព. កំពុងធ្វើទំនើបកម្ម ដោយបង្កើតមន្ទីរពិសោធន៍ន៍ដើម្បីទាក់ទាញអ្នកស្រាវជ្រាវតាមបែបទ្រឹស្តីល្បីៗ និងចូលរួមបង្កើតផលិតផលថ្មី សម្រាប់គាំទ្រឧស្សាហកម្មធន់ធ្ងន់ ធន់មធ្យម និងធន់តូច។ |
| ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីការប្រើប្រាស់ឧបករណ៍ស្រាវជ្រាវទំនើបៗ | • ត្រូវបង្កើតសៀវភៅណែនាំស្តីពីការគ្រប់គ្រងមន្ទីរពិសោធន៍ន៍។<br>• នៅក្នុងមន្ទីរពិសោធន៍ន៍ អ្នកស្រាវជ្រាវអាចរៀនប្រើឧបករណ៍ និងអនុសញ្ញាវិទ្យាសាស្ត្រ។ ឧទាហរណ៍ៈ អ្នកស្រាវជ្រាវអាចអភិវឌ្ឍជំនាញក្នុងការប្រើប្រាស់ឧបករណ៍វិទ្យាសាស្ត្របានត្រឹមត្រូវ និងសុវត្ថិភាព ធ្វើការសង្កេត វាស់វែង និងអនុវត្តនីតិវិធីវិទ្យាសាស្ត្រដែលបានកំណត់យ៉ាងល្អ។<br>• សេចក្តីណែនាំស្តីពីការប្រើប្រាស់ឧបករណ៍ ឬ វាក្យសព្ទ (terminology) នឹងត្រូវបានផ្តល់ជាភាសាខ្មែរ និងភាសាបរទេសដើម្បីធានាថារាល់ឧបករណ៍ត្រូវបានប្រើប្រាស់បានត្រឹមត្រូវ និងមានប្រសិទ្ធភាព។ |
| ផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ICT សម្រាប់ការស្រាវជ្រាវ និងផ្តល់លទ្ធភាពដែលអាចទទួលបាន | • អ្នកស្រាវជ្រាវត្រូវទទួលបាននូវហេដ្ឋារចនាសម្ព័ន្ធ និងឧបករណ៍ ICT ល្អបំផុតសម្រាប់ការស្រាវជ្រាវ។ |

| | |
|---|---|
| ឯកសារស្រាវជ្រាវ | • ឧបករណ៍ ICT សំខាន់ៗមានដូចជា Desktop, Laptop, Internet/LAN, គ្រឿងបរិក្ខារ WI-FI, OFF-Campus ចូលទៅកាន់ e-Journals, និងការបោះពុម្ពផ្សាយជាដើម។<br>• ប្រែក្លាយបណ្ណាល័យជាបណ្ណាល័យស្រាវជ្រាវតាមបែបឌីជីថលនីយកម្មសម្រាប់គាំទ្រការស្រាវជ្រាវ។ |

## ៣.៥. ការបណ្តុះបណ្តាល និងកសាងសមត្ថភាព

ស.ភ.ភ.ព. នឹងវិនិយោគរយៈពេលវែងក្នុងការបណ្តុះបណ្តាលនិងកសាងសមត្ថភាព ដើម្បីជួយគាំទ្រអ្នកស្រាវជ្រាវវ័យក្មេងឱ្យមានឱកាសក្នុងការទទួលបានថវិកាស្រាវជ្រាវ ធ្វើការបង្កើតថ្មី និងបោះពុម្ពលទ្ធផលស្រាវជ្រាវ។ ការកសាងសមត្ថភាពស្រាវជ្រាវជាដំណើរការនៃការអភិវឌ្ឍជំនាញ និងបំណិន និងសមត្ថភាពការងារប្រកបដោយចីរភាពពិតជាមានសារសំខាន់ក្នុងការជួយឱ្យបុគ្គលិក ស.ភ.ភ.ព. ចេះស្រាវជ្រាវប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។ ការកសាងសមត្ថភាពត្រូវបានកំណត់ថាជាដំណើរការនៃការអភិវឌ្ឍ និងពង្រឹងជំនាញ សមត្ថភាព ដំណើរការ និងធនធាន ដែល ស.ភ.ភ.ព. និងសហគមន៍ត្រូវការ ដើម្បីឆ្លើយតបតាមតម្រូវការក្នុងស្រុក តំបន់ និងអន្តរជាតិ។ លទ្ធផលស្រាវជ្រាវក្នុងការអនុវត្តទូទៅតម្រូវឱ្យមានការកែលម្អក្នុងផ្នែកៈ របកគំហើញនៃការស្រាវជ្រាវ ការទទួលបានចំណេះដឹង ការបណ្តុះបណ្តាល កម្មវិធីផ្លាស់ប្តូរ និងបណ្តាញស្រាវជ្រាវសហការជាមួយឧស្សាហកម្ម អាជ្ញាធរ និងអ្នកពាក់ព័ន្ធឯទៀត។

**តារាងទី១៣. ការបណ្តុះបណ្តាល និងកសាងសមត្ថភាព**

| ទម្រង់នៃការបណ្តុះបណ្តាល និងការកសាងសមត្ថភាព | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 |
|---|---|---|---|---|---|---|---|---|---|
| 1. ចំនួនកម្មវិធីអភិវឌ្ឍគុណវុឌ្ឍិអ្នកស្រាវជ្រាវ | 0 | 6 | 6 | 6 | 6 | 6 | 6 | 6 | 6 |
| 2. ចំនួនកម្មវិធីបណ្តុះបណ្តាលផ្ទៃក្នុងជាប្រចាំលើជំនាញស្រាវជ្រាវ និងគ្រប់គ្រងការស្រាវជ្រាវ | 0 | 4 | 4 | 4 | 4 | 4 | 4 | 4 | 4 |
| 3. ចំនួនកម្មវិធីអភិវឌ្ឍសមត្ថភាពសាស្ត្រាចារ្យដឹកនាំនិស្សិតថ្នាក់ក្រោយបរិញ្ញាបត្រ និងក្រមសីលធម៌អ្នកស្រាវជ្រាវ | 0 | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 4. ថវិកាគាំទ្រសាស្ត្រាចារ្យនិងនិស្សិតដែលអនុវត្តគម្រោងស្រាវជ្រាវរួមគ្នា | 0 | 100 ពាន់ ដុល្លារ | 100 ពាន់ ដុល្លារ | 100 ពាន់ ដុល្លារ | 100 ពាន់ ដុល្លារ | 100 ពាន់ ដុល្លារ | 100 ពាន់ ដុល្លារ | 100 ពាន់ ដុល្លារ | 100 ពាន់ ដុល្លារ |

## ៣.៦. ការថែរក្សានិងលើកទឹកចិត្តអ្នកស្រាវជ្រាវ

គោលនយោបាយនេះមានគោលដៅលើកទឹកចិត្តបុគ្គលិកអប់រំ ស.ភ.ភ.ព. ឱ្យធ្វើការស្រាវជ្រាវ។ ប៉ុន្តែ បច្ចុប្បន្ននេះ បុគ្គលិកអប់រំ ស.ភ.ភ.ព. ត្រូវបានទាក់ទាញដោយសកម្មភាពបង្រៀន ព្រោះពួកគាត់អាចទទួលបានប្រាក់ម៉ោងបន្ថែមពីសកម្មភាពបង្រៀននេះ។ ដូច្នេះ ដើម្បីសម្រេចគោលដៅនេះបាន ការផ្តល់គ្រឿងលើកទឹកចិត្តជាសាច់ប្រាក់និងជាប័ណ្ណសរសើរគឺជាគន្លឹះសំខាន់។ ដើម្បីឱ្យសកម្មភាពស្រាវជ្រាវកាន់តែមានភាពទាក់ទាញ ការលើកទឹកចិត្តជាសាច់ប្រាក់នឹងត្រូវបានផ្តល់ជូនដោយផ្អែកលើចំនួននៃការបោះពុម្ពផ្សាយដែលអ្នកស្រាវជ្រាវនីមួយៗសម្រេចបាន។

បុគ្គលិក ស.ភ.ភ.ព. ដែលធ្វើការស្រាវជ្រាវដោយបានទទួលហិរញ្ញប្បទានស្រាវជ្រាវ ស.ភ.ភ.ព. ឬជំនួយស្រាវជ្រាវ ឬប្រាក់កម្ចី ហើយដែលស្នាដៃស្រាវជ្រាវរបស់គាត់ត្រូវបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីដែលបានពិនិត្យត្រឹមត្រូវដោយអ្នកវិទ្យាសាស្ត្រ នឹងត្រូវទទួលបាននូវគ្រឿងលើកទឹកចិត្តជាសាច់ប្រាក់ និងជាប័ណ្ណសរសើរ។ រៀងរាល់ឆ្នាំ ការិយាល័យបោះពុម្ពផ្សាយនិងគាំទ្រទស្សនាវដ្តីវិទ្យាសាស្ត្រនឹងធ្វើការជាមួយអនុគណៈកម្មការក្រមសីលធម៌ស្រាវជ្រាវ អនុគណៈកម្មការប្រឹក្សាយោបល់ និង អនុគណៈកម្មការគ្រប់គ្រងការបោះពុម្ពឯកសារសិក្សានិងស្រាវជ្រាវរបស់ ស.ភ.ភ.ព. កំណត់ចំនួនគ្រឿងលើកទឹកចិត្តជាសាច់ប្រាក់និងជាប័ណ្ណសរសើរក្នុងអំឡុងពេលធ្វើផែនការសកម្មភាព និងថវិកា។ ការិយាល័យនិងអនុគណៈកម្មការធ្វើការប្រជុំវាយតម្លៃលើបរិមាណនិងគុណភាពនៃទស្សនាវដ្តីវិទ្យាស្ត្រដែលបានបោះពុម្ព ប្រភេទផលិតផលគំរូនិងការដាក់ប៉ាតង់ដែលបានផលិត។ ការលើកទឹកចិត្តទាំងនេះអាចត្រូវបានផ្តល់ជូនអ្នកស្រាវជ្រាវដែលបានបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវដោយជោគជ័យ ហើយត្រូវបានគេដកស្រង់ជាហូហែរចេញពីសន្ទស្សន៍ដកស្រង់ដូចជា SCI (Science Citation Index), SSCI (Social Sciences Citation Index), ISI (The Institute for Scientific Information), Scopus និងសន្ទស្សន៍ដកស្រង់អន្តរជាតិដទៃទៀត។

ការផ្តល់គ្រឿងលើកទឹកចិត្តទាំងនេះត្រូវចាប់អនុវត្តបន្ទាប់ពីគោលនយោបាយនេះត្រូវបានអនុម័តនិងរៀបចំនីតិវិធីប្រតិបត្តិប្រកបដោយស្តង់ដា (SOP) សម្រាប់ការគ្រប់គ្រងការស្រាវជ្រាវ។

លទ្ធភាពផ្តល់ការលើកទឹកចិត្តសម្រាប់ការខិតខំប្រឹងប្រែងរកចំណូលរបស់អ្នកស្រាវជ្រាវមានដូចជា៖

១. ការផ្តល់លាភការ និងប្រាក់ឧបត្ថម្ភផ្សេងៗតាមចំនួនគម្រោងស្រាវជ្រាវ និងថវិកាសម្រាប់លើកទឹកចិត្តដល់អ្នកស្រាវជ្រាវ ដោយផ្អែកលើការវាយតម្លៃលទ្ធផលការងាររបស់អ្នកស្រាវជ្រាវដែលបានចុះកិច្ចព្រមព្រៀងលទ្ធផល

២. ការវិនិយោគថវិកាដែលបានពីប្រភពចំណូលរបស់ ស.ភ.ភ.ព. ទៅលើសកម្មភាពអភិវឌ្ឍសមត្ថភាពបន្ថែមដល់អ្នកគ្រប់គ្រង អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេស ឱ្យបានចូលរួមដំណើរទស្សនកិច្ចសិក្សាស្រាវជ្រាវ សន្និសីទឬសិក្ខាសាលាក្នុងនិងក្រៅប្រទេស

៣. ការផ្តល់ថវិកាគាំទ្រដល់ការបោះពុម្ពអត្ថបទស្រាវជ្រាវ
៤. ការផ្តល់អាហារូបករណ៍បន្តការសិក្សាថ្នាក់បណ្ឌិត និងគាំទ្រដល់ការស្រាវជ្រាវថ្នាក់ក្រោយបរិញ្ញាបត្រ
៥. ការបង្កើតមូលនិធិសម្រាប់គាំទ្រដល់ការស្រាវជ្រាវ ការអភិវឌ្ឍជំនាញអាជីព និងផ្តល់រង្វាន់ជ័យលាភីសម្រាប់ការស្រាវជ្រាវ
៦. ការឧបត្ថម្ភ ឬការគាំពារសុខភាពគណៈគ្រប់គ្រងការស្រាវជ្រាវ អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេសគាំទ្រការស្រាវជ្រាវ និង
៧. ការរៀបចំផែនការវិនិយោគទៅលើការធ្វើពាណិជ្ជនីយកម្ម ឬបង្កើនការវិនិយោគចំពោះស្នាដៃស្រាវជ្រាវរបស់ខ្លួនសម្រាប់ជាប្រយោជន៍ដល់សង្គម។

## ៤. ជំរុញកំណើនផលិតភាពនៃការស្រាវជ្រាវ

### ៤.១. យន្តការគាំទ្រការវិនិយោគលើការស្រាវជ្រាវសម្រាប់កម្មវិធីមួយផលិតផលមួយ

ការស្រាវជ្រាវផលិតផលគឺជាដំណើរនៃការកំណត់ថា គំនិតអ្នកស្រាវជ្រាវចំពោះការបង្កើតផលិតផល ឬផ្តល់សេវាកម្មថ្មីអាចទទួលបានជោគជ័យតាមរបៀបល្អបំផុត និងលក់ផលិតផលដែលផលិតបានទាំងនោះ។ ទន្ទឹមនឹងនេះ ការស្រាវជ្រាវផលិតផលគឺជាដំណើរការស្រាវជ្រាវទីផ្សារដែលធ្វើឡើងដើម្បីទទួលបានព័ត៌មានអំពីលក្ខណៈដែលចង់បាន និងភាពជាក់លាក់នៃផលិតផលដែលអតិថិជនធំៗរំពឹងទុកជាចម្បងមុននឹងចេញលក់ និងវត្តមានផលិតផល។ ការវិនិយោគលើការស្រាវជ្រាវដោយប្រើប្រាស់ធនធានថវិកាផ្ទៃក្នុងរបស់គ្រឹះស្ថានគឺជាការធានានិរន្តរភាពនៃដំណើរការស្រាវជ្រាវ។ តារាងខាងក្រោមបង្ហាញពីគំរូនិងទំហំនៃការរៀបចំប្រភេទគម្រោងស្រាវជ្រាវសម្រាប់អនុវត្ត។

**តារាង១៤. គំរូនៃការរៀបចំប្រភេទនិងទំហំគម្រោងស្រាវជ្រាវសម្រាប់អនុវត្ត**

| ប្រភេទមូលនិធិ | ប្រភេទគម្រោងស្រាវជ្រាវ | ថវិកាប៉ាន់ស្មាន (លានរៀល) | រយៈពេល |
|---|---|---|---|
| ក | - ការផ្តល់ថវិកាសម្រាប់ការស្រាវជ្រាវលើកម្មវិធីសិក្សា ការបង្រៀន និងរៀន និងការវាយតម្លៃការសិក្សា<br>- ការស្រាវជ្រាវគោលនយោបាយ និងឧត្តមានុវត្តន៍ក្នុងវិស័យជំនាញ<br>- ការស្រាវជ្រាវប្រតិបត្តិផ្នែកស្វែមផ្សារភ្ជាប់នឹងវិស័យឧស្សាហកម្ម និង | - ក្រោម 20 លាន<br>- ក្រោម 10 លាន<br>- ក្រោម 40 លាន | - 1 ឆ្នាំ<br>- 1 ឆ្នាំ<br>- 2 ឆ្នាំ |

| | | | |
|---|---|---|---|
| | ការអប់រំឌីជីថល | | |
| ខ | - ថវិកាគាំទ្រការសរសេរនិក្ខេបបទសម្រាប់និស្សិតឆ្នើម<br>- ថវិកាគាំទ្រគម្រោងស្រាវជ្រាវ ឬនវានុវត្តន៍ រួមគ្នាដឹកនាំដោយនិស្សិត | - ក្រោម 6 លាន<br>- ក្រោម 8 លាន | - 1 ឆ្នាំ<br>- 1 ឆ្នាំ |
| គ | - ការប្រកួតប្រជែងស្នាដៃស្រាវស្រាវ | - លេខ 1 ៖ 40,000,000.00<br>- លេខ 2 ៖ 20,000,000.00<br>- លេខ 3 ៖ 12,000,000.00 | - 1 ឆ្នាំ |

### ៤.២. យន្តការគ្រប់គ្រង និងលើកកម្ពស់គុណភាពស្រាវជ្រាវ

#### ៤.២.១. ដំណើរការជ្រើសរើសគម្រោងស្រាវជ្រាវ

ស.ភ.ភ.ព. អនុវត្តគម្រោងស្រាវជ្រាវនានាដោយប្រើថវិកាផ្ទាល់ខ្លួន និងទទួលយកជំនួយអភិវឌ្ឍសម្រាប់ធ្វើសកម្មភាពនានាទាក់ទងនឹងការស្រាវជ្រាវ។ នីតិវិធីគ្រប់គ្រងជំនួយស្រាវជ្រាវជួយធានាចំពោះម្ចាស់ជំនួយថា សកម្មភាពស្រាវជ្រាវប្រាកដជាត្រូវបានធ្វើស្របតាមវិសាលភាពការងារ ហើយការចំណាយនឹងមានភាពត្រឹមត្រូវតាមគោលការណ៍និងលក្ខខណ្ឌរបស់ម្ចាស់ជំនួយ ដែលត្រូវគ្នានឹងគោលនយោបាយ ស.ភ.ភ.ព.។ អនុគណៈកម្មការប្រឹក្សាយោបល់មានតួនាទីយ៉ាងសំខាន់ក្នុងការជ្រើសរើសគម្រោងស្រាវជ្រាវ ត្រួតពិនិត្យ និងផ្តល់ជំនួយបច្ចេកទេសដល់បុគ្គលិកអប់រំ ស.ភ.ភ.ព. ក្នុងការអភិវឌ្ឍនិងអនុវត្តគម្រោងស្រាវជ្រាវ។ ក្នុងនោះដែរ មន្ត្រីការិយាល័យតាមដាននិងវាយតម្លៃគម្រោងស្រាវជ្រាវម្នាក់នឹងធ្វើជាជនបង្គោលក្នុងការធានាចំពោះអ្នកពាក់ព័ន្ធសំខាន់ៗថា ការរំពឹងទុករបស់ពួកគេនឹងត្រូវបានបំពេញតាំងពីពេលចាប់ផ្តើមដល់ចុងបញ្ចប់នៃគម្រោង។

#### ៤.២.២. ថវិកាស្រាវជ្រាវ

ថវិកាគម្រោងត្រូវបានគ្រប់គ្រងតាមក្របខណ្ឌការងារនេះ ដើម្បីកាត់បន្ថយហានិភ័យនៃការខាតបង់ផ្នែកហិរញ្ញវត្ថុនិងការខូចកេរ្តិ៍ឈ្មោះ ស.ភ.ភ.ព. តាមរយៈសកម្មភាពស្រាវជ្រាវផ្សេងៗ។ ការគូសបញ្ជាក់នូវទំនួលខុសត្រូវសំខាន់ៗធានាបាននូវតម្លាភាពនិងគណនេយ្យភាពក្នុងការប្រើមូលនិធិស្រាវជ្រាវ ចំណាត់ការលើថវិកាមិនចំណាយ ការចំណាយលើសកំណត់ និងថ្លៃចំណាយផ្សេងៗ (overheads)។ ហិរញ្ញប្បទានស្រាវជ្រាវនៅ ស.ភ.ភ.ព ត្រូវបានបែងចែកជាបួនប្រភេទគឺ៖

ក. ហិរញ្ញប្បទានស្រាវជ្រាវ ស.ភ.ភ.ព.

ហិរញ្ញប្បទានស្រាវជ្រាវគឺជាថវិកាសម្រាប់វិនិយោគលើសកម្មភាពនានា ដែលទាក់ទងនឹងការស្រាវជ្រាវដើម្បីអភិវឌ្ឍសមត្ថភាពជូនបុគ្គលិកស្រាវជ្រាវ ដើម្បីឱ្យធ្វើការស្រាវជ្រាវប្រកបដោយគុណភាព និងបោះពុម្ពផ្សាយ។ ភាគច្រើននៃថវិកានេះបានមកពីថ្លៃសិក្សា និងប្រភពចំណូលឯទៀតរបស់ ស.ភ.ភ.ព.។ ថវិកានេះប្រើប្រាស់សម្រាប់ការស្រាវជ្រាវ និងការចូលរួមក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និសីទនានាសម្រាប់បង្កើនសមត្ថភាពបុគ្គលិកស្រាវជ្រាវក្នុងការបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីស្រាវជ្រាវអន្តរជាតិ។

ខ. ជំនួយស្រាវជ្រាវនិងប្រាក់កម្ចី

ជំនួយស្រាវជ្រាវនិងប្រាក់កម្ចីសំដៅលើថវិកាស្រាវជ្រាវដែលផ្តល់ដោយក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នរដ្ឋឯទៀត និងដៃគូអភិវឌ្ឍនានាដូចជា ធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ីជាដើម ដើម្បីលើកកម្ពស់វប្បធម៌ស្រាវជ្រាវ របកគំហើញថ្មីៗ និង នវានុវត្តន៍នៅ ស.ភ.ភ.ព.។ ស.ភ.ភ.ព. គ្រប់គ្រងជំនួយដោយផ្ទាល់ស្របតាមគោលនយោបាយរបស់ខ្លួន។ ថវិកានេះត្រូវបានផ្តល់ជាជំនួយចំពោះស្ថាប័នជាជាងបុគ្គលអ្នកស្រាវជ្រាវ។

គ. ហិរញ្ញប្បទាននិងអាហារូបករណ៍ស្រាវជ្រាវ

ហិរញ្ញប្បទាននិងអាហារូបករណ៍ស្រាវជ្រាវសំដៅលើហិរញ្ញប្បទាននិងកញ្ចប់ថវិកានានា ដែលផ្តល់ដោយស្ថាប័នជាតិឬអង្គការអន្តរជាតិ ដើម្បីផ្តល់ថវិកាដល់គម្រោងស្រាវជ្រាវដែលអនុវត្តដោយបុគ្គលិកស្រាវជ្រាវរៀងៗខ្លួនតែម្តង។ អ្នកស្រាវជ្រាវ ស.ភ.ភ.ព. អាចដាក់ពាក្យសុំហិរញ្ញប្បទានស្រាវជ្រាវឬអាហារូបករណ៍ស្រាវជ្រាវខាងក្រៅ និងគ្រប់គ្រងហិរញ្ញប្បទាននោះដោយខ្លួនឯង ប្រសិនបើប្រើគណនីផ្ទាល់ខ្លួន។

ឃ. សេវាផ្តល់ប្រឹក្សាយោបល់

សេវាប្រឹក្សាយោបល់សំដៅលើសេវាដែលអ្នកជំនាញស្រាវជ្រាវ ស.ភ.ភ.ព. អាចផ្តល់ការប្រឹក្សាយោបល់ជូនស្ថាប័នជាតិ អង្គការមិនមែនរដ្ឋាភិបាល ឬអង្គការអន្តរជាតិ ក្នុងការអនុវត្តគម្រោងស្រាវជ្រាវណាមួយជាលក្ខណៈបុគ្គលរៀងៗខ្លួន ដោយស្ថិតឬមិនស្ថិតក្រោមការគ្រប់គ្រងរបស់ ស.ភ.ភ.ព. ក៏បាន។

បុគ្គលិកអប់រំ ស.ភ.ភ.ព. អាចដាក់ពាក្យសុំហិរញ្ញប្បទាននិងអាហារូបករណ៍ស្រាវជ្រាវ និងការប្រឹក្សាយោបល់ ទោះក្នុងនាមជាផ្នែកមួយនៃស្ថាប័នក្តី ឬជាបុគ្គលអ្នកស្រាវជ្រាវខ្លួនឯងក្តី។ ស.ភ.ភ.ព. នឹងចេញលិខិតគាំទ្រតាមការស្នើសុំធ្វើការស្រាវជ្រាវ និងផ្តល់ការគាំទ្រ ដើម្បីជួយឱ្យទទួលបានមូលនិធិ។ អ្នកដាក់ពាក្យសុំ ដែលទទួលបានហិរញ្ញប្បទានស្រាវជ្រាវ ត្រូវបង់វិភាគទានជូនសាកលវិទ្យាល័យ ដោយមិនគិតពីទំហំនៃជំនួយនោះទេ។ ថ្លៃសេវានេះនឹងស្ថិតនៅចន្លោះពី ៥% ទៅ ១០% នៃថវិកាសរុបដែលទទួលបានពី

ស្ថាប័នផ្តល់មូលនិធិ។ ដើម្បីឱ្យមានតម្លាភាព ស.ភ.ភ.ព. នឹងអនុញ្ញាតឱ្យដៃគូស្រាវជ្រាវធ្វើសវនកម្មពីខាងក្រៅលើការចំណាយរបស់គម្រោងតាមការស្នើសុំ។

មជ្ឈមណ្ឌលគាំទ្រ គ្រប់គ្រងការស្រាវជ្រាវ និងនវានុវត្តន៍ ជួយជ្រោមជ្រែង និងត្រួតពិនិត្យគុណភាព និងបច្ចេកទេសស្រាវជ្រាវរបស់អ្នកទទួលហិរញ្ញប្បទានម្នាក់ៗ។ អ្នកស្រាវជ្រាវនឹងទទួលបានសេវាគាំទ្រ និងជ្រោមជ្រែងពីការិយាល័យទាំង៣នៃមជ្ឈមណ្ឌលគាំទ្រ គ្រប់គ្រងការស្រាវជ្រាវ និងនវានុវត្តន៍។ តួនាទី និងការទទួលខុសត្រូវដូចបានចែងសម្រាប់ (១) ការិយាល័យតាមដាន និងវាយតម្លៃគម្រោងស្រាវជ្រាវ (២) ការិយាល័យកម្មសិទ្ធិបញ្ញានិងនវានុវត្តន៍ និង (៣) ការិយាល័យបោះពុម្ពផ្សាយនិងគាំទ្រទស្សនាវដ្តីវិទ្យាសាស្ត្រ។ រីឯការិយាល័យគណនេយ្យជ្រោមជ្រែងនិងត្រួតពិនិត្យឯកសារហិរញ្ញវត្ថុសម្រាប់ការទូទាត់និងការធ្វើសវនកម្ម។

### ៤.២.៣. យន្តការគ្រប់គ្រង និងលើកកម្ពស់គុណភាពស្រាវជ្រាវ

មជ្ឈមណ្ឌលគាំទ្រការស្រាវជ្រាវនិងនវានុវត្តន៍ត្រូវសហការជាមួយដេប៉ាតឺម៉ង់ មហាវិទ្យាល័យ វិទ្យាស្ថាន និងមជ្ឈមណ្ឌលនីមួយៗក្នុងការពិនិត្យគម្រោងស្រាវជ្រាវនានា ដើម្បីឱ្យដឹងថា តើគម្រោងទាំងនោះមានប្រយោជន៍ និងមានផលជះលើដំណោះស្រាយបញ្ហាសង្គម ដូចក្នុងគំនូសបំព្រួញខាងក្រោមនេះដែរឬទេ។

ប្រព័ន្ធស្រាវជ្រាវឌីជីថល ឬបណ្ណសារឌីជីថល (Digital Research Output) នឹងជួយដល់ការផ្សព្វផ្សាយស្នាដៃស្រាវជ្រាវ និងលើកស្ទួយផលប្រយោជន៍ និងផលជះនៃស្នាដៃស្រាវជ្រាវរបស់បុគ្គលិកអប់រំ ស.ភ.ភ.ព. ឱ្យកាន់តែទូលំទូលាយ។ ស្នាដៃស្រាវជ្រាវទាំងអស់នឹងត្រូវបានបោះពុម្ពនិងរក្សាទុកក្នុងបណ្ណសារឌីជីថលនេះដើម្បីបង្កភាពងាយស្រួលដល់បុគ្គលិកអប់រំ ស.ភ.ភ.ព. ក្នុងការចែករំលែកលទ្ធផលស្រាវជ្រាវរបស់ខ្លួនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ និងជាមួយស្ថាប័នដទៃ។ ឯកសារស្រាវជ្រាវអនទ្បាញមាន៖ សៀវភៅ ជំពូកសៀវភៅ (Book Chapters) ឯកសារពិភាក្សា អត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្តី អត្ថបទបោះពុម្ពផ្សាយក្នុងសន្និសីទ ឯកសារបច្ចេកទេស និងរបាយការណ៍ផ្សេងៗទៀត។ មជ្ឈមណ្ឌលគាំទ្រការស្រាវជ្រាវ និងនវានុវត្តន៍ នឹងគ្រប់គ្រងកម្មសិទ្ធិបញ្ញារបស់បុគ្គលិកស្រាវជ្រាវដោយធានាថា នៅពេលដែលស្នាដៃរបស់ពួកគេត្រូវបានរក្សាទុកក្នុងប័ណ្ណសារនោះ ការរក្សាសិទ្ធិតឹងរឹងចំពោះស្នាដៃនីមួយៗនឹងត្រូវបានគាំទ្រ។ គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ ស.ភ.ភ.ព. ត្រូវជួយបុគ្គលិកស្រាវជ្រាវក្នុងការចរចាអំពីបញ្ហាទាំងនេះ។

មជ្ឈមណ្ឌលគាំទ្រការស្រាវជ្រាវ និងនវានុវត្តន៍នឹងប្រើប្រាស់បណ្ណសារឌីជីថល (Digital Research Output) ដើម្បីវាយតម្លៃផលប្រយោជន៍និងផលជះនៃស្នាដៃស្រាវជ្រាវរបស់បុគ្គលិកស្រាវជ្រាវ ស.ភ.ភ.ព.។ ក្រៅពីផលប្រយោជន៍នៃស្នាដៃស្រាវជ្រាវប្រកបដោយស្តង់ដាដូចជាការបោះពុម្ពក្នុងទស្សនាវដ្តីស្រាវជ្រាវនិងសៀវភៅ ប្រព័ន្ធនេះនឹងវាយតម្លៃស្នាដៃច្នៃប្រឌិតនានា វីដេអូ ប្លក់ (blogs) និងប្រព័ន្ធផ្សព្វផ្សាយដ៏ទៃទៀត ព្រមទាំងការស្រាវជ្រាវផ្នែកអនុវត្តដូចជារបាយការណ៍បច្ចេកទេស និងសេចក្តីសង្ខេបគោលនយោបាយជាដើម។ ចំនួនគម្រោងស្រាវជ្រាវ ដែលបានទទួលហិរញ្ញប្បទានស្រាវជ្រាវ ហើយអនុវត្តបានជោគជ័យ និង

បរិមាណប្រាក់ចំណូលដែលទទួលបាន ក៏នឹងត្រូវបានបញ្ចូលក្នុងការវាយតម្លៃបែបបរិមាណវិស័យផងដែរ។ ការិយាល័យស្រាវជ្រាវនឹងប្រើប្រាស់ទិន្នន័យក្នុងប័ណ្ណសារនេះសម្រាប់វាយតម្លៃដើម្បីផ្តល់ក្រឌីត ក៏ដូចជាអត្ថប្រយោជន៍នានាជូនអ្នកស្រាវជ្រាវដែលមានស្នាដៃល្អ។ អត្ថប្រយោជន៍ទាំងនេះអាចជា ការតម្លើងឋានៈសាស្ត្រាចារ្យ ការផ្តល់ថវិកា ការផ្តល់វិញ្ញាបនប័ត្រកិត្តិយស ឬប័ណ្ណសរសើរផ្សេងៗ។

**រូបភាពទី៧. របៀបវាស់វែងលទ្ធផលគម្រោងស្រាវជ្រាវ**




### ៤.២.៤. ប្រព័ន្ធតាមដាននិងវាយតម្លៃ

ដើម្បីតាមដាននិងវាយតម្លៃការងារស្រាវជ្រាវ ស.ភ.ភ.ព. បានបង្កើតឯកសារគតិយុត្តដូចខាងក្រោម៖

**តារាង១៥. ប្រភេទនៃការតាមដាននិងវាយតម្លៃការងារស្រាវជ្រាវ ស.ភ.ភ.ព.**

| ប្រភេទ | ពិពណ៌នា |
|---|---|
| គោលនយោបាយសម្រាប់គ្រប់គ្រងនិងជំរុញការស្រាវជ្រាវ និងនវានុវត្តន៍ | • ការស្រាវជ្រាវនិងនវានុវត្តន៍ដើរតួយ៉ាងសំខាន់ក្នុងការជំរុញកំណើន និងការបង្កើតការងារប្រកបដោយចីរភាពនិងភាពឆ្លាតវៃ តាមរយៈការផលិតចំណេះដឹងថ្មីៗ។ ការស្រាវជ្រាវគឺជាស្នូលក្នុងការអភិវឌ្ឍផលិតផល ដំណើរការ និងសេវាកម្មថ្មី ដោយមានភាពច្នៃប្រឌិត ដែលអាចទទួលបានផលិតភាពខ្ពស់ និងការប្រកួតប្រជែងក្នុងឧស្សាហកម្ម។<br>• គោលនយោបាយ និងការគ្រប់គ្រងមានសារសំខាន់ក្នុងការការពារផលប្រយោជន៍គ្រប់ភាគីពាក់ព័ន្ធ។ |
| គោលការណ៍ណែនាំសម្រាប់គ្រប់គ្រងហិរញ្ញប្បទានស្រាវជ្រាវ | ការគ្រប់គ្រងហិរញ្ញវត្ថុគឺជាការរៀបចំផែនការយុទ្ធសាស្ត្រ ការរៀបចំ ដឹកនាំ គ្រប់គ្រងកិច្ចការហិរញ្ញវត្ថុនៅ ស.ភ.ភ.ព. និង ការអនុវត្តគោលការណ៍គ្រប់គ្រងទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ របស់ស.ភ.ភ.ព. ហើយក៏មាននាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងសារពើពន្ធផងដែរ។ |

| | |
|---|---|
| បង្កើតបទដ្ឋានប្រតិបត្តិនៃនីតិវិធីគោលនយោបាយស្រាវជ្រាវ (SOP) | បទដ្ឋានប្រតិបត្តិនៃនីតិវិធីគោលនយោបាយស្រាវជ្រាវ (SOPs) មានការណែនាំលម្អិតដើម្បីកត់ត្រាប្រតិបត្តិការ ដំណើរការ និងការអនុវត្តតាមទម្លាប់ដែលបានអនុវត្តក្នុងការស្រាវជ្រាវ។ |
| អនុវត្តនីតិវិធីក្រមសីលធម៌មនុស្សសម្រាប់ការស្រាវជ្រាវ | ធ្វើការស្រាវជ្រាវដោយមានទំនួលខុសត្រូវជាពិសេស ចំពោះអ្នកចូលរួមសហសេវិក និយោជក អ្នកផ្តល់មូលនិធិ និងសង្គម។ សុចរិតភាពនៃការស្រាវជ្រាវៈ ធ្វើការស្រាវជ្រាវតាមវិធីដែលផ្តល់ទំនុកចិត្តលើលទ្ធផល អ្នកស្រាវជ្រាវ និងសហគមន៍ស្រាវជ្រាវ។ សុចរិតភាពនៃការស្រាវជ្រាវគឺជាស្នូលនៃសកម្មភាពស្រាវជ្រាវនិងឧត្តមភាព ឬជាមូលដ្ឋានសម្រាប់អ្នកស្រាវជ្រាវជឿជាក់គ្នាទៅវិញទៅមក ក៏ដូចជាកំណត់ត្រាស្រាវជ្រាវ និងជាមូលដ្ឋាននៃការជឿទុកចិត្តរបស់សង្គមលើភស្តុតាង និងជំនាញស្រាវជ្រាវ។ |

### ៤.២.៥. ការរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានអ្នកស្រាវជ្រាវ

ព័ត៌មានបឋម ដែលអ្នកស្រាវជ្រាវ ស.ភ.ភ.ព. ត្រូវសហការផ្តល់ជូន មានពីរផ្នែកដូចខាងក្រោម។

**តារាង១៦. ទិន្នន័យអ្នកស្រាវជ្រាវដែលត្រូវប្រមូល**

| |
|---|
| **ទិន្នន័យអ្នកស្រាវជ្រាវ ដែលគ្រឹះស្ថានត្រូវធ្វើការប្រមូលប្រចាំត្រីមាស** |
| (១) បញ្ជីឈ្មោះ ភេទ សញ្ញាបត្រ និងអង្គភាពអ្នកស្រាវជ្រាវ |
| (២) ចំនួនគម្រោងស្រាវជ្រាវដែលបាននិងកំពុងដឹកនាំអនុវត្ត |
| (៣) ចំនួនអត្ថបទ សៀវភៅ ឬឯកសារពាក់ព័ន្ធផ្សេងៗដែលបានបោះពុម្ពផ្សាយ |
| (៤) ឯកសារគាំទ្រប៉ាតង់ផ្សេងៗពីអ្នកស្រាវជ្រាវ និងកត្តាផលជះ (Impact Factor) ប្រសិនបើមាន |
| (៥) លទ្ធផលស្រាវជ្រាវជាផលិតផលគំរូ |
| (៦) ប្រាក់ចំណូលពីការស្រាវជ្រាវ ... ជាដើម។ |
| **ទិន្នន័យគម្រោងស្រាវជ្រាវ ដែលគ្រឹះស្ថានត្រូវធ្វើការប្រមូលរៀងរាល់ឆ្នាំ** |
| (១) ចំនួនគម្រោងស្រាវជ្រាវដែលបានអនុវត្ត |
| (២) ចំនួនគម្រោងស្រាវជ្រាវឆ្លើយតបទៅនឹងវិស័យអាទិភាព ឬឧត្តមភាពរបស់គ្រឹះស្ថាន |
| (៣) អ្នកដឹកនាំគម្រោងស្រាវជ្រាវរបស់មហាវិទ្យាល័យ ឬមជ្ឈមណ្ឌលស្រាវជ្រាវ ឬវិទ្យាស្ថានស្រាវជ្រាវ និងនវានុវត្តន៍ |
| (៤) ចំនួនអត្ថបទ សៀវភៅ ឬឯកសារពាក់ព័ន្ធផ្សេងៗដែលបានបោះពុម្ពផ្សាយ |
| (៤) ឯកសារគាំទ្រប៉ាតង់ផ្សេងៗ និងកត្តាផលជះ (Impact Factor) ប្រសិនបើមាន |
| (៥) ចំនួនផលិតផលគំរូ (Prototype) នៃលទ្ធផលស្រាវជ្រាវរបស់គ្រឹះស្ថាន និង |
| (៦) ប្រាក់ចំណូលពីការស្រាវជ្រាវជាដើម។ |

## ៤.២.៦. ការពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តគម្រោងស្រាវជ្រាវនៅគ្រឹះស្ថាន

ការិយាល័យតាមដាននិងវាយតម្លៃគម្រោងស្រាវជ្រាវមានតួនាទីក្នុងការប្រមូលវឌ្ឍនភាព និងវាយតម្លៃលើលទ្ធផលនៃការអនុវត្តគម្រោងស្រាវជ្រាវ។ ការត្រួតពិនិត្យត្រូវធ្វើឡើងនៅពេលចាប់ផ្តើមគម្រោងស្រាវជ្រាវដើម្បីប្រមូលទិន្នន័យនិងព័ត៌មានតាមសូចនាករសំខាន់ៗនៃការអនុវត្ត (Key Performance Indicators) ដែលបានកំណត់រវាងអ្នកទទួលគម្រោងនិងម្ចាស់ជំនួយ។ ជាងនេះទៅទៀត ឯកសារចង្អុលបង្ហាញពីរបៀបលំហូរទិន្នន័យតាមច្រកតែមួយក្រោមការគ្រប់គ្រងរបស់ការិយាល័យតាមដាននិងវាយតម្លៃគម្រោងស្រាវជ្រាវ។ ការវាយតម្លៃបង្ហាញពីធាតុផ្សំមួយចំនួននៃប្រព័ន្ធ M&E នៅ ស.ភ.ភ.ព. និងនីតិវិធីអនុវត្តការងារ។ ការវាយតម្លៃក៏បង្ហាញពីសូចនាករដែលត្រូវបានភ្ជាប់ដោយផ្ទាល់ទៅនឹងគោលបំណងនៅក្នុងផែនការយុទ្ធសាស្ត្រផងដែរ។ ប្រព័ន្ធតាមដាននិងវាយតម្លៃ (M&E System) នឹងត្រូវបានបង្កើតឡើងដើម្បីប្រមូលវឌ្ឍនភាពតាមទម្រង់ដែលបានរៀបចំរៀងរាល់បីខែម្តង (Q1 Q2 Q3 និងQ4)។ ការិយាល័យតាមដាននិងវាយតម្លៃគម្រោងស្រាវជ្រាវ ការិយាល័យកម្មសិទ្ធិបញ្ញានិងនវានុវត្តន៍ និង ការិយាល័យបោះពុម្ពផ្សាយនិងគាំទ្រទស្សនាវដ្តីវិទ្យាសាស្ត្រ ត្រូវធ្វើការជាមួយអនុគណៈកម្មការគ្រប់គ្រងកិច្ចការស្រាវជ្រាវ ដែលមានអនុគណៈកម្មការក្រមសីលធម៌ស្រាវជ្រាវ អនុគណៈកម្មការប្រឹក្សាយោបល់ ត្រូវជួបប្រជុំរៀងរាល់ខែធ្នូដើម្បីវាយតម្លៃលទ្ធផលតាមសូចនាករសំខាន់ៗនៃការអនុវត្ត (Key Performance Indicators)។ សមត្ថភាពផលិតស្នាដៃស្រាវជ្រាវរបស់ស្ថាប័ននឹងត្រូវបានវាយតម្លៃតាមលក្ខខណ្ឌក្នុងតារាងខាងក្រោម។

**តារាងទី១៧. របៀបវាយតម្លៃសមត្ថភាពផលិតស្នាដៃស្រាវជ្រាវ**

| ការប្រៀបធៀប | លទ្ធផលនៃការប្រៀបធៀប | សមត្ថភាពផលិតស្នាដៃស្រាវជ្រាវ |
|---|---|---|
| ចំនួនសមិទ្ធផលស្រាវជ្រាវដែលមានធៀបនឹងចំនួនអ្នកស្រាវជ្រាវសរុប | > 1 | ផលិតភាពមានកម្រិតល្អ |
| | = 1 | ផលិតភាពមានកម្រិតមធ្យម |
| | < 1 | ផលិតភាពមានកម្រិតទាប |

កិច្ចការធំៗ ដែលអ្នកស្រាវជ្រាវត្រូវធ្វើ គឺការរៀបចំកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងការចូលរួមអភិវឌ្ឍសមត្ថភាពជាប្រចាំ។ ចំណែកគណៈកម្មការគ្រប់គ្រងការស្រាវជ្រាវនិងនវានុវត្តន៍មានតួនាទីផ្តល់ការគាំទ្រ និងអនុវត្តកិច្ចការដូចខាងក្រោម៖

- រៀបចំផែនការវិនិយោគលើការស្រាវជ្រាវរយៈពេលមធ្យម និងរយៈពេលវែង
- ជ្រើសរើសអ្នកស្រាវជ្រាវដែលមានសមត្ថភាពក្នុងនិងក្រៅគ្រឹះស្ថានមកគាំទ្រការស្រាវជ្រាវក្នុងគ្រឹះស្ថាន
- វាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំរបស់អ្នកស្រាវជ្រាវ
- ផ្តល់ការលើកទឹកចិត្តជាប្រាក់ឧបត្ថម្ភប្រចាំខែបន្ថែម ដោយផ្អែកលើសូចនាករផលសម្រេច ឬការតម្លើងឋានៈវិជ្ជាជីវៈ និង

- ផ្តល់ឱកាសអភិវឌ្ឍសមត្ថភាពជាប្រចាំ។

### ៤.២.៧. កសាងអន្តរកម្មរវាងគ្រឹះស្ថាន វិស័យឯកជនឬឧស្សាហកម្ម និងសហគមន៍

កិច្ចសហប្រតិបត្តិការរវាងឧស្សាហកម្ម និង ស.ភ.ភ.ព អាចជំរុញការច្នៃប្រឌិត និងការរីកចម្រើនក្នុងវិស័យបច្ចេកវិទ្យា។ ភាពជាដៃគូក្នុងឧស្សាហកម្មគឺជាឧបករណ៍មួយក្នុងការជំរុញការស្រាវជ្រាវ និងបង្កើតកម្លាំងពលកម្មជំនាញ។ កិច្ចសហការកាន់តែច្រើនអាចជួយជំរុញបានកាន់តែខ្លាំងនិងកាន់តែឆាប់រហ័សក្នុងការផ្តល់ឱ្យកាសសិក្សាស្រាវជ្រាវ បង្កើតផលិតផលថ្មី និងអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ការរៀននិងបង្រៀន។ ដោយសង្កត់ធ្ងន់លើកិច្ចសហការរវាង ស.ភ.ភ.ព វិស័យឯកជនឬឧស្សាហកម្ម និងសហគមន៍ បុគ្គលិកអប់រំ ស.ភ.ភ.ព អាចកំណត់យុគ្គសម័យថ្មីនៃការអប់រំឧត្តមសិក្សានេះថាជាការរីកចម្រើនតាមរយៈកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជនឬឧស្សាហកម្ម និងសហគមន៍។ ដើម្បីបង្កើនអន្តរកម្មរវាងគ្រឹះស្ថាន វិស័យឯកជនឬឧស្សាហកម្ម និងសហគមន៍ ស.ភ.ភ.ព កំពុងដំណើរការ និងកំពុងបង្កើតៈ (១) មជ្ឈមណ្ឌលផលិតកម្មឌីជីថលកម្ពុជា-ជប៉ុន (CJDM), (២) មជ្ឈមណ្ឌលជាតិបណ្តុះធុរកិច្ចថ្មីនៃកម្ពុជា, (៣) មជ្ឈមណ្ឌលសហប្រតិបត្តិការសាកលវិទ្យាល័យ-សហគ្រាស (UICC), និង (៤) មជ្ឈមណ្ឌលឌីជីថល និងបច្ចេកវិទ្យាព័ត៌មាន (DITC)។

**ក.** មជ្ឈមណ្ឌលផលិតកម្មឌីជីថលកម្ពុជា-ជប៉ុន (CJDM) មានការិយាល័យចំនួន៣ គឺៈ (១) ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវផលិតកម្មឌីជីថល, (២) ការិយាល័យសេវាកម្មផលិតកម្មឌីជីថល និង (៣) ការិយាល័យទំនាក់ទំនងនិងទីផ្សារ។ តួនាទីរួមរបស់មជ្ឈមណ្ឌលគឺធ្វើការស្រាវជ្រាវទាក់ទងនឹងផលិតកម្មឌីជីថលដូចខាងក្រោមៈ

- ផលិតកម្មឌីជីថលដើម្បីច្នៃប្រឌិតពុម្ពគំរូថ្មីៗសម្រាប់ឧស្សាហកម្មផលិតកម្ម
- បណ្តុះបណ្តាលនិងស្រាវជ្រាវផលិតកម្មឌីជីថល ដើម្បីច្នៃប្រឌិតពុម្ពគំរូថ្មីៗ សម្រាប់ឧស្សាហកម្ម និងអាជីវកម្ម។
- អនុវត្តជាក់ស្តែងនូវរចនាម៉ូឌែល ដែលទទួលបានពីការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវផលិតកម្មឌីជីថល។ និង
- បង្កើត រៀបចំ និងផ្សព្វផ្សាយគម្រោងស្រាវជ្រាវ និង វគ្គបណ្តុះបណ្តាល និងរៀបចំព្រឹត្តិការណ៍ផ្សេងៗ។

**ខ.** មជ្ឈមណ្ឌលជាតិបណ្តុះធុរកិច្ចថ្មីនៃកម្ពុជាមានការិយាល័យ ០៣ គឺៈ (១) ការិយាល័យរដ្ឋបាលទំនាក់ទំនង និងទីផ្សារ, (២) ការិយាល័យបណ្តុះធុរកិច្ចថ្មី និងអភិវឌ្ឍន៍អាជីវកម្ម, និង (៣) ការិយាល័យបណ្តុះបណ្តាលធនធានមនុស្សនិងស្រាវជ្រាវ។ មជ្ឈមណ្ឌលនេះមានភារកិច្ចដូចតទៅៈ

- បង្កើត រៀបចំ និងផ្សព្វផ្សាយគម្រោងស្រាវជ្រាវនិងវគ្គបណ្តុះបណ្តាល និងរៀបចំកម្មវិធីឬព្រឹត្តិការណ៍ផ្សេងៗដែលទាក់ទងនឹងបច្ចេកវិទ្យា និងធុរកិច្ចថ្មី

- ស្រាវជ្រាវ រៀបចំផែនការ និងអនុវត្តគំនិតផ្តួចផ្តើមទីផ្សារគោលដៅថ្មី និងស្រាវជ្រាវបង្កើតគំរូអាជីវកម្ម ឬបច្ចេកវិទ្យាសម្រាប់ជួយជំរុញធុរកិច្ចថ្មី
- ផ្តល់ការប្រឹក្សាយោបល់ និងផ្តល់ដំណោះស្រាយក្នុងការបង្កើតធុរកិច្ចឬអាជីកម្មថ្មីដោយប្រើបច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មាន
- ស្រាវជ្រាវពីតម្រូវការទីផ្សារធនធានមនុស្សផ្នែកធុរកិច្ច និង បច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន និង
- បង្កើត រៀបចំ និងគ្រប់គ្រងវគ្គបណ្តុះបណ្តាលលើផ្នែកធុរកិច្ចថ្មី និងបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មានស្រាវជ្រាវ និងបង្កើតគំរូអាជីវកម្ម ឬបច្ចេកវិទ្យាសម្រាប់ជួយជំរុញធុរកិច្ចថ្មី។

គ. មជ្ឈមណ្ឌលសហប្រតិបត្តិការសាកលវិទ្យាល័យ-សហគ្រាស (UICC) មានការិយាល័យចំនួន ៤ គឺ៖ (១) ការិយាល័យផ្សព្វផ្សាយធុរកិច្ចនិងផ្សារភ្ជាប់សហគ្រាស, (២) ការិយាល័យប្រកួតប្រជែងអាជីវកម្ម និងវេទិកាសហគ្រាស, (៣) ការិយាល័យទីផ្សារនិងវិនិយោគ, និង (៤) ការិយាល័យរៀបចំព្រឹត្តិការណ៍និងអន្តេវាសិកដ្ឋាន។ មជ្ឈមណ្ឌលនេះមានភារកិច្ចដូចតទៅ៖

- សិក្សាស្វែងយល់ និងពិនិត្យសហគ្រាសដែលមានសក្តានុពលផ្សារភ្ជាប់នឹងសហគ្រាស និងរៀបចំវេទិកាលើកកម្ពស់សហគ្រិនថ្មើម និងទាក់ទងចរចារជាមួយសហគ្រាស។
- ផ្តល់ប្រឹក្សាយោបល់អាជីវកម្មទាក់ទងសហគ្រាសដៃគូនិងមិនមែនដៃគូ ដើម្បីឧបត្ថមកម្មវិធី ទីផ្សារ ពង្រីកទីផ្សារ និងនិវានុវត្តន៍។
- សម្របសម្រួលទីតាំងផ្សព្វផ្សាយពាណិជ្ជកម្ម និងដាក់ស្តង់ផ្សព្វផ្សាយក្នុងទីតាំងសាកលវិទ្យាល័យ និងសម្របសម្រួលសហគ្រិនភាព និងការវិនិយោគ។
- រៀបចំយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍនិរន្តរភាពអាជីវកម្ម និងផ្តល់សិទ្ធិចែកចាយអាជីវកម្ម។
- រៀបចំប្រព័ន្ធបច្ចេកវិទ្យា សំឡេង និងផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថល និងបណ្តាញសង្គម។

ឃ. មជ្ឈមណ្ឌលឌីជីថល និងបច្ចេកវិទ្យាព័ត៌មាន (DITC) មានការិយាល័យចំនួន ៣ គឺ៖ (១) ការិយាល័យហេដ្ឋារចនាសម្ព័ន្ធបណ្តាញនិងសន្តិសុខព័ត៌មានវិទ្យា, (២) ការិយាល័យបណ្តុះបណ្តាលបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន (ICT) និងអភិវឌ្ឍន៍កម្មវិធី, និង (៣) ការិយាល័យគាំទ្រនិងសិក្សាធិការសាយប៊ើរ។ មជ្ឈមណ្ឌលនេះមានភារកិច្ចដូចតទៅ៖

- រៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្តាញមេក្នុងសាកលវិទ្យាល័យ ដោយភ្ជាប់ពីមជ្ឈមណ្ឌលទិន្នន័យរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញមណ្ឌល១ ទៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញមណ្ឌល២ វិទ្យាស្ថានភាសាបរទេស បណ្ណាល័យ មហាវិទ្យាល័យ និងការិយាល័យ ព្រមទាំងមជ្ឈមណ្ឌលផ្សេងៗទៅតាមតម្រូវការ និងភាពជាក់ស្តែង។ ផ្តល់វេទិកាបច្ចេកវិទ្យាសម្រាប់ប្រព័ន្ធគ្រប់គ្រងទាំងអស់របស់សាកលវិទ្យាល័យ និងផ្តល់នូវសេវាអ៊ីនទ្រើណិតនិងអ៊ីនធើណិតសម្រាប់គាំទ្រដល់ការបង្រៀន ការរៀន និងការស្រាវជ្រាវរបស់សាកលវិទ្យាល័យ

- ផ្តល់សេវាលើការអភិវឌ្ឍកម្មវិធីសម្រាប់លក់ឱ្យក្រុមហ៊ុន ដែលជាដៃគូរបស់សាកលវិទ្យាល័យ
- ផ្តល់ការថែរក្សា និងអភិវឌ្ឍវេបសាយធ៍ អ៊ីមែល និងប្រព័ន្ធគាំទ្រការបង្រៀន ការរៀន និងស្រាវជ្រាវ របស់សាកលវិទ្យាល័យ និង
- គាំទ្រការងារបច្ចេកវិទ្យាក្នុងការផលិត និងបង្ហោះនូវសម្ភារៈសិក្សា ទាំងមាតិកានិងទាំងអត្ថបទក្នុងផ្នែកសិក្សាធិការសាយប៊ើរ។

យន្តការជាច្រើនត្រូវបានអនុវត្តរួមគ្នាជាប្រចាំដូចក្នុងតារាងខាងក្រោម៖

**តារាងទី១៨. យន្តការទំនាក់ទំនង រវាង ស.ភ.ភ.ព វិស័យឯកជន និងសហគមន៍**

| សាកលវិទ្យាល័យ | វិស័យឯកជន/ឧស្សាហកម្ម | សហគមន៍ |
|---|---|---|
| 1. បង្កើតបណ្តាញការងារដើម្បីសម្របសម្រួលជាមួយឧស្សាហកម្ម ក្នុងការរៀបចំព្រឹត្តិការណ៍ កម្មវិធីពិព័ណ៌សមិទ្ធផល ផលិតផលថ្មីៗ និងផ្សព្វផ្សាយស្នាដៃស្រាវជ្រាវថ្មីៗ។ | - ផ្តល់កិច្ចសហការ និងឱកាសដល់សាកលវិទ្យាល័យក្នុងការចូលរួមសហការ។ | - ផ្តល់ទំនុកចិត្ត និងបើកឱកាសសម្រាប់ការរួមចំណែកអភិវឌ្ឍ។<br>- បង្ហាញពីតម្រូវការដែលជួបបញ្ហាប្រឈមដើម្បីឱ្យភាគីពាក់ព័ន្ធចូលរួមដោះស្រាយ។ |
| 2. រៀបចំវេទិកាប្រចាំឆ្នាំដើម្បីបង្ហាញពីសមិទ្ធផលស្រាវជ្រាវ ឬវេទិកាពិភាក្សាគោលនយោបាយរវាងអ្នកស្រាវជ្រាវ និងភាគីពាក់ព័ន្ធ។ | - ផ្តល់ការឧបត្ថម្ភគាំទ្រជាថវិកា បច្ចេកទេស ចំណេះដឹង ជំនាញ និងចូលរួមផ្តល់យោបល់កែលម្អ ចំណុចខ្វះចន្លោះ។ | - ផ្តល់ឱកាសចូលរួម និងគាំទ្រសមិទ្ធផលស្រាវជ្រាវដែលជាស្នាដៃរបស់អ្នកស្រាវជ្រាវជាតិ។ |
| 3. រៀបចំគម្រោងស្រាវជ្រាវរួមគ្នាជាមួយវិស័យឯកជន និងឧស្សាហកម្ម។ | - ផ្តល់ឱកាសជូនអ្នកស្រាវជ្រាវ និងនិស្សិតឱ្យទទួលបាននូវចំណេះដឹង និងបច្ចេកទេសដែលជាតម្រូវការក្នុងស្ថាប័នការងារ។ | - ផ្តល់ទំនុកចិត្តក្នុងការប្រើប្រាស់ផលិតផលស្រាវជ្រាវក្នុងស្រុកដើម្បីជាការលើកទឹកចិត្តដល់គ្រឹះស្ថានឧត្តមសិក្សា អ្នកស្រាវជ្រាវ និស្សិត និងឧស្សាហកម្មក្នុងការបង្កើតផលិតផលក្នុងស្រុកឱ្យបានកាន់តែប្រសើរ។ |
| 4. ផ្តល់ឱកាសជូនអ្នកស្រាវជ្រាវ និងនិស្សិតចុះកម្មសិក្សាស្រាវជ្រាវនៅតាម | - ផ្តល់ព័ត៌មានគ្រឡប់ដើម្បីអភិវឌ្ឍគ្រឹះស្ថាន អ្នកស្រាវជ្រាវ និងនិស្សិត។ | - ផ្តល់ព័ត៌មានគ្រឡប់ដើម្បីអភិវឌ្ឍគ្រឹះស្ថាន អ្នកស្រាវជ្រាវ និងនិស្សិត។ |

| | | |
|---|---|---|
| ក្រុមហ៊ុន ឧស្សាហកម្ម និង សហគមន៍។ | | |

# ជំពូកទី៤
# ក្របខណ្ឌអនុវត្តប្រព័ន្ធផ្តល់ថាមពលគាំទ្រការងារស្រាវជ្រាវ

## ១. ការកសាងកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ

ក្រៅពីបង្រៀននិងការងារការិយាល័យ បុគ្គលិកអប់រំ ស.ភ.ភ.ព. ក៏មានតួនាទីចូលរួមកាងារស្រាវជ្រាវ និងបង្កើតផលិតផលថ្មីពីការស្រាវជ្រាវ។ មជ្ឈមណ្ឌលគាំទ្រការស្រាវជ្រាវ និងនវានុវត្តន៍ត្រូវធ្វើការជាមួយដេប៉ាតឺម៉ង់នីមួយៗដើម្បីលើកកម្ពស់វប្បធម៌ស្រាវជ្រាវសម្រាប់បោះពុម្ពផ្សាយ និងបង្កើតផលិតផលថ្មី។ ជាងនេះទៅទៀត ដេប៉ាតឺម៉ង់នីមួយៗត្រូវមានកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំជាមួយបុគ្គលិកអប់រំ ស.ភ.ភ.ព. ដោយផ្តោតលើការបង្រៀនផង និងការស្រាវជ្រាវផង។ ការវាយតម្លៃសមិទ្ធផលការងារក្នុងដេប៉ាតឺម៉ង់ត្រូវមានតុល្យភាពរវាងការបង្រៀននិងការស្រាវជ្រាវ។ ក្រៅពីការបង្រៀនតាមម៉ោងកំណត់របស់ ស.ភ.ភ.ព ឬដេប៉ាតឺម៉ង់នីមួយៗ បុគ្គលិកអប់រំ ស.ភ.ភ.ព. ត្រូវចូលរួមសកម្មភាពស្រាវជ្រាវដូចក្នុងតារាងខាងក្រោម។

**តារាងទី១៩. កិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំរវាងស.ភ.ភ.ព. និងបុគ្គលិកអប់រំ ស.ភ.ភ.ព.**

| ល. | សកម្មភាព | ឆ្នាំ |
|---|---|---|
| 1 | ប្រធានគម្រោង (Principle Investigator) យ៉ាងតិចមួយគម្រោងក្នុងរយៈពេល | 3 |
| 2 | សមាជិកគម្រោងយ៉ាងតិចមួយគម្រោងក្នុងរយៈពេល | 2 |
| 3 | អ្នកបង្ហាញលទ្ធផលស្រាវជ្រាវក្នុងស្រុកម្តងក្នុងរយៈពេល | 1 |
| 4 | អ្នកបង្ហាញលទ្ធផលស្រាវជ្រាវក្នុងតំបន់/អន្តរជាតិម្តងក្នុងរយៈពេល | 2 |
| 5 | បោះពុម្ពទស្សនាវដ្តីវិទ្យាស្រ្តក្នុងស្រុកមួយក្នុងរយៈពេល | 2 |
| 6 | បោះពុម្ពទស្សនាវដ្តីវិទ្យាស្រ្តក្នុងស្រុកមួយអត្ថបទក្នុងរយៈពេល | 3 |
| 7 | បោះពុម្ពទស្សនាវដ្តីវិទ្យាស្រ្តក្នុងអន្តរជាតិមួយក្នុងរយៈពេល | 5 |
| 8 | បង្កើតផលិតផលគំរូមួយក្នុងរយៈពេល | 3 |
| 9 | ដាក់ប៉ាតង់មួយក្នុងរយៈពេល | 5 |
| 10 | លក់ប៉ាតង់មួយក្នុងរយៈពេល | 5 |

សាកលវិទ្យាល័យត្រូវកំណត់តំណែងស្រាវជ្រាវចំនួនពីរគឺ តំណែងអ្នកស្រាវជ្រាវបទពិសោធតិច និងតំណែងអ្នកស្រាវជ្រាវបទពិសោធច្រើនសម្រាប់បុគ្គលិកអប់រំក្របខណ្ឌ និងកិច្ចសន្យា។ មានតែបុគ្គលិកអប់រំក្របខណ្ឌ និងបុគ្គលិកកិច្ចសន្យា ស.ភ.ភ.ព. ប៉ុណ្ណោះ ដែលអាចមានសិទ្ធិដាក់ពាក្យសុំចូលរួមប្រកួតប្រជែងយកតំណែងស្រាវជ្រាវណាមួយ។ អ្នកដែលត្រូវបានជ្រើសរើសនឹងទទួលបានថវិកាលើកទឹកចិត្តបន្ថែមជារៀងរាល់ខែពី ស.ភ.ភ.ព.។ នៅពេលទទួលបានប្រាក់ឧបត្ថម្ភនេះ អ្នកស្រាវជ្រាវនោះនឹងត្រូវបានតម្រូវឱ្យកាត់បន្ថយចំនួនម៉ោងបង្រៀន និងផ្តោតលើសកម្មភាពស្រាវជ្រាវ។ ការជ្រើសរើសយកអ្នកស្រាវជ្រាវ

ចូលកាន់តំណែងស្រាវជ្រាវនីមួយៗត្រូវធ្វើជារៀងរាល់ឆ្នាំដោយគណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

**ក. សម្រាប់តំណែងអ្នកស្រាវជ្រាវបទពិសោធតិច បេក្ខជនត្រូវមាន៖**

- សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិតមួយពីសាកលវិទ្យាល័យដែលមានការទទួលស្គាល់ជាផ្លូវការ។
- សមត្ថភាពប្រមូលនិងវិភាគទិន្នន័យ និងសរសេរអត្ថបទស្រាវជ្រាវផ្នែកទ្រឹស្តីសម្រាប់បោះពុម្ព។
- ការបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រក្នុងបណ្តាញទស្សនាវដ្តីថ្នាក់ជាតិនិងតំបន់ ដូចជា ASEAN citation index ជាដើម។

**ខ. សម្រាប់តំណែងអ្នកស្រាវជ្រាវបទពិសោធច្រើន បេក្ខជនត្រូវមាន៖**

- ទទួលបានបណ្ឌិតពីសាកលវិទ្យាល័យដែលមានការទទួលស្គាល់ជាផ្លូវការ។
- មានសមត្ថភាពប្រមូលនិងវិភាគទិន្នន័យ និងសរសេរអត្ថបទស្រាវជ្រាវផ្នែកទ្រឹស្តីសម្រាប់ការបោះពុម្ពផ្សាយ។
- ការបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីដែលពិនិត្យដោយអ្នកវិទ្យាសាស្ត្រ ក្នុងទស្សនាវដ្តីអន្តរជាតិ ដូចជា SCI, ISI, និង Scopus ជាដើម។

អ្នកដែលស្ថិតក្នុងតំណែងស្រាវជ្រាវបទពិសោធតិចនឹងត្រូវការបង្កើតផលិតផលថ្មី ឬបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្តីដែលពិនិត្យដោយអ្នកវិទ្យាសាស្ត្រជាតិ ឬតំបន់ យ៉ាងតិចមួយក្នុងរយៈពេល២ឆ្នាំ។ ចំណែកអ្នកដែលមានតំណែងស្រាវជ្រាវបទពិសោធច្រើននឹងត្រូវបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្តីអន្តរជាតិដូចជា SCI, ISI, និង Scopus ជាដើម យ៉ាងតិចមួយក្នុងរយៈពេល២ឆ្នាំដែរ។

ការតែងតាំងបុគ្គលិកស្រាវជ្រាវចូលតំណែងស្រាវជ្រាវនីមួយៗត្រូវធ្វើជារៀងរាល់ឆ្នាំ ដោយមានកិច្ចសន្យាច្បាស់លាស់។ គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវនឹងពិនិត្យកិច្ចសន្យាទាំងនោះឡើងវិញជារៀងរាល់ឆ្នាំ ដើម្បីផ្ទៀងផ្ទាត់លទ្ធផល ឬវឌ្ឍនភាពការងារនិងលក្ខខណ្ឌបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវ ឬការបង្កើតផលិតផលថ្មី។ កិច្ចសន្យានឹងត្រូវបានបន្តចំពោះអ្នកស្រាវជ្រាវណាដែលបានបំពេញតាមលក្ខខណ្ឌក្នុងកិច្ចសន្យា។ កិច្ចសន្យានឹងត្រូវបានបញ្ចប់ចំពោះអ្នកស្រាវជ្រាវណាដែលពុំមានលទ្ធភាពបំពេញតាមលក្ខខណ្ឌក្នុងកិច្ចសន្យា។

## ២. ការវាយតម្លៃការអនុវត្តការងារស្រាវជ្រាវ

គិតត្រឹមបច្ចុប្បន្ន សាកលវិទ្យាល័យមានអនុស្សរណៈយោគយល់ (MoU) ចំនួន២២០ ជាមួយប្រទេសចំនួន២៧ ក្នុងនោះ ស.ភ.ភ.ព. មានទំនាក់ទំនងជាដៃគូយ៉ាងជិតស្និតជាមួយសាកលវិទ្យាល័យនៅបណ្តាប្រទេសអាស៊ាន ចិន ជប៉ុន កូរ៉េខាងត្បូង អាមេរិក អូស្ត្រាលី កាណាដា និងរុស្ស៊ី។ ភាពជាដៃគូអន្តរជាតិ

បានដើរតួយ៉ាងសំខាន់ក្នុងការបង្កើនសកម្មភាពស្រាវជ្រាវតាមរយៈការកសាងសមត្ថភាព សហប្រតិបត្តិការស្រាវជ្រាវ ការបោះពុម្ព និងការផ្សព្វផ្សាយ។ ដូច្នេះ ស.ភ.ភ.ព. ត្រូវៈ

- ពង្រឹងកិច្ចសហប្រតិបត្តិការស្រាវជ្រាវគ្រប់វិស័យជាមួយអ្នកស្រាវជ្រាវ វិទ្យាស្ថានស្រាវជ្រាវ និងមជ្ឈមណ្ឌលស្រាវជ្រាវ ទាំងកម្រិតជាតិ កម្រិតតំបន់ និងកម្រិតអន្តរជាតិ។
- ពង្រីកឱកាសជូនបុគ្គលិកស្រាវជ្រាវ ដើម្បីចូលរួមក្នុងកម្មវិធីផ្លាស់ប្តូរបទពិសោធនានាដូចជា ការផ្តល់អាហារូបករណ៍ស្រាវជ្រាវថ្នាក់ក្រោយបណ្ឌិត និងឱកាសអភិវឌ្ឍវិជ្ជាជីវៈផ្សេងៗទៀត។ ក្នុងន័យនេះ ស.ភ.ភ.ព. ត្រូវស្វែងរកកន្លែងសមស្របនៅតាមគ្រឹះស្ថានស្រាវជ្រាវអន្តរជាតិនានាសម្រាប់ដាក់បុគ្គលិករយៈពេលវែងឬខ្លី ឬធ្វើជាម្ចាស់ផ្ទះទទួលអ្នកស្រាវជ្រាវមកពីក្រៅ។

មជ្ឈមណ្ឌលគាំទ្រការស្រាវជ្រាវនិងនវានុវត្តន៍ត្រូវធ្វើការជាមួយដេប៉ាតឺម៉ង់នីមួយៗ ដើម្បីធ្វើចំណាត់ថ្នាក់និងកំណត់គុណភាពទស្សនាវដ្តីស្រាវជ្រាវតាមវិស័យនីមួយៗផ្សេងៗគ្នា ដោយផ្អែកលើសន្ទស្សន៍ដកស្រង់ (Citation Index) ដែលមានការទទួលស្គាល់ក្នុងប្រទេស ក្នុងតំបន់ និងជាអន្តរជាតិដូចជា ISI, Scopus និងសន្ទស្សន៍ដកស្រង់ដទៃទៀត។ គុណភាពនៃស្នាដៃស្រាវជ្រាវត្រូវបានវាយតម្លៃដោយសន្ទស្សន៍ដកស្រង់នីមួយៗតាមវិធីផ្សេងគ្នា។

**តារាងទី២០. លក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់គ្រឿងលើកទឹកចិត្ត**

| ប្រភេទ | សន្ទស្សន៍ | កម្រិតផលជះ | គ្រឿងលើកទឹកចិត្ត |
|---|---|---|---|
| 1 | • Institute for Scientific Information (ISI)<br>• Science Citation Index (SCI)<br>• Science Citation Index Expension (SCIE)<br>• Scopus | កម្រិតផលជះ ≥ 1 | ថវិកានិង ប័ណ្ណសរសើរថ្នាក់លេខ 1 |
| 2 | • Institute for Scientific Information (ISI)<br>• Science Citation Index (SCI)<br>• Scopus<br>• Emerging Sources Citation Index (ESCI) | កម្រិតផលជះ < 1 | ថវិកានិង ប័ណ្ណសរសើរថ្នាក់លេខ 2 |
| 3 | • Accredited international citation indexes (i.e., ACI, ESCI, CAB Abstracts, Aqualine Abstracts, Cambridge Scientific Abstracts, Environment Abstracts, GEO | មិនបាច់គិត | ថវិកានិង ប័ណ្ណសរសើរថ្នាក់លេខ 3 |

| | | | |
|---|---|---|---|
| | Abstracts, IBZ/IBR, Science Citation Index and ICEA.) | | |
| 4 | Regional and national citation indexes (i.e., Google Scholar, EZB, and WorldCat) | មិនបាច់គិត | ថវិកានិងប័ណ្ណសរសើរថ្នាក់លេខ 4 |

- **ប្រភេទទី១** ត្រូវបានផ្តល់ជូនអ្នកស្រាវជ្រាវដែលមានអត្ថបទបោះពុម្ពផ្សាយក្នុងទស្សនាវដ្តី SCI ឬ ISI ឬ Scopus ដូចក្នុងតារាងខាងលើ។ អ្នកស្រាវជ្រាវដែលមានលក្ខណៈវិនិច្ឆ័យប្រភេទទី១នេះនឹងទទួលបានការលើកទឹកចិត្តជាថវិកានិងប័ណ្ណសរសើរថ្នាក់លេខ១។
- **ប្រភេទទី២** ត្រូវបានផ្តល់ជូនអ្នកស្រាវជ្រាវដែលមានអត្ថបទបោះពុម្ពផ្សាយក្នុងទស្សនាវដ្តី SCI ឬ ISI ឬ Scopus ឬ ESCI ដូចក្នុងតារាងខាងលើ។ អ្នកស្រាវជ្រាវដែលមានលក្ខណៈវិនិច្ឆ័យប្រភេទទី២នេះនឹងទទួលបានការលើកទឹកចិត្តជាថវិកានិងប័ណ្ណសរសើរថ្នាក់លេខ២។
- **ប្រភេទទី៣** ត្រូវបានផ្តល់ជូនអ្នកស្រាវជ្រាវដែលមានអត្ថបទបោះពុម្ពផ្សាយក្នុងទស្សនាវដ្តី ដែលមានសន្ទស្សន៍ដកស្រង់ត្រូវបានទទួលស្គាល់ជាអន្តរជាតិ ដូចក្នុងតារាងខាងលើ។ អ្នកស្រាវជ្រាវដែលមានលក្ខណៈវិនិច្ឆ័យប្រភេទទី៣នេះនឹងទទួលបាននូវការលើកទឹកចិត្តជាថវិកា និងប័ណ្ណសរសើរថ្នាក់លេខ៣។
- **ប្រភេទទី៤** ត្រូវបានផ្តល់ជូនអ្នកស្រាវជ្រាវដែលមានអត្ថបទបោះពុម្ពផ្សាយក្នុងទស្សនាវដ្តី ដែលមានសន្ទស្សន៍ដកស្រង់ថ្នាក់ជាតិនិងថ្នាក់តំបន់ដូចក្នុងតារាងខាងលើ។ អ្នកស្រាវជ្រាវដែលមានលក្ខណៈវិនិច្ឆ័យប្រភេទទី៤នេះនឹងទទួលបានការលើកទឹកចិត្តជាថវិកា និងជាប័ណ្ណសរសើរថ្នាក់លេខ៤។

**ឧទាហរណ៍និងសេចក្តីពន្យល់ស្តីពីសន្ទស្សន៍ដកស្រង់៖**

១. **The Institute for Scientific Information (ISI)** គឺជាវិទ្យាស្ថានបម្រើសេវាកម្មបោះពុម្ពផ្សាយអត្ថបទសិក្សាស្រាវជ្រាវ នៅទីក្រុង Philadelphia ដែលត្រូវបានបង្កើតឡើងដំបូងគេដោយអ្នកវិទ្យាសាស្ត្រមួយរូបឈ្មោះ Eugene Garfield នៅទសវត្សឆ្នាំ១៩៦០។ វិទ្យាស្ថាននេះផ្តល់សេវាផ្សេងៗទាក់ទងនឹងមូលដ្ឋានទិន្នន័យវិទ្យាសាស្ត្រនិងគន្ថនិទ្ទេស ដែលមានជំនាញក្នុងការធ្វើលិបិក្រមនិងការវិភាគសន្ទស្សន៍ដកស្រង់ (Citation Index)។ បញ្ជីទស្សនាវដ្តីស្រាវជ្រាវជាង ១៤០០០ក្បាល មានរក្សាទុកក្នុងវិទ្យាស្ថាននេះ ក្នុងនោះ ផ្នែកសង្គមសាស្ត្រនិងមនុស្សសាស្ត្រមានប្រហែល១១០០ចំណងជើង។ បញ្ជីនេះមានក្នុងគេហទំព័រ http://mjl.clarivate.com។

២. **The Science Citation Index (SCI)** ក៏ត្រូវបានបង្កើតឡើងជាផ្នែកមួយរបស់អ្នកវិទ្យាសាស្ត្រឈ្មោះ Eugene Garfield ដែរ។ ចាប់តាំងពីឆ្នាំ១៩៩០ SCI បានពង្រីកខ្លួនកាន់តែធំ។ រហូតមកទល់ពេលនេះ SCI រក្សាទុកជាង ៨៥០០ទស្សនាវដ្តី ទាក់ទងនឹង ១៥០មុខវិជ្ជា ដែលអ្នក

ស្រាវជ្រាវអាចរកបានតាមវិធីច្រើនយ៉ាងដូចជា Web of Science and SciSearch ជាដើម។ ស្នាដៃស្រាវជ្រាវមួយចំនួនតូចដែលត្រូវបានវាយតម្លៃដោយ SCI ក៏មានការផ្សព្វផ្សាយដោយបោះពុម្ពជា CD និងជាទស្សនាវដ្តីផងដែរ។ មូលដ្ឋានទិន្នន័យ SCI នេះមានភាពងាយស្រួលដល់អ្នកស្រាវជ្រាវ ក្នុងការតាមដានអត្ថបទដែលបានដកស្រង់ពីស្នាដៃមុនៗរបស់ខ្លួន ហើយថែមទាំងអាចកំណត់បាននូវស្នាដៃដែលត្រូវបានគេដកស្រង់ច្រើនបំផុតក្នុងវិស័យឬប្រធានបទណាមួយទៀតផង។ បញ្ជីទស្សនាវដ្តីដែលគ្រប់គ្រងដោយ SCI អាចរកបានតាមគេហទំព័រ https://www.scijournal.org។

៣. **Scopus** គឺជាមូលដ្ឋានទិន្នន័យនៃសង្ខិត្តន័យ (Abstaract) និងការដកស្រង់ (Citation) ដែលត្រូវបានបង្កើតឡើងដោយ Elsevier ក្នុងឆ្នាំ២០០៤។ មូលដ្ឋានទិន្នន័យនេះមានស្នាដៃចំនួន៣៦៣៧៧ចំណងជើង (ចំណងជើងសកម្ម ២២.៧៩៤ និងអសកម្ម ១៣.៥៨៣) ដែលបានពីក្រុមហ៊ុនបោះពុម្ពផ្សាយចំនួន១១៦៧៨។ **Scopus** ជាមូលដ្ឋានទិន្នន័យដែលមានផ្ទុកអត្ថបទស្រាវជ្រាវប្រកបដោយគុណភាពខ្ពស់តាមមុខវិជ្ជានីមួយៗ ហើយមានទស្សនាវដ្តីដែលបានពិនិត្យយ៉ាងហ្មត់ចត់ពីក្រុមអ្នកវិទ្យាសាស្ត្រ ចំនួន៣៤៣៤៦។ ប្រភពបីប្រភេទគឺ ស៊េរីសៀវភៅ (Book Series) ទស្សនាវដ្តី និងទស្សនាវដ្តីពាណិជ្ជកម្ម ត្រូវបានវាយតម្លៃជារៀងរាល់ឆ្នាំ ដើម្បីរក្សាស្តង់ដាគុណភាពខ្ពស់។ Scopus មានរង្វាស់គុណភាពបួនយ៉ាង សម្រាប់វាយតម្លៃចំណងជើងនីមួយៗគឺ h-Index, CiteScore, SCImago Journal Rank (SJR) និង Source Normalized Impact per Paper (SNIP)។ បញ្ជីទស្សនាវដ្តីដែលគ្រប់គ្រងដោយ Scopus អាចរកបានតាមគេហទំព័រ https://www.scopus.com។

៤. **The Emerging Sources Citation Index (ESCI)** គឺជាមូលដ្ឋានទិន្នន័យថ្មីមួយនៅក្នុង Web of Science ដែលបានចាប់ផ្តើមនៅចុងឆ្នាំ២០១៥។ ពេលផ្តើមដំបូង ESCI មានទស្សនាវដ្តីប្រហែល៣០០០ ទាក់ទងនឹងគ្រប់មុខវិជ្ជា។ ទស្សនាវដ្តីមួយត្រូវទទួលបានជ្រើសរើសពី ESCI ជាមុនសិន ទើបអាចដាក់ពាក្យសុំចុះក្នុងបញ្ជីបណ្តាញសន្ទស្សន៍វិទ្យាសាស្ត្រ (Web of Science indexes) ដទៃទៀតដូចជា SCI, SSCI, និង AHCI (the Arts and Humanities Citation Index) ជាដើម។ ទស្សនាវដ្តី ដែលបានដាក់ស្នើសុំវាយតម្លៃចូលក្នុង Web of Science databases ធំៗទាំងនេះ ត្រូវបានទទួលចុះក្នុងបញ្ជី ESCI ដោយមានការត្រួតពិនិត្យគុណភាពនិងកែលម្អកាន់តែស៊ីជម្រៅ។ បញ្ជីទស្សនាវដ្តីនៅ ESCI អាចរកបានតាមគេហទំព័រ http://mjl.clarivate.com/cgi-bin/jrnlst/jlresults.cgi ។

៥. **Accredited international citations** ទទួលបានពីទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ ដែលមានគ្រប់មុខវិជ្ជាទាំងអស់ និងមានជាច្រើនភាសាដែលត្រូវបានគ្រប់គ្រងដើម្បីគុណភាពដោយផ្អែកលើសន្ទស្សន៍ដកស្រង់ទាំងនេះ។ ទស្សនាវដ្តីនីមួយៗត្រូវបានចាត់ថ្នាក់ដោយផ្អែកលើចំនួននៃការដកស្រង់ (Number of Citations) ដែលបង្ហាញពីកត្តាផលជះថា តើការស្រាវជ្រាវនេះមានឥទ្ធិពលយ៉ាងណា។ **Accredited international citations** មាននៅក្នុងមូលដ្ឋានទិន្នន័យមួយ

ចំនួន ដូចជា the Bibliography of Asian Studies; the International Bibliography of the Social Sciences; International Political Science Abstracts; the Public Affairs Information Service; the Centre for Agriculture and Bioscience International (CABI) and NHN។ ដោយសារពុំមានសន្ទស្សន៍ណាមួយអាចបញ្ជាក់ថា សេចក្តីដកស្រង់នៃស្នាដៃស្រាវជ្រាវមួយត្រូវបានទទួល accredited international citation គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ ស.ភ.ភ.ព. នឹងវាយតម្លៃគុណភាពស្រាវជ្រាវដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានពីប្រភពដែលមាន។

៦. **National and regional citation indices** គឺជាមូលដ្ឋានទិន្នន័យដែលត្រូវបានបង្កើតឡើងដើម្បីធ្វើសន្ទស្សន៍កំណត់ត្រាគន្ថនិទ្ទេសនិងការដកស្រង់លើស្នាដៃស្រាវជ្រាវ ដែលមានគុណភាពក្នុងទស្សនាវដ្តីស្រាវជ្រាវនៅកម្ពុជានិងបណ្តាប្រទេសអាស៊ានដទៃទៀត។ ទស្សនាវដ្តីទាំងនេះមានបោះពុម្ពផ្សាយជាច្រើននៅប្រទេសប្រ៊ុយណេដារូសាឡឹម កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។ ដោយសារពុំមានសន្ទស្សន៍ណាមួយបញ្ជាក់ថា ស្នាដៃស្រាវជ្រាវមួយទទួលបានការដកស្រង់ថ្នាក់ជាតិឬថ្នាក់តំបន់ គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវនឹងវាយតម្លៃគុណភាពនៃស្នាដៃស្រាវជ្រាវដោយផ្អែកលើប្រភពដែលមាន។

៧. **Open access journals** គឺជាស្ថាប័នដែលគាំទ្រខ្លួនឯងនិងមិនទទួលថវិកាពីស្ថាប័នខាងក្រៅឬរដ្ឋាភិបាលឡើយ។ ស្ថាប័នប្រភេទនេះដំណើរការបានដោយទទួលថវិកាពីការបង់ថ្លៃរបស់អ្នកនិពន្ធតែម្យ៉ាងគត់ មិនទទួលបានកម្រៃពីការលក់ទស្សនាវដ្តីទេ ព្រោះអ្នកសិក្សាស្រាវជ្រាវអាចចូលប្រើប្រាស់តាមអ៊ីនធើណិតបានដោយសេរី។ ជាទូទៅ អ្នកនិពន្ធត្រូវបង់ថ្លៃសម្រាប់ចាត់ចែងកិច្ចការនានាដែលពាក់ព័ន្ធនឹងការបោះពុម្ព បន្ទាប់ពីសំណៅដើមរបស់ខ្លួនត្រូវបានទទួលយកសម្រាប់ការបោះពុម្ពផ្សាយ។ ដោយសារមិនមានប្រភពជាក់លាក់ណាមួយបញ្ជាក់ថា អត្ថបទក្នុងទស្សនាវដ្តីត្រូវបានធ្វើសន្ទស្សន៍ដកស្រង់ដោយស្ថាប័ននេះ គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ ស.ភ.ភ.ព. នឹងវាយតម្លៃស្នាដៃស្រាវជ្រាវដោយផ្អែកលើប្រភពដែលមាន។

បន្ទាប់ពីអត្ថបទស្រាវជ្រាវត្រូវបានដាក់ជូនពិនិត្យសម្រាប់ការបោះពុម្ពផ្សាយ ការវាយតម្លៃគុណភាពនឹងត្រូវបានធ្វើភ្លាមៗ ដោយមានសេចក្តីបញ្ជាក់ថា អត្ថបទស្រាវជ្រាវនេះមានគុណភាពដល់កម្រិតអាចឬមិនអាចបោះពុម្ពផ្សាយបាន។ ផលជះនៃស្នាដៃស្រាវជ្រាវនឹងត្រូវបានវាស់វែងដោយការរាប់ចំនួនដកស្រង់ (Citation counts), the h-index និងកត្តាផលជះនានានៃទស្សនាវដ្តី។ សន្ទស្សន៍ដកស្រង់របស់ Google នឹងត្រូវបានច្នៃជាឧបករណ៍ប្រើប្រាស់ ដើម្បីដឹងពីស្ថានភាពអំណាន និងចំនួនដកស្រង់នៃស្នាដៃស្រាវជ្រាវរបស់អ្នកស្រាវជ្រាវ ស.ភ.ភ.ព.។ ការិយាល័យស្រាវជ្រាវត្រូវធ្វើការជាមួយអ្នកស្រាវជ្រាវ ស.ភ.ភ.ព. ដើម្បីបង្កើតគណនី Google citation ផ្ទាល់ខ្លួន ដែលនឹងត្រូវតភ្ជាប់ទៅនឹងបណ្ណសារ ស.ភ.ភ.ព. ដែលជាកន្លែងរក្សាទុកឯកសារស្រាវជ្រាវអនឡាញ។

## ២.១. កិច្ចការដែលត្រូវរៀបចំនិងផ្តល់ការណែនាំមុនពេលវាយតម្លៃ

ការណែនាំមុនពេលវាយតម្លៃ៖

(១) របៀបនៃការបង្ហាញលទ្ធផលតាមរយៈការរាយការណ៍ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ឬប្រចាំខែ ទៅកាន់អ្នកគ្រប់គ្រងផ្ទាល់របស់ខ្លួន

(២) កំណត់កាលបរិច្ឆេទ និងការរៀបចំកិច្ចប្រជុំ ដើម្បីបង្ហាញរបាយការណ៍វឌ្ឍនភាពប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ដែលជាភស្តុតាងនៃកិច្ចការបានអនុវត្ត និងលទ្ធផលសម្រេចបានតាមកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ

(៣) ពិភាក្សា និងកំណត់ឱ្យបានច្បាស់លាស់ក្នុងការផ្តល់ផែនការដែលត្រូវសម្រេច និងដំណោះស្រាយបញ្ហាប្រឈមដែលជួយគាំទ្រដល់ការអនុវត្ត និង

(៤) ការពន្យល់ ឬបង្ហាញពីតម្រូវការនៃនីតិវិធីនៃការវាយតម្លៃ និងកំណត់កាលបរិច្ឆេទវាយតម្លៃការអនុវត្តការងារឱ្យបានជាក់លាក់។

## ២.២. ដំណើរការវាយតម្លៃ

ពិនិត្យតាមដាន និងវាយតម្លៃកិច្ចការរៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវមាន៣ទម្រង់៖

(១) ពិនិត្យតាមដានលើការរៀបចំ និងអនុវត្តការគ្រប់គ្រងការស្រាវជ្រាវ រៀងរាល់ត្រីមាស ដោយការិយាល័យគាំទ្រការស្រាវជ្រាវ និង/ឬមជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍

(២) ពិនិត្យតាមដានលទ្ធផលនៃការអនុវត្ត និងគ្រប់គ្រងការស្រាវជ្រាវរៀងរាល់ឆមាសដោយ គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវរបស់គ្រឹះស្ថាន ដើម្បីពិនិត្យ ឬបញ្ជាក់ពីកិច្ចការដែលបានកំណត់ជាលាយលក្ខអក្សរពីដើមឆ្នាំ។ ការវាយតម្លៃនេះជាការជួយដល់បុគ្គលិកដែលមានបញ្ហាលំបាក ឬកិច្ចការសំខាន់ដែលសម្រេចបាន ឬក៏ជាការបង្ហាញពីកិច្ចការដែលត្រូវធ្វើបញ្ចប់នៅដំណាច់ឆ្នាំ។ ការវាយតម្លៃនេះត្រូវធ្វើឡើងតាមរយៈការសរសេររបាយការណ៍ស្វ័យវាយតម្លៃ ដោយពុំមានការដាក់ពិន្ទុ ហើយអាចបង្ហាញលទ្ធផល ឬកិច្ចពិភាក្សាតាមរយៈការប្រជុំបូកសរុបការងារ។

(៣) វាយតម្លៃផលសម្រេចតាមឆ្នាំ ដោយផ្តោតលើសូចនាករគន្លឹះដូចជា ចំនួនអ្នកស្រាវជ្រាវ ចំនួនគម្រោងស្រាវជ្រាវ និងសមត្ថភាពអ្នកស្រាវជ្រាវនិងស្ថាប័ន។ ក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកទទួលខុសត្រូវលើការពិនិត្យតាមដាន និងវាយតម្លៃ។ គ្រឹះស្ថានសាធារណៈរដ្ឋបាលអាចតែងតាំងជនបង្គោលមួយរូបសម្រាប់ទទួលខុសត្រូវការពិនិត្យតាមដាន និងវាយតម្លៃ។ ការវាយតម្លៃនេះមានគោលបំណងពិនិត្យ និងវាយតម្លៃសរុបនូវកិច្ចសន្យាលទ្ធផល និងផែនការប្រចាំឆ្នាំ។ ការវាយតម្លៃនៃការអនុវត្តនេះគឺធ្វើនៅចុងឆ្នាំ ឬចុងឆមាសទី២។ ការវាយតម្លៃនេះត្រូវធ្វើឡើងតាមរយៈកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ ដែលមានកាលបរិច្ឆេទកំណត់ច្បាស់លាស់ និងធ្វើតាមឋានានុក្រមគ្រប់គ្រងការស្រាវជ្រាវដែលបានកំណត់ក្នុងគ្រឹះស្ថាន។ ការវាយតម្លៃនេះជាការវាយតម្លៃការអនុវត្តការងាររបស់បុគ្គលិកអប់រំគ្រប់ស្រទាប់គ្រប់គ្រង

ហូតដល់អ្នកស្រាវជ្រាវតាមរយៈការផ្តល់ពិន្ទុ។ វង្វាយតម្លៃនៃការផ្តល់ពិន្ទុគឺត្រូវជានាតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងមានការផ្តល់មតិកែលម្អ ដើម្បីបំពេញបន្ថែម។ គំរូនៃការផ្តល់ពិន្ទុនេះផ្អែកតាមទម្រង់នៃការផ្តល់ពិន្ទុលើលទ្ធផលសម្រេចការងាររបស់បុគ្គលិកអប់រំ ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រនៃអនុវិស័យឧត្តមសិក្សាឆ្នាំ (២០២១-២០៣០)។

**តារាងទី២១. លក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់ពិន្ទុលើលទ្ធផលការងារ**

| លទ្ធផលអនុវត្តការងារ | កម្រិតពិន្ទុ |
|---|---|
| សម្រេចបានគ្រប់លទ្ធផលរំពឹងទុកនិងលើសផែនការ | 5 |
| សម្រេចគ្រប់លទ្ធផលរំពឹងទុកទាំងអស់ | 4 |
| សម្រេចលើសពី 60% ដល់ 85% នៃលទ្ធផលរំពឹងទុក | 3 |
| សម្រេចលើសពី 50% ដល់ 60% នៃលទ្ធផលរំពឹងទុក | 2 |
| សម្រេចទាបជាង 50% នៃលទ្ធផលរំពឹងទុក | 1 |

**សម្គាល់៖**

- អ្នកដែលបានពិន្ទុ ១ ឬ ២ មិនបង្ហាញគណនេយ្យភាពឡើយ ត្រូវបានផ្តល់ឱកាស ១ឆ្នាំបន្ត។ បើមិនមានការរីកចម្រើន ត្រូវស្នើទៅប្រធានក្រុមប្រឹក្សាភិបាល ដើម្បីមានវិធានការរដ្ឋបាល។
- អ្នកដែលបានពិន្ទុ៣ ត្រូវបានផ្តល់ឱកាស ២ឆ្នាំសម្រាប់កែលម្អនិងរៀនសូត្រ។
- អ្នកដែលបានពិន្ទុ៤ ជាកម្រិតដែលអាចទទួលរង្វាន់កម្រិតមធ្យម។
- អ្នកដែលបានពិន្ទុ៥ ជាបុគ្គលិកឆ្នើម ដែលត្រូវផ្តល់រង្វាន់ល្អប្រសើរ។

### ៣. ការផ្តល់រង្វាន់

ការផ្តល់គ្រឿងលើកទឹកចិត្តជាការលើកកម្ពស់ការអនុវត្តការងារនៅតាមគ្រឹះស្ថាន ដើម្បីបង្ហាញពីគុណតម្លៃ និងវប្បធម៌ការងាររបស់គ្រឹះស្ថាន ជាពិសេស ជាការបង្ហាញនូវការផ្តល់តម្លៃដល់ការងារជាក្រុមដែលបានខិតខំប្រឹងប្រែង ដើម្បីផលប្រយោជន៍អង្គភាពរបស់ខ្លួន។ គ្រឹះស្ថានអាចរៀបចំរង្វាន់ក៏ដូចជាការលើកទឹកចិត្តដល់បុគ្គលិកឆ្នើមលើការងារស្រាវជ្រាវតាមរូបភាពផ្សេងៗ អាស្រ័យលើស្ថានភាព លទ្ធភាព និងសមត្ថភាពរបស់គ្រឹះស្ថាន។ ប្រការដែលចាំបាច់គឺត្រូវតែបង្កើតឱ្យមានជាការលើកទឹកចិត្តដល់បុគ្គលិកអប់រំគ្រប់រូប ដែលអនុវត្តទទួលបានជោគជ័យតាមកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំរបស់ខ្លួន។ ការផ្តល់រង្វាន់លើកទឹកចិត្តបុគ្គលិកអប់រំអាចធ្វើបានតាមពីរប្រភេទគឺ៖

**ក. រង្វាន់ប្រចាំឆ្នាំពីការអនុវត្តប្រព័ន្ធវាយតម្លៃ**

- ការដំឡើងឋានៈ មុខតំណែង ការផ្តល់ឱកាសទទួលបានវគ្គបំប៉នវិជ្ជាជីវៈ ឬអាហារូបករណ៍សិក្សា ឬមូលនិធិគាំទ្រដល់ការពង្រីកការងារស្រាវជ្រាវ និងបោះពុម្ពផ្សាយស្នាដៃរបស់ខ្លួន និងការលើកទឹកចិត្តផ្សេងៗទៀត

- វត្ថុតាងជារូបភាពថ្លែងអំណរគុណ ឬលិខិតសរសើរចំពោះបុគ្គលិកអប់រំដែលបានបំពេញការងារតាមផែនការ

ខ. ប្រាក់ឧបត្ថម្ភប្រចាំខែ

- បុគ្គលិករដ្ឋដែលចូលរួមក្នុងគម្រោងស្រាវជ្រាវអាចទទួលបានប្រាក់ឧបត្ថម្ភប្រចាំឆ្នាំ/ខែ/ថ្ងៃ/ម៉ោង និង ឬសម្ភារៈ ពីម្ចាស់ជំនួយ បន្ថែមលើប្រាក់បៀវត្សរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- បុគ្គលិកកិច្ចសន្យាដែលចូលរួមក្នុងគម្រោងស្រាវជ្រាវអាចទទួលបានប្រាក់ឧបត្ថម្ភប្រចាំឆ្នាំ/ខែ/ថ្ងៃ/ម៉ោង និង ឬ សម្ភារៈ ពីម្ចាស់ជំនួយ បន្ថែមលើប្រាក់បៀវត្សប្រចាំខែ ដែលកំណត់ដោយសាកលវិទ្យាល័យ។

## ៤. ការអភិវឌ្ឍគន្លងអាជីពអ្នកស្រាវជ្រាវនៅ ស.ភ.ភ.ព.

នៅក្នុងយុទ្ធសាស្ត្រ១០ឆ្នាំ (២០២១- ២០៣០) ស.ភ.ភ.ព. កំពុងធ្វើការអភិវឌ្ឍគន្លងអាជីពដែលជាយន្តការលើកទឹកចិត្ត និងផ្តល់គន្លងអាជីពដើម្បីឱ្យបុគ្គលិកអប់រំ ស.ភ.ភ.ព. អាចអភិវឌ្ឍសមត្ថភាពខ្លួនបាន ដោយផ្តល់សេវាកម្មនានាដែលជួយអ្នកស្រាវជ្រាវនិងគ្រូបង្រៀនឱ្យយល់ដឹងពីទិសដៅក្នុងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ដោយចាប់ផ្តើមពីចំណុចណាមួយនៃមុខងារនិងតួនាទីរបស់ខ្លួន ហើយអាចនឹងឈានដល់ចំណុចណាមួយទៀត។ បន្ទាប់ពីការខិតខំយកចិត្តទុកដាក់បំពេញតួនាទីនិងអភិវឌ្ឍសមត្ថភាពជាបន្តបន្ទាប់ក្នុងពេលកំពុងបំពេញភារកិច្ចជាមួយទេពកោសល្យផ្ទាល់ខ្លួនផងនោះ បុគ្គលិកអប់រំ ស.ភ.ភ.ព. អាចឈានចាប់យកតួនាទីបន្តបន្ទាប់ទៀត។ គន្លងអាជីពនៅ ស.ភ.ភ.ព. បានបែងចែកជាបីប្រភេទតាមឋានានុក្រមដូចក្នុងតារាងខាងក្រោម។

**តារាងទី២២. ប្រភេទនៃគន្លងអាជីព**

| ល.រ. | ប្រភេទនៃគន្លងអាជីព | ឋានានុក្រម |
|---|---|---|
| 1 | គ្រប់គ្រង | – ព្រឹទ្ធបុរស ឬប្រធានវិទ្យាស្ថាន<br>– ព្រឹទ្ធបុរសរង ឬអនុប្រធានវិទ្យាស្ថាន<br>– ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់<br>– ប្រធាន/អនុប្រធានការិយាល័យ/បណ្ណាល័យ |
| 2 | គ្រូបង្រៀន | – សាស្ត្រាចារ្យ<br>– សាស្ត្រាចារ្យរង<br>– សាស្ត្រាចារ្យជំនួយ<br>– គ្រូឧទ្ទេសឧត្តមសិក្សា |
| 3 | មន្ត្រីផ្តល់សេវាគាំទ្រ/បុគ្គលិករដ្ឋបាល | – ប្រធានបុគ្គលិក និងរដ្ឋបាល<br>– បុគ្គលិកសេវាកម្មរដ្ឋបាល |

| | | |
|---|---|---|
| | | – បុគ្គលិកជំនាញ សេវាកម្ម រដ្ឋបាល<br>– បុគ្គលិកជំនាញជាន់ខ្ពស់ សេវាកម្មរដ្ឋបាល |

